# យុទ្ធសាស្រ្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេស

# COUNTRY DEVELOPMENT COOPERATION STRATEGY

(English version is available below the Khmer text)

(អត្ថបទជាភាសាអង់គ្លេស គឺនៅបន្ទាប់ពីភាសាខ្មែរ)

USAID | កម្ពុជា
ជំនួយពីពលរដ្ឋអាមេរិក



# យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេស (CDCS)

ខែ ធ្នូ ឆ្នាំ ២០២០ – ខែ ធ្នូ ឆ្នាំ ២០២៥

បានអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយជាសាធារណៈ

# មាតិកា

**មាតិកា** ....... **2**

**បញ្ជីពាក្យកាត់** ....... **3**

**ផែនទីប្រទេសកម្ពុជា** ....... **5**

**សេចក្តីសង្ខេបពិស្តារ** ....... **6**

រូបភាពទី ១៖ ក្របខណ្ឌលទ្ធផល CDCS ....... 12

**បរិបទប្រទេស** ....... **12**

កត្តាគួរឱ្យកត់សម្គាល់នៅក្នុងបរិបទកម្ពុជា ....... 13

ចំណុចអាទិភាពសំខាន់ក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ....... 21

ដំណើរឆ្ពោះទៅការពឹងផ្អែកលើខ្លួនឯង (J2SR)៖ ការវិភាគផែនទីបង្ហាញផ្លូវប្រទេស ....... 21

ផែនការអន្តរកាលប្រទេស ....... 23

**វិធីសាស្រ្តយុទ្ធសាស្រ្ត** ....... **24**

ការរៀបចំផែនការសេណារីយ៉ូ ....... 33

**ក្របខ័ណ្ឌលទ្ធផល** ....... **33**

គោលបំណងអភិវឌ្ឍន៍ទី ១៖ ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព ....... 34

គោលបំណងអភិវឌ្ឍន៍ទី ២៖ កែលម្អសុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា ....... 45

គោលបំណងអភិវឌ្ឍន៍ទី ៣៖ ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល ....... 57

**ការតាមដាន វាយតម្លៃ និងការសិក្សា (MEL)** ....... **69**

# បញ្ជីពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AIDS | ជំងឺអេដស៍ |
| CDCS | យុទ្ធសាស្រ្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេស |
| $CO_2$ | ឧស្ម័នកាបូនិក |
| COVID-19 | ជំងឺកូរ៉ូណា ២០១៩ (យោងតាម CDC) |
| CSO | អង្គការសង្គមស៊ីវិល |
| C-TIP | ការប្រឆាំងការជួញដូរមនុស្ស |
| DFAT | ក្រសួងការបរទេស និងពាណិជ្ជកម្ម (អូស្រ្តាលី) |
| DO | គោលបំណងអភិវឌ្ឍន៍ |
| EU | សហភាពអឺរ៉ុប |
| FDI | ការវិនិយោគផ្ទាល់ពីបរទេស |
| FSR | ការពឹងផ្អែកលើស្វ័យហិរញ្ញប្បទាន |
| GBV | អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GFATM | មូលនិធិសកលសម្រាប់ប្រយុទ្ធនឹងជំងឺអេដស៍ របេង និង ជំងឺគ្រុនចាញ់ |
| GIZ | *Gesellschaft für Internationale Zusammenarbeit* (ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ) |
| HEF | មូលនិធិសមធម៌សុខាភិបាល |
| HIV | វីរុសដែលធ្វើឱ្យប្រព័ន្ធការពាររាងកាយមនុស្សចុះខ្សោយ |
| ICS | យុទ្ធសាស្រ្តប្រទេសរួមបញ្ចូល |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ |
| TI | គំនិតផ្តួចផ្តើមតម្លាភាព (Transparency Initiative) |
| IR | លទ្ធផលរំពឹងទុក |
| J2SR | ដំណើរឆ្ពោះទៅការពឹងផ្អែកលើខ្លួនឯង |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| JSP | ផែនការយុទ្ធសាស្រ្តរួមរវាងទីភ្នាក់ងារជំនួយអាមេរិក USAID និងក្រសួងការបរទេសអាមេរិក |
| KfW | *Kreditanstalt für Wiederaufbau* (វិទ្យាស្ថានឥណទានអាល្លឺម៉ង់សម្រាប់ការកសាងឡើងវិញ) |
| KOICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |

| | |
|---|---|
| LGBTI | អ្នកស្រលាញ់ភេទដូចគ្នា |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEL | ការតាមដាន ការវាយតម្លៃ និងការសិក្សា |
| MOE | ក្រសួងបរិស្ថាន |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | ក្រសួងសុខាភិបាល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSS | យុទ្ធសាស្ត្រសន្តិសុខជាតិ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| PSE | ការចូលរួមរបស់វិស័យឯកជន |
| REDD+ | កម្មវិធីជាតិកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS-IV | យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព (ដំណាក់កាលទី IV) |
| TB | ជំងឺរបេង |
| TIP | អំពើជួញដូរមនុស្ស |
| UN | អង្គការសហប្រជាជាតិ |
| UNAIDS | កម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ |
| USG | រដ្ឋាភិបាលសហរដ្ឋអាមេរិក |
| V-Dem | ប្រភេទផ្សេងៗនៃប្រជាធិបតេយ្យ |
| WHO | អង្គការសុខភាពពិភពលោក |

# ផែនទីប្រទេសកម្ពុជា




គ្រួសារ & ភាពក្រីក្រតាមខេត្ត*

| ខេត្ត | ចំនួនគ្រួសារ | ប័ណ្ណក្រីក្រ |
|---|---|---|
| បន្ទាយមានជ័យ | 222,767 | 11% |
| បាត់ដំបង | 297,096 | 23% |
| កំពង់ចាម | 272,436 | 14% |
| កំពង់ឆ្នាំង | 147,658 | 18% |
| កំពង់ស្ពឺ | 191,045 | 12% |
| កំពង់ធំ | 189,801 | 17% |
| កំពត | 160,519 | 13% |
| កណ្ដាល | 311,148 | 10% |
| កោះកុង | 34,403 | 20% |
| ក្រចេះ | 94,456 | 21% |
| មណ្ឌលគិរី | 19,739 | 19% |
| ភ្នំពេញ | 201,267 | 8% |
| ព្រះវិហារ | 61,303 | 18% |
| ព្រៃវែង | 292,277 | 18% |
| ពោធិ៍សាត់ | 133,141 | 18% |
| រតនគិរី | 54,211 | 17% |
| សៀមរាប | 250,824 | 12% |
| ព្រះសីហនុ | 47,784 | 9% |
| ស្ទឹងត្រែង | 37,633 | 18% |
| ស្វាយរៀង | 153,025 | 14% |
| តាកែវ | 236,649 | 15% |
| ឧត្តរមានជ័យ | 79,021 | 10% |
| តាកែវ | 9,161 | 16% |
| ប៉ៃលិន | 22,216 | 20% |
| ត្បូងឃ្មុំ | 214,993 | 15% |
| **សរុប** | **3,734,573** | **15%** |

*ចំនួនប្រជាជនសរុបគឺ 15,288,489 ដែលមានទំហំផ្ទះ 4.6 (ជំរឿនថ្នាក់ជាតិ 2019) ដែលក្នុងនោះមាន 15% គឺជាជនក្រីក្រ (ទិន្នន័យប័ណ្ណក្រីក្រ 2019)**

## សេចក្តីសង្ខេបពិស្តារ

**សេចក្តីថ្លែងអំពីគោលដៅយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេស “ប្រទេសកម្ពុជា ក្លាយជាដៃគូកាន់តែបើកចំហ មានវិបុលភាព ភាពធន់ និងបរិយាបន្ននៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក”។** គោលដៅប្រកបដោយមហិច្ឆិតានេះឆ្លុះបញ្ចាំងអំពីសក្តានុពលក្នុងការពង្រឹងភាពជាដៃគូរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា។ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ស្ថិតក្រោមការដឹកនាំរបស់ប្រធានបេសកកម្ម និងដោយសហការជាមួយក្រុមប្រទេសអន្តរទីភ្នាក់ងារ អាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការពង្រឹងផលប្រយោជន៍ពីការអភិវឌ្ឍនៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ និងសហការជាមួយភាគីពាក់ព័ន្ធកម្ពុជាដើម្បីសម្រេចឱ្យបាននូវគោលដៅរួម។ គោលដៅគាំទ្រដល់វិធីសាស្ត្ររបស់សហរដ្ឋអាមេរិកសម្រាប់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកកាន់តែបើកចំហនិងសេរី និងជំរុញប្រទេសកម្ពុជាក្នុងដំណើរឆ្ពោះទៅរកការពឹងផ្អែកលើខ្លួនឯង តាមរយៈការអភិវឌ្ឍប្រកបដោយចីរភាព ការពង្រឹងអធិបតេយ្យភាព និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ។ ទីភ្នាក់ងារជំនួយអាមេរិក USAID នឹងធ្វើកិច្ចការដើម្បីសម្រេចគោលដៅនេះតាមរយៈគោលបំណងអភិវឌ្ឍន៍បំពេញបន្ថែមចំនួនបី៖ កំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព សុខភាព ការអប់រំ និងសុខុមាលភាពប្រជាជនកម្ពុជាមានភាពល្អប្រសើរតាមរយៈការលើកកម្ពស់សេវា និងការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល។ ជាងនេះទៅទៀត គោលដៅនេះពង្រឹងចំណុចអាទិភាពផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន[1] ជាពិសេសពាក់ព័ន្ធនឹងការលើកកម្ពស់ជីវភាព និងសុខុមាលភាព ការបង្កើនប្រសិទ្ធភាព និងគុណភាពសេវារដ្ឋាភិបាល និងការលើកកម្ពស់នីតិរដ្ឋ និងសិទ្ធិមនុស្ស។ យុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជានេះស្របនឹងយុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី IV និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣ ដែលបានកំណត់ “ចតុកោណយុទ្ធសាស្ត្រ” សម្រាប់ការអភិវឌ្ឍ៖ ១) ការអភិវឌ្ឍធនធានមនុស្ស ២) ពិពិធកម្មសេដ្ឋកិច្ច ៣) ការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន និងការងារ និង ៤) ការអភិវឌ្ឍលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព។

**ផែនទីបង្ហាញផ្លូវប្រទេស J2SR របស់ប្រទេសកម្ពុជាបង្ហាញថា រដ្ឋាភិបាលមានសមត្ថភាពខ្ពស់គួរសម ប៉ុន្តែពុំសូវមានការប្តេជ្ញាចិត្តឡើយ។** នៅកម្រិតខ្ពស់បំផុត ចំណុចសំខាន់ៗចំនួនពីរនៃផែនទីបង្ហាញផ្លូវប្រទេស[2] គឺពិន្ទុប្តេជ្ញាចិត្តកម្រិតទាបរបស់ប្រទេសកម្ពុជាសម្រាប់អភិបាលកិច្ចបើកចំហ និងប្រកបដោយគណនេយ្យភាព និងពិន្ទុសមត្ថភាពកម្រិតទាបសម្រាប់*សមត្ថភាពរដ្ឋាភិបាល* និង*សមត្ថភាពសង្គមស៊ីវិល*។ ការប្តេជ្ញាចិត្តចំពោះ*គោលនយោបាយបរិស្ថាន* ក៏មានកម្រិតទាបផងដែរ ដែលឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមទូទៅរបស់ប្រទេសពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តច្បាប់ការពារបរិស្ថាន រួមទាំងច្បាប់ដែលត្រូវបានរៀបចំឡើងដើម្បីទប់ស្កាត់ការកាប់ព្រៃឈើខុសច្បាប់ និងការជណ្តើមកាន់កាប់ដីធ្លីផងដែរ ទោះបីជាក្រសួងបរិស្ថានកំពុងខិតខំប្រឹងប្រែងធ្វើកំណែទម្រង់នៅក្នុងវិស័យនេះផងដែរ។ បញ្ហាប្រឈមសមត្ថភាពចម្បងគឺពាក់ព័ន្ធនឹង*ប្រសិទ្ធភាពសង្គមស៊ីវិល & ប្រព័ន្ធផ្សព្វផ្សាយ* ដែលឆ្លុះបញ្ចាំងអំពីការកាត់បន្ថយលំហនៅក្នុងវិស័យទាំងនេះ។ ចំណុច

[1] “យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី IV” រាជរដ្ឋាភិបាលកម្ពុជា ខែកញ្ញា ឆ្នាំ ២០១៨។

[2] “ដំណើរឆ្ពោះទៅការពឹងផ្អែកលើខ្លួនឯងរបស់ប្រទេសកម្ពុជា៖ ផែនទីបង្ហាញផ្លូវប្រទេសសម្រាប់ឆ្នាំ2021” USAID ឆ្នាំ ២០២០។

ខ្លាំងទាំងពីរផ្នែកសម្រាប់ប្រទេសកម្ពុជាពាក់ព័ន្ធនឹងការប្តេជ្ញាចិត្តគឺ *សុវត្ថិភាព & សន្តិសុខ* និង*ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍* ដោយចំណុចទីពីរគឺជាឱកាសដែលទីភ្នាក់ងារជំនួយអាមេរិក USAID កំពុងព្យាយាមសម្រេចឱ្យបាន ជាការផ្លាស់ប្តូរនៅក្នុងយុទ្ធសាស្ត្រ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដើម្បីជួយដោះស្រាយចន្លោះខ្វះខាតដ៏ធំបំផុតនៅក្នុងការប្តេជ្ញាចិត្ត និងសមត្ថភាព ខណៈធ្វើការលើកកម្ពស់ចំណុចខ្លាំងរបស់ប្រទេសកម្ពុជា។

**ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពយ៉ាងខ្លាំងនៅក្នុងផ្នែកអភិវឌ្ឍន៍មួយចំនួន ប៉ុន្តែនៅតែជួបប្រទះនូវឧបសគ្គពាក់ព័ន្ធជាមួយនឹងភាពធន់នឹងវិបត្តិ និងការពឹងផ្អែកលើខ្លួនឯងដដែល។** ក្រៅពីការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចនៅឆ្នាំ២០២០ ដែលបណ្តាលមកពីការរីករាលដាលជំងឺជាសកលនេះ ប្រទេសកម្ពុជាបានសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាច្រើនក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ (អត្រាកំណើនប្រចាំឆ្នាំជាមធ្យមប្រាំពីរភាគរយ) ក្រៅពីវឌ្ឍនភាពដ៏ខ្ពស់ទាំងនៅក្នុងផ្នែកសុខាភិបាល និងអប់រំ។ ទោះបីជាយ៉ាងណា ផលប្រយោជន៍ទាំងនេះមិនទាន់មានសមភាពនៅឡើយទេ ដោយស្ត្រី យុវជន ព្រមទាំងក្រុមដែលមិនត្រូវបានយកចិត្តទុកដាក់ និងងាយរងគ្រោះជាច្រើន កំពុងប្រឈមនឹងការទុកចោលដោយគ្មានការគិតគូរ។ នៅពេលកើតមានករណីជំងឺឆ្លងកូវីដ-១៩ជាសកលឆ្នាំ២០១៩ ផលប្រយោជន៍ដែលសម្រេចបានរហូតមកដល់ពេលនេះមានភាពងាយរងគ្រោះដោយសារវិបត្តិទាំងក្នុងប្រទេស និងក្រៅប្រទេស។ ជាងនេះទៅទៀត ឱកាសសម្រាប់ការពិភាក្សារបស់ពលរដ្ឋ និងកិច្ចការពារសិទ្ធិមនុស្សដែលត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា អាចធ្វើឱ្យកាន់តែប្រសើរឡើងបាន។ គណនេយ្យភាព និងតម្លាភាពរដ្ឋាភិបាលបង្កឱ្យមានបញ្ហាប្រឈមលើការអភិវឌ្ឍយ៉ាងខ្លាំង ដោយប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់១៦២ នៅក្នុងចំណោម ១៨០ ប្រទេសនៅក្នុងសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ (The Corruption Perceptions Index) ឆ្នាំ ២០១៩។[3] ការគំរាមកំហែងផ្នែកបរិស្ថាន ដែលរួមមានផលប៉ះពាល់នៃការប្រែប្រួលបរិស្ថាន និងអត្រាដ៏ខ្ពស់នៃការកាប់បំផ្លាញព្រៃឈើ គំរាមកំហែងដល់ធនធានធម្មជាតិដ៏សំបូរបែប និងចីរភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ USAID មានលទ្ធភាពខ្ពស់ក្នុងការជួយប្រទេសកម្ពុជាដើម្បីជម្នះនឹងបញ្ហាប្រឈមទាំងនេះ ព្រមទាំងពង្រឹងនូវការពឹងផ្អែកលើខ្លួនឯង និងរួមចំណែកដល់គោលបំណងគោលនយោបាយការបរទេសរបស់រដ្ឋាភិបាលអាមេរិក នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

## វិធីសាស្ត្រដែលមានលក្ខណៈអន្តរវិស័យ៖

- **ការកំណត់ទំនាក់ទំនងឡើងវិញ៖** USAID នឹងជួយពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីផ្តល់សេវាប្រកបដោយគុណភាព និងការពារធនធានដើម្បីបង្កើនភាពជាម្ចាស់ ព្រមទាំងតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាលចំពោះប្រជាជនកម្ពុជា។ ឧទាហរណ៍ នៅក្នុងផ្នែកសុខាភិបាល USAID នឹងផ្លាស់ប្តូរពីការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យសុខាភិបាល និងការផ្តល់សេវា ទៅជាការពង្រឹងប្រព័ន្ធទាំងមូល។ USAID នឹងរៀបចំឱ្យមានការចូលរួមពីសង្គមស៊ីវិលដើម្បី

[3] "ទិន្នន័យប្រទេសកម្ពុជា" អង្គការតម្លាភាពអន្តរជាតិ ឆ្នាំ ២០១៩

ពង្រឹងការតស៊ូមតិ និងកិច្ចការពារសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀត ព្រមទាំងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ការកាប់ព្រៃឈើខុសច្បាប់ និងការរុករានតំបន់អភិរក្សដែលបានកំណត់។ USAID នឹងរៀបចំឱ្យមានការចូលរួមពីរាជរដ្ឋាភិបាលកម្ពុជាទៅក្នុងកំណែទម្រង់សំខាន់ៗ ប្រសិនបើមានតម្រូវការ មានការចាប់អារម្មណ៍ និងការប្តេជ្ញាចិត្ត។

- **ទំនាក់ទំនងជាមួយវិស័យឯកជន៖** ទំនាក់ទំនងជាមួយវិស័យឯកជនត្រូវបានដាក់បញ្ចូលទៅក្នុងគោលបំណងអភិវឌ្ឍន៍ទាំងបី ព្រមទាំងនឹងផ្តោតទៅលើកិច្ចសហការជាមួយតួអង្គវិស័យឯកជនដែលមានចំណាប់អារម្មណ៍ និងគុណតម្លៃស្របជាមួយរដ្ឋាភិបាលអាមេរិក ដើម្បីជំរុញការវិនិយោគទៅក្នុងប្រព័ន្ធ និងទីផ្សារមូលដ្ឋាន ដើម្បីធានាឱ្យមានស្វ័យចីរភាព។

- **តម្លាភាព និងគណនេយ្យភាព៖** ការកសាងសម្ព័ន្ធភាពរបស់ភាគីពាក់ព័ន្ធនៅក្នុងវិស័យនានា ដែលរួមមាន អង្គភាពដឹកនាំដោយស្ត្រី និងយុវជន សហជីពការងារ អង្គការសិទ្ធិដីធ្លី និងតួអង្គផ្សេងៗទៀត មានសារៈសំខាន់ក្នុងការសម្រេចបាននូវកំណែទម្រង់ដែលមានគោលដៅជំរុញតម្លាភាព និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។ USAID នឹងធ្វើការអភិវឌ្ឍសមត្ថភាពរបស់អង្គការ និងភាគីពាក់ព័ន្ធកម្ពុជាដើម្បីបញ្ចេញមតិយោបល់ និងធ្វើសកម្មភាពតាងនាមពលរដ្ឋកម្ពុជា។

- **ការអភិវឌ្ឍលក្ខណៈបរិយាបន្ន៖** USAID ស្វែងរកប្រជាជនកម្ពុជាជាច្រើនទៀតដើម្បីចូលរួមចំណែកអភិវឌ្ឍ និងទទួលប្រយោជន៍ពីការងើបឡើងវិញនៃសេដ្ឋកិច្ច និងវឌ្ឍនភាពសេដ្ឋកិច្ចនាពេលអនាគតរបស់ប្រទេស ដោយប្រើប្រាស់នូវសេរីភាពដែលធានាដោយរដ្ឋធម្មនុញ្ញ។ USAID នឹងខិតខំកាត់បន្ថយឧបសគ្គនានាចំពោះស្ត្រី និងយុវជននៅក្នុងការចូលរួម និងដឹកនាំនៅក្នុងលំហនយោបាយ និងលំហពលរដ្ឋ វិស័យសេដ្ឋកិច្ច ការអភិរក្សជីវចម្រុះ និងធនធានធម្មជាតិ ព្រមទាំងការអប់រំ និងសេវាសុខាភិបាល។ USAID ក៏នឹងគាំទ្រផងដែរដល់វិធីសាស្ត្រដែលមានភាពច្នៃប្រឌិត និងអន្តរវិស័យដើម្បីដោះស្រាយបញ្ហាទូទៅនៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ យុទ្ធសាស្ត្រក៏នឹងរក្សាការផ្តោតការយកចិត្តទុកដាក់ទៅលើសិទ្ធិ និងការចូលរួមរបស់ប្រជាជនដែលមិនត្រូវបានយកចិត្តទុកដាក់ ដែលរួមមាន ប្រជាជនដើមភាគតិច ក្រុមសាសនានិងជនជាតិភាគតិច ជនមានពិការភាព និងសមាជិកសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ។

## គោលបំណងអភិវឌ្ឍន៍ទី ១៖ ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព

គោលបំណងអភិវឌ្ឍន៍ទី ១ ភ្ជាប់ទៅនឹងគោលដៅយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេសតាមរយៈការគាំទ្រស្ថានភាពសេដ្ឋកិច្ចដែលមានភាពចាំបាច់ក្នុងការលើកកម្ពស់វិបុលភាព និងភាពធន់នឹងវិបត្តិនៅក្នុងប្រទេស តាមរយៈការផ្តោតទៅលើបញ្ហាអភិបាលកិច្ចល្អពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ។ គោលបំណងអភិវឌ្ឍន៍ទី ១ មានគោលដៅ ១) ពន្លឿនពិពិធកម្មសេដ្ឋកិច្ចតាមរយៈការលើកកម្ពស់ឱកាសកែលម្អ

ជីវភាព ដោយយកចិត្តទុកដាក់ទៅលើការធ្វើការងារជាមួយក្រុមហ៊ុនអាជីវកម្ម និងសហគមន៍ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច និងផ្តោតទៅលើវិធីសាស្រ្តផ្អែកលើទីផ្សារនៅក្នុងវិស័យកសិកម្ម ២) ការអភិវឌ្ឍសមត្ថភាពរបស់ពលរដ្ឋកម្ពុជា ជាពិសេសយុវជន និងស្ត្រី ដើម្បីទទួលបានការងារប្រាក់ចំណូលខ្ពស់ជាងមុន និងការកំណត់គោលដៅវិនិយោគផ្នែកវិទ្យាសាស្រ្ត និងបច្ចេកវិទ្យាដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ៣) កែលម្អបរិយាកាសធុរកិច្ចដើម្បីទាក់ទាញការងារ និងការវិនិយោគតាមរយៈការលើកកម្ពស់អភិបាលកិច្ចសេដ្ឋកិច្ច និងបរិយាកាសអំណោយផលដល់ធុរកិច្ច និង ៤) កែលម្អការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិ រួមទាំងការយកចិត្តទុកដាក់ទៅលើទេសភាពដែលរងការគំរាមកំហែងខ្ពស់ និងការគាំទ្រចំពោះការគ្រប់គ្រងអាងរងទឹកភ្លៀង ដើម្បីបង្កើតគ្រឹះកាន់តែរឹងមាំសម្រាប់កំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព។

## គោលបំណងអភិវឌ្ឍន៍ទី ២ ៖ កែលម្អសុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា

គោលបំណងអភិវឌ្ឍន៍ទី ២ (DO2) ផ្សារភ្ជាប់ទៅនឹងគោលដៅយុទ្ធសាស្រ្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេសតាមរយៈការគាំទ្រលទ្ធផលនៃការអភិវឌ្ឍសង្គម និងធនធានមនុស្សដែលចាំបាច់សម្រាប់ការបង្កើនវិបុលភាព និងភាពធន់នឹងវិបត្តិក្នុងប្រទេសកម្ពុជា។ ខណៈពេលកំពុងបន្តការផ្លាស់ប្តូរពីការផ្តល់សេវាដោយផ្ទាល់ទៅជាការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធសុខាភិបាលដែលផ្ទុយពីយុទ្ធសាស្រ្តមុន គោលបំណងអភិវឌ្ឍន៍ទី ២ នឹងបង្កើនការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើបញ្ហាដែលមានលក្ខណៈអន្តរវិស័យ ដូចជាការធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ច និងគណនេយ្យភាពនៃប្រព័ន្ធសុខាភិបាល អប់រំ និងការពារកុមាររបស់ប្រទេសកម្ពុជា។ DO2 មានគោលដៅ៖ ១) ធ្វើអោយប្រសើរឡើងគុណភាព និងការប្រើប្រាស់សេវាសុខាភិបាលជាអាទិភាព ដែលរួមមានសុខភាពមាតានិងកុមារ កម្មវិធីជំងឺឆ្លង និងសេវាផ្តល់ដោយវិស័យឯកជន ២) ពង្រឹងអភិបាលកិច្ច និងគណនេយ្យភាពនៃប្រព័ន្ធសុខាភិបាល អប់រំ និងការពារកុមារ ដោយផ្តោតទៅលើការប្រើប្រាស់ភស្តុតាងដើម្បីកំណត់អាទិភាពធនធានក្នុងស្រុកនៅកម្រិតរដ្ឋបាលថ្នាក់ខេត្ត និងថ្នាក់ស្រុក និង ៣) លើកកម្ពស់គុណភាពសេវាអប់រំ និងការពារកុមារតាមរយៈការពង្រឹងសមត្ថភាពប្រព័ន្ធផ្តល់សេវារដ្ឋាភិបាល ព្រមទាំងធ្វើការកសាងសមត្ថភាព និងជំនាញរបស់បុគ្គលិកជំនាញផ្នែកអប់រំ និងអ្នកផ្តល់សេវាសង្គមដើម្បីឱ្យកុមារ ជាពិសេសជនមានពិការភាព និងជនងាយរងគ្រោះបំផុតមានលទ្ធភាពកាន់តែខ្ពស់ក្នុងការទទួលបានសេវាប្រកបដោយគុណភាព។

## គោលបំណងអភិវឌ្ឍន៍ទី ៣ ៖ ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល

គោលបំណងអភិវឌ្ឍន៍ទី ៣ មានជាប់ពាក់ព័ន្ធនឹងគោលដៅយុទ្ធសាស្រ្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេសតាមរយៈការគាំទ្រលទ្ធផលចូលរួមរបស់ពលរដ្ឋដែលចាំបាច់សម្រាប់ការបង្កើនវិបុលភាព និងភាពធន់នឹងវិបត្តិក្នុងប្រទេសកម្ពុជា និងសម្រាប់អភិបាលកិច្ចដែលមានភាពរឹងមាំ និងកាន់តែមានភាពបើកចំហតាមរយៈគណនេយ្យភាពសង្គម។ ផ្ទុយពីយុទ្ធសាស្រ្តមុន វិធីសាស្រ្តបច្ចុប្បន្នផ្តោតទៅលើការទប់ស្កាត់ការធ្លាក់ចុះនៃកិច្ចពិភាក្សារបស់ពលរដ្ឋ និងការបង្កើតឱកាសចូលរួម។ យុទ្ធសាស្រ្តនេះមានគោលដៅបង្កើនការ

ចូលរួម និងសកម្មភាពរបស់ពលរដ្ឋក្នុងការកសាងការគាំទ្រសាធារណៈទូលំទូលាយសម្រាប់អភិបាលកិច្ច ដែលកាន់តែមានលក្ខណៈឆ្លើយតប ខណៈគាំទ្រដល់ការការពារសិទ្ធិផងដែរ។ គោលបំណងអភិវឌ្ឍន៍នេះ មានគោលដៅ៖ ១) ផ្តល់អំណាចដល់អ្នកការពារសិទ្ធិ និងអង្គការនានាតាមរយៈការលើកទឹកចិត្តផ្នែក សេដ្ឋកិច្ចដើម្បីទាមទារសិទ្ធិ (ដូចជា សហជីពការងារ ក្រុមសហគមន៍ដែលពាក់ព័ន្ធនៅក្នុងទំនាស់ដីធ្លី។ល។ ២) គាំទ្រការតស៊ូមតិឱ្យមានកំណែទម្រង់ ដែលរួមមាន អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងស្ត្រី យុវជន និង ក្រុមដែលមិនត្រូវបានយកចិត្តទុកដាក់ និង ៣) ពង្រឹងគណនេយ្យភាពសង្គមតាមរយៈការពង្រីកលទ្ធភាព របស់ពលរដ្ឋកម្ពុជាក្នុងការទទួលបានព័ត៌មានសុក្រឹត និងឯករាជ្យ និងតាមរយៈការផ្តល់លទ្ធភាពឱ្យពលរដ្ឋធ្វើ ការតាមដានទៅលើសេវាសាធារណៈ។

## ការពិចារណាលើគោលនយោបាយកម្រិតខ្ពស់

គោលបំណងអភិវឌ្ឍន៍នីមួយៗ មានលក្ខណៈស្របជាយុទ្ធសាស្ត្រជាមួយនឹងគោលនយោបាយការបរទេស កម្រិតខ្ពស់ផ្សេងៗរបស់រដ្ឋាភិបាលអាមេរិក ដែលរួមមាន យុទ្ធសាស្ត្រសន្តិសុខជាតិ[4] ផែនការយុទ្ធសាស្ត្ររួម រវាង USAID និងក្រសួងការបរទេសអាមេរិក (JSP)[5] និងចំណុចអាទិភាពសំខាន់ៗសម្រាប់តំបន់ឥណ្ឌូ ប៉ាស៊ីហ្វិក។ ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រសន្តិសុខជាតិ CDCS គាំទ្រដល់សសរស្តម្ភទី II "លើកកម្ពស់វិបុលភាព អាមេរិក" និងសសរស្តម្ភទី IV "បង្កើនឥទ្ធិពលអាមេរិក"។ ពាក់ព័ន្ធនឹង JSP, CDCS គាំទ្រដល់គោលដៅទី ២ "បន្តបង្កើនឧត្តមភាពប្រកួតប្រជែងរបស់សហរដ្ឋអាមេរិកដើម្បីធានាចីរភាពដល់កំណើនសេដ្ឋកិច្ច និងការ បង្កើតការងារ" គោលដៅទី ៣ "លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់អាមេរិកតាមរយៈការរក្សាតុល្យភាពនៃការ ចូលរួម" និងគោលដៅទី ៤ "ធានាប្រសិទ្ធភាព និងគណនេយ្យភាពចំពោះអ្នកជាប់ពន្ធអាមេរិក"។ យុទ្ធសាស្ត្រ នេះក៏គាំទ្រដល់អភិបាលកិច្ច សេដ្ឋកិច្ច និងសន្តិសុខដែលស្របជាមួយអាទិភាពសម្រាប់តំបន់ឥណ្ឌូប៉ាស៊ីហ្វិក ផងដែរ។

កិច្ចការងារនៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ១ នឹងជំរុញការអភិវឌ្ឍលក្ខណៈបរិយាបន្ន និងប្រកបដោយ ចីរភាព បើកចំហរទីផ្សារថ្មី និងជំរុញឱ្យមានកំណែទម្រង់សេដ្ឋកិច្ចផ្តោតលើទីផ្សារ។ នៅក្រោមគោលបំណង អភិវឌ្ឍន៍ទី ២ ការវិនិយោគនឹងលើកកម្ពស់ចំនួនប្រជាជនដែលប្រកបដោយសុខភាព ការអប់រំ និងផលិតភាព បន្ថែមពីលើការទប់ស្កាត់ការរីករាលដាលជំងឺឆ្លង។ នៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ៣ យុទ្ធសាស្ត្រនឹង គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការប្រឆាំងអំពើពុករលួយ ព្រមទាំងលើកកម្ពស់តម្លាភាព និងគណនេយ្យ ភាពដើម្បីជួយធានាប្រសិទ្ធភាព និងចីរភាពនៃការវិនិយោគលើការអភិវឌ្ឍន៍។ តាមរយៈទំនាក់ទំនងជាមួយ វិស័យឯកជន នៅក្រោមគោលបំណងអភិវឌ្ឍន៍ទាំងបី ទីភ្នាក់ងារជំនួយអាមេរិក USAID នឹងលើកកម្ពស់ដល់ ការប្រកួតប្រជែងទីផ្សារសេរី គាំទ្រដល់បច្ចេកវិទ្យា និងគំនិតច្នៃប្រឌិត ព្រមទាំងលើកទឹកចិត្តដល់កំណើន វិស័យឯកជន និងដំណោះស្រាយផ្អែកលើទីផ្សារ។ USAID នឹងផ្តោតទៅលើការវិនិយោគលើការអភិវឌ្ឍ ដើម្បីលើកទឹកចិត្តឱ្យមានជម្រើសផ្សេងៗដែលធ្វើឱ្យកាន់តែប្រសើរឡើងនូវអភិបាលកិច្ច នីតិរដ្ឋ និងការ

[4] "យុទ្ធសាស្ត្រសន្តិសុខជាតិរបស់សហរដ្ឋអាមេរិក" សេតវិមាន ឆ្នាំ ២០១៧

[5] "ផែនការយុទ្ធសាស្ត្ររួមឆ្នាំ ២០១៨ - ២០២២" ក្រសួងការបរទេសអាមេរិក និងទីភ្នាក់ងារជំនួយអាមេរិក USAID ខែកុម្ភៈ ឆ្នាំ ២០១៨

អភិវឌ្ឍប្រកបដោយចីរភាព លើកកម្ពស់គោលការណ៍ស្នូលរបស់អាមេរិកស្តីពីឯករាជ្យភាព និងការគោរពសេរីភាពបុគ្គលជាមូលដ្ឋាន និងគាំទ្រដល់ការគៀរគរទាំងធនធានសាធារណៈ និងឯកជនដើម្បីបង្កើនលទ្ធផលនៃការអភិវឌ្ឍ និងជំរុញវិបុលភាព និងការពឹងផ្អែកលើខ្លួនឯង។ ដោយសារពុំសូវមានការប្តេជ្ញាចិត្តចំពោះការចូលរួមលក្ខណៈពហុភាគីនៅក្នុងស្ថាប័នអភិបាលកិច្ច យុទ្ធសាស្ត្រនឹងបញ្ឈប់ការគាំទ្រដល់ការបោះឆ្នោតដោយផ្ទាល់ ដែលរួមមានការពង្រឹងគណបក្សនយោបាយ លើកលែងតែមានការបើកចំហឱ្យមានការបំពេញការងារក្នុងន័យស្ថាបនាជាមួយអាជ្ញាធររដ្ឋាភិបាលដើម្បីធ្វើឱ្យមានភាពល្អប្រសើរខ្លាំងនៅក្នុងផ្នែកនេះ។ ពាក់ព័ន្ធនឹងការជួញដូរមនុស្ស (TIP) ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី ២ ក្នុងបញ្ជីឃ្លាំមើល (Tier 2 Watch List) នៃរបាយការណ៍ស្តីពីការជួញដូរមនុស្សរបស់ក្រសួងការបរទេសអាមេរិក ដែលធ្វើឱ្យប្រទេសកម្ពុជាជាប់ឈ្មោះនៅក្នុងបញ្ជីនេះរយៈពេលពីរឆ្នាំជាប់ៗគ្នា។ ជាការឆ្លើយតប ស្ថានទូតអាមេរិកបានបង្កើនកិច្ចខិតខំប្រឹងប្រែងបេសកកម្មទាំងមូលដើម្បីជំរុញអាជ្ញាធរកម្ពុជាឱ្យអនុវត្តអនុសាសន៍នៅក្នុងរបាយការណ៍។

ប្រទេសកម្ពុជាក៏ត្រូវបានកំណត់ថា ជាប្រទេសគួរឱ្យព្រួយបារម្ភនៅក្នុងរបាយការណ៍ប្រចាំឆ្នាំទីបួន របស់ក្រសួងការបរទេសអាមេរិក នៅក្រោមច្បាប់ស្តីពីការលុបបំបាត់ ទប់ស្កាត់ និងរារាំងការជួញដូរសត្វព្រៃ (Eliminate, Neutralize, and Disrupt Wildlife Trafficking Act) ឆ្នាំ ២០១៦។ ជាការឆ្លើយតប សកម្មភាពរបស់ USAID ទាំងអស់ ដោយមានសមាសភាគប្រយុទ្ធប្រឆាំងការជួញដូរសត្វព្រៃនឹងសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាលអាមេរិកផ្សេងទៀត និងអង្គភាពអនុវត្តច្បាប់ស្របទៅតាម "យុទ្ធសាស្ត្រប្រឆាំងការជួញដូរសត្វព្រៃក្នុងប្រទេសកម្ពុជា" (២០១៨)។

ពាក់ព័ន្ធនឹងសេរីភាពសាសនា ប្រទេសកម្ពុជាពុំត្រូវបានណែនាំថាជាប្រទេសដែលមានការព្រួយបារម្ភខ្លាំង និងពុំស្ថិតនៅលើបញ្ជីឃ្លាំមើលរបស់ក្រសួងការបរទេសសម្រាប់របាយការណ៍សេរីភាពសាសនាអន្តរជាតិប្រចាំឆ្នាំរបស់គណៈកម្មការសហរដ្ឋអាមេរិក។[6] មានកិច្ចគាំពារផ្លូវច្បាប់មួយចំនួនសម្រាប់សេរីភាពខាងសាសនា និងជនជាតិដើមភាគតិចនៅក្នុងប្រទេស។[7]

រូបភាពទី ១ សង្ខេបគោលដៅកម្រិតខ្ពស់ គោលបំណងអភិវឌ្ឍ និងលទ្ធផលរំពឹងទុកនៃមធ្យោបាយយុទ្ធសាស្ត្រថ្មី

[6] "របាយការណ៍ប្រចាំឆ្នាំរបស់គណកម្មការសេរីភាពសាសនាអន្តរជាតិ" USCIRF ខែមេសា ឆ្នាំ ២០២០
[7] រដ្ឋធម្មនុញ្ញកម្ពុជាផ្តល់សេរីភាពជំនឿសាសនា ដរាបណាសេរីភាពទាំងនេះមិនរំខានដល់ជំនឿសាសនារបស់អ្នកដទៃ ឬរំលោភទៅលើបទបញ្ញា និងសន្តិសុខសាធារណៈ

## រូបភាពទី ១៖ ក្របខណ្ឌលទ្ធផល CDCS

| គោលបំណង៖ ប្រទេសកម្ពុជា ក្លាយជាដៃគូកាន់តែបើកចំហ មានវិបុលភាព ភាពធន់ និងបរិយាបន្ន នៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក | | |
|---|---|---|
| គោលបំណងអភិវឌ្ឍន៍ទី ១៖ ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព | គោលបំណងអភិវឌ្ឍន៍ទី ២៖ កែលម្អសុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា | គោលបំណងអភិវឌ្ឍន៍ទី ៣៖ ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល |
| IR ១.១៖ ពន្លឿនពិពិធកម្មសេដ្ឋកិច្ចដើម្បីលើកកម្ពស់ជីវភាព | IR ២.១៖ កែលម្អគុណភាព និងការប្រើប្រាស់សេវាសុខាភិបាលអាទិភាព | IR ៣.១៖ ពង្រឹងកិច្ចការពារសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀត |
| IR ១.២៖ កែលម្អបរិយាកាសធុរកិច្ចដើម្បីទាក់ទាញការវិនិយោគ និងបង្កើតការងារ | IR ២.២៖ ពង្រឹងអភិបាលកិច្ច និងគណនេយ្យភាពនៃប្រព័ន្ធសុខាភិបាល អប់រំ និងគាំពារកុមាររបស់ប្រទេសកម្ពុជា | IR ៣.២៖ បង្កើនការចូលរួម និងសកម្មភាពរបស់ពលរដ្ឋក្នុងកំណែទម្រង់ |
| IR ១.៣៖ កែលម្អការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងគណនេយ្យភាព | IR ២.៣៖ កែលម្អគុណភាពសេវាអប់រំ និងគាំពារកុមារ | IR ៣.៣៖ ពង្រឹងការត្រួតពិនិត្យសាធារណៈទៅលើស្ថាប័នរដ្ឋាភិបាល |

## បរិបទប្រទេស

នៅក្នុងឆ្នាំ ២០២០ សហរដ្ឋអាមេរិក និងប្រទេសកម្ពុជាបានអបអរខួប ៧០ ឆ្នាំនៃការភ្ជាប់ទំនាក់ទំនងការទូត។ កម្មវិធី USAID មានឫសគល់ជាជំនួយមនុស្សធម៌ និងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ (ស្ពានថ្មល់) នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និងបានឈានទៅយកចិត្តទុកដាក់ទៅលើដំណើរឆ្ពោះទៅការពឹងផ្អែកលើខ្លួនឯងរបស់ប្រទេសកម្ពុជា។ សហរដ្ឋអាមេរិកបានជួយនៅក្នុងការចរចា និងជាហត្ថលេខីនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ ១៩៩១ សម្រាប់ប្រទេសកម្ពុជា[8] ដែលត្រូវបានរៀបចំឡើងដើម្បីធានាអធិបតេយ្យភាព ឯករាជ្យភាព និងអព្យាក្រឹតភាពនៃប្រទេសកម្ពុជា។ កិច្ចព្រមព្រៀងបានបង្កើតក្របខណ្ឌសម្រាប់រដ្ឋធម្មនុញ្ញកម្ពុជាដើម្បីផ្តល់ការការពារសិទ្ធិជាមូលដ្ឋាន និងប្រជាធិបតេយ្យសេរីដោយប្រកាន់ខ្ជាប់នូវគោលការណ៍ពហុបក្ស។[9] USAID បានបើកដំណើរការសាជាថ្មីក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩៩២។ ចាប់តាំងពីពេលនោះមក សហរដ្ឋអាមេរិកបានផ្តល់ទឹកប្រាក់ចំនួន ១,៥ ពាន់លានដុល្លារ ជាជំនួយអភិវឌ្ឍន៍ដើម្បីគាំទ្រដល់ពលរដ្ឋកម្ពុជាក្នុងការទទួលបានជីវិតរស់នៅកាន់តែមានសុខភាព មានវិបុលភាព និងធន់នឹងវិបត្តិ។

---

[8] Taing Rinith, "ស្ថានទូតក្នុងប្រទេសកម្ពុជាអះអាងជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការគោរពកិច្ចព្រមព្រៀងទីក្រុងប៉ារីស" *ខ្មែរថាមស៍* ថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០២០

[9] "កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់ទំនាស់ក្នុងប្រទេសកម្ពុជា" អង្គការសហប្រជាជាតិ ក្រសួងព័ត៌មានសាធារណៈ ខែមករា ឆ្នាំ១៩៩២ ទទួលបានពីវិទ្យាស្ថានសន្តិភាពសហរដ្ឋអាមេរិក៖ សមូហកម្មឌីជីថលកិច្ចព្រមព្រៀងសន្តិភាព។

## កត្តាគួរឱ្យកត់សម្គាល់នៅក្នុងបរិបទកម្ពុជា

**ប្រទេសកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅការពឹងផ្អែកលើខ្លួនឯង។ ប្រទេសកម្ពុជាបានសម្រេចនូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាច្រើនទសវត្សរ៍ចុងក្រោយនេះ ដែលរងការគំរាមកំហែងពីវិសមភាពសេដ្ឋកិច្ចកម្រិតខ្ពស់ ពិពិធកម្មសេដ្ឋកិច្ចកម្រិតទាប និងកំណើនការអភិវឌ្ឍសេដ្ឋកិច្ចដែលគ្មានចីរភាព។** USAID អាចដើរតួនាទីសំខាន់នៅក្នុងភាពជាដៃគូគោលដៅជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជួយធានាថា កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះកាន់តែមានចីរភាព និងអភិវឌ្ឍប្រទេសឱ្យមានភាពបើកចំហ និងវិបុលភាពដែលមានសក្តានុពលក្នុងការដើរតួជាសម្ព័ន្ធមិត្ត និងដៃគូតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដ៏សំខាន់។ ក្នុងទិដ្ឋភាពមួយចំនួន ប្រទេសកម្ពុជាសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ក្នុងដំណើរឆ្ពោះទៅរកការពឹងផ្អែកលើខ្លួនឯង។ ក្នុងនាមជាប្រទេសមួយដែលសេដ្ឋកិច្ចមានការរីកចម្រើនបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់លើសពីប្រាំពីរភាគរយក្នុងមួយឆ្នាំ[10] [11] [12] ដោយប្រទេសនេះបានផ្លាស់ប្តូរពីប្រទេសមានប្រាក់ចំណូលទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ ២០១៥ និងមានគោលដៅប្រែក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមនៅត្រឹមឆ្នាំ ២០៣០។ ទោះបីជាទទួលបានលទ្ធផលបែបនេះក៏ដោយ សេដ្ឋកិច្ចនៅតែមិនទាន់បានធ្វើពិពិធកម្មគ្រប់គ្រាន់ និងពឹងផ្អែកទៅលើវិស័យមួយចំនួន (ដូចជា កសិកម្ម ទេសចរណ៍ និងកាត់ដេរ)។ ភាពក្រីក្រពហុវិស័យក្នុងប្រទេសកម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន ៣៧,២ ភាគរយ[13] ហើយប្រជាជនកម្ពុជាប្រមាណបួនលាននាក់ កំពុងរស់នៅដោយមានប្រាក់ចំណូលតិចជាង $១,២៥ ក្នុងមួយថ្ងៃ។[14] ជាងនេះទៅទៀត នៅពេលកើតមានជំងឺរាតត្បាតជាសកលកូរ៉ូណាឆ្នាំ ២០១៩ (កូវីដ-19) កំណើនសេដ្ឋកិច្ចជាច្រើនដែលសម្រេចបានក្នុងពេលថ្មីៗមានភាពផុយស្រួយ និងប្រឈមនឹងការធ្លាក់ទៅក្នុងស្ថានភាពមិនល្អដូចកាលពីមុន។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករណ៍ថា ប្រទេសកម្ពុជានឹងមានការធ្លាក់ចុះ ៤,0 ភាគរយនូវផលិតផលក្នុងស្រុកសរុបរបស់ខ្លួននៅក្នុងឆ្នាំ ២០២០។ ទោះជាយ៉ាងនេះក្តី ធនាគារនេះបានព្យាករណ៍ថា សេដ្ឋកិច្ចនឹងមានការកើនឡើងឡើងវិញនៅក្នុងឆ្នាំ ២០២១។[15] លើសពីនេះ ផលប៉ះពាល់ពីការប្រែប្រួល និងផ្លាស់ប្តូរអាកាសធាតុនឹងបន្តគំរាមកំហែងដល់ភាពជោគជ័យទាំងនេះ។[16] គ្រាន់តែនៅក្នុងឆ្នាំ ២០១៥ មួយឆ្នាំនេះ ផលប៉ះពាល់ដោយសារអាកាសធាតុបណ្តាលឱ្យខាតបង់ទឹកប្រាក់ប្រមាណ ១,៥ ពាន់លានដុល្លារ ស្មើនឹងដប់ភាគរយនៃផលិតផលក្នុងស្រុកប្រចាំឆ្នាំសរុប (GDP)។[17]

ទោះបីយ៉ាងណា នៅមានឱកាសសម្រាប់ប្រទេសកម្ពុជាក្នុងការចាប់ផ្តើមដំណើរប្រកបដោយចីរភាព និងលក្ខណៈបរិយាបន្នឆ្ពោះទៅកំណើនសេដ្ឋកិច្ច។ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលគោលដៅ និងទំនាក់ទំនងជាមួយវិស័យឯកជន ការបង្កើតការងារនៅក្នុងវិស័យក្នុងប្រព័ន្ធអាចធ្វើឱ្យកាន់តែប្រសើរឡើងនូវភាពធន់នឹងវិបត្តិ

[10] "កំណើនផលិតផលក្នុងស្រុកសរុប (គិតជា % ប្រចាំឆ្នាំ) ប្រទេសកម្ពុជា" ទិន្នន័យរបស់ធនាគារពិភពលោក ឆ្នាំ ២០១៨ ចូលថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ2020

[11] "របាយការណ៍ពិគ្រោះយោបល់ប្រចាំឆ្នាំ AMRO៖ ប្រទេសកម្ពុជា ឆ្នាំ ២០១៧" ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+3 ឆ្នាំ ២០១៧, ៧

[12] "បុគ្គលិក IMF បំពេញបេសកកម្មឆ្នាំ2019 ទៅកាន់ប្រទេសកម្ពុជា" សេចក្តីប្រកាសព័ត៌មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) លេខ ១៩/៣៧0 ទី១១ ខែតុលា ឆ្នាំ២០១៩, ៣៦

[13] "របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ2019៖ កម្ពុជា" UNDP, ២០១៩

[14] "ការពិនិត្យពាក់កណ្តាលវគ្គ យុទ្ធសាស្ត្រសហប្រតិបត្តិការអភិវឌ្ឍប្រទេសកម្ពុជាឆ្នាំ ២០១៤-២០១៨" USAID, ឆ្នាំ ២០១៦

[15] "ទស្សនវិស័យធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ 2020៖ សុខុមាលភាពក្នុងពេលគួរឱ្យព្រួយបារម្ភ" ខែកញ្ញា ឆ្នាំ ២0២0

[16] "ការវិភាគលើការគ្រប់គ្រងហានិភ័យអាកាសធាតុ USAID/កម្ពុជា" USAID, ២0២0

[17] "កម្រងទិន្នន័យហានិភ័យអាកាសធាតុកម្ពុជា" USAID, ២០១៩

នៃសេដ្ឋកិច្ចកម្ពុជា ជាពិសេសសម្រាប់កម្លាំងពលកម្មវ័យក្មេង និងប្រកបដោយថាមពលរបស់ប្រទេស។ ការណ៍ដែលជំងឺរាតត្បាតបានធ្វើឱ្យធ្លាក់ចុះនូវពាណិជ្ជកម្មឆ្លងកាត់ព្រំដែនគឺជាឱកាសដែលផលិតករ និងអ្នកកែច្នៃក្នុងស្រុកអាចបង្កើននូវបទដ្ឋានរបស់ខ្លួន ដែលនឹងលើកកម្ពស់ភាពប្រកួតប្រជែង ព្រមទាំងលទ្ធភាពចូលទៅក្នុងទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ (នៅពេលមានភាពល្អប្រសើរឡើងវិញ)។

**ប្រទេសកម្ពុជាអាចធ្វើឱ្យប្រសើរឡើងនូវវឌ្ឍនភាពឆ្ពោះទៅរកគោលដៅនៃអភិបាលកិច្ចដែលបើកចំហ មានតម្លាភាព និងគណនេយ្យភាព។** បញ្ហាប្រឈមដ៏ធំដែលរារាំងប្រទេសកម្ពុជាពីការពឹងផ្អែកលើខ្លួនឯងនោះ គឺកង្វះខាតប្រជាធិបតេយ្យសេរី បណ្តាញផ្សព្វផ្សាយឯករាជ្យ និងសង្គមស៊ីវិលទន់ខ្សោយ និងកិច្ចការពារសិទ្ធិមនុស្សមិនបានល្អ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងពិន្ទុទាបនៅលើសន្ទស្សន៍ប្រជាធិបតេយ្យសេរី (Liberal Democracy Index) (0.0៩ នៅលើមាត្រដ្ឋាន 0 ដល់ ១)។[18] រដ្ឋធម្មនុញ្ញកម្ពុជាកំណត់ឱ្យប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស។[19] ទោះបីជាទិដ្ឋភាពនយោបាយក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៧៩ មានភាពចម្រុះគ្នាក៏ដោយ ប៉ុន្តែគណបក្សនយោបាយតែមួយកាន់កាប់ទាំង ១២៥ អសនៈនៅក្នុងសភាជាតិ និង ៥៨ ក្នុងចំណោម ៦២ អសនៈ នៅក្នុងព្រឹទ្ធសភា។[20] នៅក្នុងឆ្នាំ ២០១៧ គណបក្សប្រឆាំងត្រូវបានរំលាយ ហើយប្រធានរបស់គណបក្សនេះត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទក្បត់ជាតិ។ បណ្តាញផ្សព្វផ្សាយមួយចំនួនក៏ត្រូវបានបិទទ្វារផងដែរ។

គណនេយ្យភាព និងតម្លាភាពរបស់រដ្ឋាភិបាលក៏ជាផ្នែកដែលបង្កឱ្យមានបញ្ហាប្រឈមខ្លាំងដល់ការអភិវឌ្ឍផងដែរ។ យោងតាមអង្គការតម្លាភាពអន្តរជាតិ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៦២ ក្នុងចំណោម ១៨០ ប្រទេស នៅក្នុងសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ (The Corruption Perceptions Index) ឆ្នាំ ២០១៩ ហើយតាមរយៈសន្ទស្សន៍នេះបង្ហាញថា កម្ពុជាគឺជាប្រទេសមួយស្ថិតក្នុងចំណោមប្រទេសដែលពុករលួយបំផុតក្នុងពិភពលោក។[21] អំពើពុករលួយ តម្លាភាព និងនីតិរដ្ឋគឺជាផ្នែកដែលរាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការកែលម្អដើម្បីផ្តល់លទ្ធផលប្រសើរដល់ពលរដ្ឋរបស់ខ្លួន។ ការពឹងផ្អែកទៅលើធនធានខាងក្រៅដោយគ្មានតម្លាភាពក៏អាចធ្វើឱ្យអំពើពុករលួយកាន់តែមានសភាពធ្ងន់ធ្ងរ និងបង្កការគំរាមកំហែងទៅដល់អធិបតេយ្យភាពរបស់ប្រទេសផងដែរ។ ការវិនិយោគទាំងនេះជាច្រើនក៏នាំឱ្យមានកត្តាអវិជ្ជមានផ្សេងទៀត ដូចជា ឧក្រិដ្ឋកម្ម ការខូចខាតបរិស្ថាន និងការព្រួយបារម្ភរបស់សាធារណជនអំពីកម្រិតនៃការជំរុញផលប្រយោជន៍បរទេស។[22]

---

[18] សន្ទស្សន៍ប្រជាធិបតេយ្យសេរីភាគីទីបីធ្វើការវាស់វែងសេរីភាពនៃការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគម សិទ្ធិបោះឆ្នោត ការបោះឆ្នោត នីតិរដ្ឋ ឧបសគ្គប្រព័ន្ធតុលាការទៅលើអង្គនីតិប្រតិបត្តិ និងឧបសគ្គផ្នែកនីតិបញ្ញត្តិទៅលើអង្គនីតិប្រតិបត្តិ។ ប្រភព៖ ប្រភេទផ្សេងៗនៃប្រជាធិបតេយ្យ (V-Dem)។

[19] "រដ្ឋធម្មនុញ្ញកម្ពុជា" បកប្រែដោយក្រុមប្រឹក្សាធម្មនុញ្ញ ខែមីនា ឆ្នាំ ២០១០

[20] Prak Chan Thul, "គណៈបក្សកាន់អំណាចកម្ពុជាបានឈ្នះអសនៈទាំងអស់នៅក្នុងការបោះឆ្នោតខែកក្កដា៖ គណៈកម្មការរៀបចំការបោះឆ្នោត" Reuters, ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១៨

[21] "សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ" អង្គការតម្លាភាពអន្តរជាតិ ឆ្នាំ ២០១៩

[22] Kimkong Heng, "ការវិនិយោគចិនបង្កឧបសគ្គនៅក្នុងសង្គមកម្ពុជា" *Nikkea Asia* ថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០១៩

ប៉ុន្តែ នៅតែមានចំណុចដែលមានសុទិដ្ឋិនិយម។ ពលរដ្ឋកម្ពុជាអាចទទួលបានសេវាអ៊ីនធឺណិត[23] និងព័ត៌មានទូលំទូលាយ ជាពិសេសតាមរយៈបណ្តាញសង្គម។[24] ដោយសារអ្នកប្រើប្រាស់បណ្តាញសង្គមនៅកម្ពុជាកើនឡើង ១៧ ភាគរយ ជារៀងរាល់ឆ្នាំ បណ្តាញសង្គម និងអ៊ីនធឺណិតនៅតែផ្តល់ឱកាសដ៏ល្អដល់ប្រជាជនកម្ពុជាក្នុងការទទួលបានព័ត៌មានច្បាស់លាស់ និងមានតម្លាភាពដែលអាចធ្វើឱ្យការរស់នៅរបស់ពួកគាត់កាន់តែល្អប្រសើរ។ ទន្ទឹមនឹងនេះ ប្រជាជនកម្ពុជាភាគច្រើនមានការយល់ឃើញល្អចំពោះសហរដ្ឋអាមេរិក និងចាត់ទុកសហរដ្ឋអាមេរិកជាដៃគូដ៏ល្អបំផុតរបស់ប្រទេសកម្ពុជាសម្រាប់វិស័យពាណិជ្ជកម្ម និងសន្តិសុខ។[25] នៅលើទំព័រហ្វេសប៊ុកដែលរហូតមកដល់ពេលនេះមានអ្នកប្រើប្រាស់ចំនួនពាក់កណ្តាលនៃប្រជាជនសរុប វិទ្យុសំឡេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរីគឺជាទំព័រដែលមានប្រជាប្រិយភាពជាងគេលំដាប់ទីពីរក្នុងចំណោមប្រជាជនកម្ពុជា (បន្ទាប់ពីទំព័ររបស់នាយករដ្ឋមន្ត្រី)។[26] ចំណុចទិន្នន័យទាំងនេះបង្ហាញថា មានវេទិកាកាន់តែធំសម្រាប់បង្ហាញអំពីចំណុចអាទិភាពអាមេរិកនៅក្នុងតំបន់ និងការចាប់អារម្មណ៍កាន់តែខ្លាំងពីសាធារណជនទៅលើសេរីភាពអ៊ីនធឺណិត និងសារព័ត៌មានឯករាជ្យ។ តាមរយៈការលើកកម្ពស់បច្ចេកវិទ្យា ទីភ្នាក់ងារ USAID អាចបង្ហាញអំពីគំរូសហរដ្ឋអាមេរិកនៃឥណ្ឌូប៉ាស៊ីហ្វិកសេរី និងបើកចំហ ដោយផ្អែកលើការធ្វើសេចក្តីសម្រេចចិត្តមានតម្លាភាព និងផ្អែកលើវិធាន ទៅដល់ពលរដ្ឋកម្ពុជាជាច្រើន។

**វិស័យសុខាភិបាល និងវិស័យអប់រំសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ប៉ុន្តែទោះបីជាយ៉ាងណា បញ្ហាប្រឈមមួយចំនួននៅតែកើតមាន។** នៅក្នុងវិស័យសុខាភិបាល ប្រទេសកម្ពុជាបានបោះជំហានយ៉ាងច្បាស់លាស់នៅក្នុងការដោះស្រាយបញ្ហាជំងឺឆ្លង ដែលរួមមានជំងឺគ្រុនចាញ់[27] អេដស៍ (HIV)[28] និងរបេង (TB)[29]។ ប្រទេសកម្ពុជាក៏បានមើលឃើញការធ្លាក់ចុះជាលំដាប់នូវមរណភាពមាតាក្នុងរយៈពេល១៥ឆ្នាំកន្លងមក។ ទោះបីជាទទួលបានលទ្ធផលទាំងនេះក្តី ក៏នៅតែមានការចំណាយចេញពីហោប៉ៅខ្ពស់ទៅលើការថែទាំសុខភាព[30] ហើយអត្រាគ្រិននៅក្នុងប្រទេសកម្ពុជាមានអត្រាខ្ពស់ជាងគេនៅក្នុងតំបន់។ ដោយសារកង្វះអនាម័យ និងរបបអាហារមានជីវជាតិកម្រិតទាប ធ្វើឱ្យកុមារកម្ពុជាចំនួនមួយភាគបីមានភាពគ្រិន។[31] អត្រានៃភាពស្លេកស្លាំងក៏មានកម្រិតខ្ពស់ផងដែរ (៤៥,៤% ក្នុងចំណោមស្ត្រី និង ៥៥,៥ ភាគរយក្នុងចំណោមកុមារ)

[23] "អ្នកប្រើប្រាស់អ៊ីនធឺណិតក្នុងប្រទេសកម្ពុជាកើនឡើង 20 ភាគរយទៅដល់ 16.1 លាននាក់ក្នុងឆ្នាំ2019" *ខ្មែរថាមស៍* ថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០២០

[24] ការប្រើប្រាស់ទូរសព្ទចល័តមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយមានការភ្ជាប់ទូរសព្ទចល័តចំនួន ជិត 130 លានគ្រឿង នៅក្នុងប្រទេសកម្ពុជាសម្រាប់ប្រជាជនសរុបចំនួន ១៦,៦ លាននាក់ ដែលធ្វើឱ្យប្រជាជនដែលមានអ៊ីនធឺណិត និងបណ្តាញសង្គមប្រើប្រាស់មានការកើនឡើង។ អ្នកប្រើប្រាស់បណ្តាញសង្គម ១០០ ភាគរយអាចប្រើប្រាស់បណ្តាញសង្គមតាមរយៈទូរសព្ទចល័តរបស់ខ្លួន ហើយក្រុមហ៊ុន Facebook រាយការណ៍អំពីលទ្ធភាពគ្របដណ្តប់ចំនួន ៧៦ ភាគរយនៃពលរដ្ឋកម្ពុជាទាំងអស់ដែលមានអាយុលើស ១៣ ឆ្នាំ តាមរយៈការផ្សាយពាណិជ្ជកម្មដែលបានដាក់នៅលើកម្មវិធីរបស់ខ្លួន។ ប្រភព "ឌីជីថល 2020៖ ប្រទេសកម្ពុជា" DataReportal

[25] Richard Bush និង Maeve Whelan-Wuest, Brookings Institution "អាមេរិក (និងប្រទេសចិន) ក្នុងក្រសែភ្នែកអាស៊ាន" ២០១៧

[26] "ស្ថិតិទំព័រហ្វេសប៊ុកកម្ពុជា" SocialBakers។

[27] ការស្លាប់ដោយសារជំងឺគ្រុនចាញ់បានធ្លាក់ចុះពីមួយករណីក្នុងឆ្នាំ ២០១៧ មកដល់ចំនួនសូន្យក្នុងឆ្នាំ ២០១៨ និង ២០១៩ ហើយប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណើរឆ្ពោះទៅរកការលុបបំបាត់ជំងឺគ្រុនចាញ់ទូទាំងប្រទេស។ របាយការណ៍ប្រចាំឆ្នាំស្តីពីជំងឺគ្រុនចាញ់កម្ពុជាឆ្នាំ ២០១៩ បានបង្ហាញថា ករណីជំងឺគ្រុនចាញ់ដែលបានរកឃើញក្នុងមួយឆ្នាំមានចំនួន ៣១.៩៧១ ករណី ពោលគឺធ្លាក់ចុះ ៤៩ ភាគរយបើធៀបនឹងឆ្នាំ ២០១៨។ ប្រភព៖ របាយការណ៍ប្រចាំឆ្នាំស្តីពីជំងឺគ្រុនចាញ់កម្ពុជាឆ្នាំ ២០១៩។

[28] អត្រាប្រេវ៉ាឡង់មេរោគអេដស៍សម្រាប់មនុស្សពេញវ័យបានធ្លាក់ចុះជាបន្តបន្ទាប់មកត្រឹម ០,៥ ភាគរយក្នុងឆ្នាំ ២០១៩ ដោយមានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ៧៣.០០០ នាក់។ ចំនួនអ្នកឆ្លងមេរោគអេដស៍ថ្មីក៏បានធ្លាក់ចុះពី ២០០០ នាក់ក្នុងឆ្នាំ ២០១០ មកនៅត្រឹម ៧៨០ នាក់ក្នុងឆ្នាំ ២០១៩ ដែលមានការថយចុះចំនួន ៦២ ភាគរយ។ ប្រភព៖ ឯកសារព័ត៌មាន UNAIDS Cambodia Factsheet, ២០១៩

[29] ការប៉ាន់ប្រមាណអត្រាកើតជំងឺរបេងប្រចាំឆ្នាំនៅកម្ពុជាបានធ្លាក់ចុះពី ៥៧៥ ករណីក្នុងឆ្នាំ ២០០០ មកត្រឹម ៤២៣ ករណី ក្នុងឆ្នាំ ២០១១ និង ៣២៦ ករណី ក្នុងចំណោម ១០០.០០០ នាក់ ក្នុងឆ្នាំ ២០១៧ ដោយមានអត្រាថយចុះប្រចាំឆ្នាំជាមធ្យម ២,៥ ភាគរយ។ ប្រភព៖ WHO World Health Data Platform។

[30] ការចំណាយប្រាក់ចេញពីហោប៉ៅមានចំនួនប្រមាណ ៦០ ភាគរយនៃការចំណាយសុខភាពបច្ចុប្បន្ន។ ប្រភព៖ Cambodia National Health Accounts (២០១២-២០១៦), អង្គការសុខភាពពិភពលោក, ឆ្នាំ ២០១៩

[31] ការអង្កេតសុខភាពប្រជាសាស្ត្រកម្ពុជា DHS, ២០១៥, ១៩៥

។ រដ្ឋាភិបាលកម្ពុជាខិតខំប្រមូលធនធានចាំបាច់សម្រាប់វិធីសាស្រ្តឆ្លងវិស័យដែលតម្រូវឱ្យមានសម្រាប់ដោះស្រាយមូលហេតុនៃកង្វះអាហារូបត្ថម្ភ។

នៅក្នុងវិស័យអប់រំ ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយសម្រេចបានអត្រាចូលរៀនបឋមសិក្សា ៩៨% ក្នុងឆ្នាំ ២០១៩។[32] ប្រទេសកម្ពុជាបានពង្រឹងការចុះឈ្មោះក្មេងស្រី និងសម្រេចបានសមភាពយេនឌ័រ (១.០១)[33] នៅក្នុងការអប់រំបឋមសិក្សា។ ទិន្នន័យទូទាំងប្រទេសបង្ហាញថា បច្ចុប្បន្ននេះក្មេងស្រីបានបញ្ចប់មធ្យមសិក្សាបឋមភូមិចំនួនជិត ២០ ភាគរយ ច្រើនជាងក្មេងប្រុស។[34] ទោះជាសម្រេចបានលទ្ធផលទាំងនេះក្តី ប្រទេសកម្ពុជាមានផលធៀបសិស្សគ្រូខ្ពស់ជាងគេនៅក្នុងតំបន់ និងអត្រាបោះបង់ការសិក្សាខ្ពស់។[35] សិស្សម្នាក់តែប៉ុណ្ណោះក្នុងចំណោមប្រាំនាក់ដែលចាប់ផ្តើមថ្នាក់ទី ១ នឹងបញ្ចប់ថ្នាក់ទី ១២។

ទោះបីប្រទេសកម្ពុជាប្រឈមមុខនឹងបញ្ហាសុខភាព និងការអប់រំយ៉ាងណាក្តី ប៉ុន្តែនៅតែមានឱកាសជាច្រើនក្នុងការលើកកម្ពស់ស្ថានភាពរបស់ប្រជាជនកម្ពុជា។ ក្រសួងអប់រំដែលមានការប្តេជ្ញាចិត្តខ្ពស់ កំពុងប្រើប្រាស់កម្មវិធីសិក្សាដែលគាំទ្រដោយទីភ្នាក់ងារ USAID ដើម្បីធ្វើការពង្រីកការអប់រំកម្រិតបឋមសិក្សាទូទាំងប្រទេសឱ្យបានឆាប់រហ័ស។ វិមជ្ឈការ និងវិសហមជ្ឈការ កំពុងផ្តល់សិទ្ធិអំណាចដល់ថ្នាក់ដឹកនាំស្រុក និងខេត្ត ក្នុងការបែងចែកធនធានសុខាភិបាល និងអប់រំ។ សេចក្តីសម្រេចចិត្តដែលបានរៀបចំកាលពីមុនដោយក្រសួងពាក់ព័ន្ធ។ ថ្នាក់ដឹកនាំផ្នែកសុខាភិបាលកំពុងពង្រីកយ៉ាងឆាប់រហ័សនូវមូលនិធិសមធម៌សុខាភិបាល (HEF) ដើម្បីការពារប្រជាជនដែលងាយរងគ្រោះបំផុត ដែលរួមទាំងអ្នកផ្ទុកមេរោគអេដស៍ផងដែរ។

**បញ្ហាប្រឈមនៃអំពើជួញដូរមនុស្ស (TIP) នៅតែកើតមាន ដែលប៉ះពាល់ទៅដល់ប្រជាជនងាយរងគ្រោះ និងមិនត្រូវបានយកចិត្តទុកដាក់ភាគច្រើន ប៉ុន្តែនៅមានឱកាសជាច្រើនសម្រាប់កែលម្អ។** ប្រទេសកម្ពុជា បានកាត់បន្ថយពលកម្មដោយបង្ខំក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ ជាពិសេសនៅក្នុងវិស័យកាត់ដេរនាំចេញ អាជីវកម្មផ្លូវភេទ និងក្នុងចំណោមអ្នកបម្រើតាមផ្ទះ។

ទោះបីជាយ៉ាងនេះក្តី ការជាប់បំណុលនៅតែបន្តកើតមាននៅក្នុងវិស័យមួយចំនួន ហើយការជួញដូរមនុស្សនៅតែជាបញ្ហាប្រឈមដ៏សំខាន់ក្នុងការអភិវឌ្ឍ និងសិទ្ធិមនុស្ស។ ជាប្រទេសប្រភព ប្រទេសឆ្លងកាត់ និងប្រទេសគោលដៅសម្រាប់ការជួញដូរមនុស្ស ប្រទេសកម្ពុជាត្រូវបានវាយតម្លៃថាស្ថិតក្នុងបញ្ជីឃ្លាំមើលកម្រិត ២ (Tier 2 Watch List) នៃរបាយការណ៍ TIP[36] របស់ក្រសួងការបរទេសសម្រាប់ឆ្នាំ ២០២០ ដែលធ្វើឱ្យប្រទេសកម្ពុជាជាប់ឈ្មោះនៅក្នុងបញ្ជីនេះរយៈពេលពីរឆ្នាំជាប់ៗគ្នា។ យោងតាមរបាយការណ៍ TIP សម្រាប់ប្រទេសកម្ពុជា អាជ្ញាធរមិនបានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូល ឬចែករំលែកព័ត៌មានសំខាន់ៗជាមួយមន្ត្រីអនុវត្តច្បាប់ឡើយ។ អំពើពុករលួយបានបន្តរាំងដល់ប្រតិបត្តិការអនុវត្តច្បាប់ ដំណើរការនីតិវិធីព្រហ្មទណ្ឌ

[32] "ការអប់រំក្នុងលទ្ធផលប្រទេសកម្ពុជាពីបទពិសោធន៍របស់ប្រទេសកម្ពុជានៅក្នុង PISA សម្រាប់ការអភិវឌ្ឍ" OECD, ២០១៨, ១៣៥

[33] ទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មានក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩-២០២០

[34] "ហេតុអ្វីបានជាក្មេងប្រុសនៅប្រទេសកម្ពុជាឈប់សិក្សានៅថ្នាក់បឋមសិក្សាតាំងពីនៅវ័យក្មេង?" អង្គការ UNICEF, ឆ្នាំ ២០២០

[35] "យុទ្ធសាស្រ្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រទេសកម្ពុជា ការពិនិត្យពាក់កណ្តាលវគ្គ ឆ្នាំ២០១៤-២០១៨" ទីភ្នាក់ងារ USAID, ២០១៦, ៩

[36] "របាយការណ៍ស្តីពីការជួញដូរមនុស្ស" ក្រសួងការបរទេសអាមេរិក ខែមិថុនា ឆ្នាំ ២០២០

និងការផ្តល់សេវាជនរងគ្រោះ។ នៅពេលវិធានការត្រួតពិនិត្យ និងវិធានការគណនេយ្យភាពរបស់រដ្ឋាភិបាលមិនមានលក្ខណៈគ្រប់គ្រាន់ អាជ្ញាធរមិនបានស៊ើបអង្កេតរបាយការណ៍គួរឱ្យទុកចិត្តនៃភាពស្មុគស្មាញជាផ្លូវការពាក់ព័ន្ធនឹងម្ចាស់អាជីវកម្មមិនគោរពច្បាប់ ដែលបានជំរុញមនុស្សប្រុសស្រី និងកុមាររាប់ពាន់នាក់នៅទូទាំងប្រទេសឱ្យជួបប្រទះការជួញដូរមនុស្សនៅតាមមណ្ឌលកម្សាន្ត និងឡតដ្ឋ។ ទោះបីយ៉ាងណា នៅក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ រដ្ឋាភិបាលបានបង្ហាញឆន្ទៈបន្ថែមទៀតក្នុងការធ្វើឱ្យប្រសើរឡើងនូវយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស និងបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាដ៏សំខាន់នេះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមមានការបន្តកាត់ទោស និងផ្តន្ទាទោសអ្នកជួញដូរ ការបង្កើតផែនការសកម្មភាពប្រឆាំងការជួញដូរមនុស្សរយៈពេលប្រាំឆ្នាំថ្មី និងការប្រើប្រាស់បច្ចេកវិទ្យាកំណត់អត្តសញ្ញាណជនរងគ្រោះ និងប្រមូលទិន្នន័យថ្មី[37]។

**អត្រាខ្ពស់នៃការកាប់បំផ្លាញព្រៃឈើ និងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ បង្កឱ្យមានបញ្ហាប្រឈមធ្ងន់ធ្ងរចំពោះការអភិវឌ្ឍប្រកបដោយចីរភាព និងការអភិរក្សបរិស្ថាន ប៉ុន្តែនៅមានឱកាស។** ទេសភាពព្រៃឈើចម្រុះរបស់ប្រទេសកម្ពុជារងការគំរាមកំហែងដោយសារផលប្រយោជន៍សេដ្ឋកិច្ចដែលពុំមានចីរភាព ដូចជាការប្រមូលផល និងការនាំចេញឈើខុសច្បាប់ ការប្រែក្លាយដីព្រៃឈើទៅជាដីសម្រាប់ការបង្កបង្កើនផល ការពង្រីកកសិកម្មឧស្សាហកម្ម និងការរុករករ៉ែ។ សន្តិសុខដីធ្លីក៏ជាបញ្ហាចម្បងមួយនៅក្នុងប្រទេសកម្ពុជាផងដែរ ដែលបង្កឡើងដោយសម្បទានដីសេដ្ឋកិច្ច ដែលជាញឹកញាប់សម្រាប់វិនិយោគិនបរទេស ដែលបង្កផលប៉ះពាល់ទៅដល់ជីវភាពរស់នៅ និងសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋាន។ អត្រាការកាប់បំផ្លាញព្រៃឈើរបស់កម្ពុជាមានអត្រាខ្ពស់ជាងគេលំដាប់ទីបួនក្នុងចំណោមប្រទេសព្រៃឈើធំៗ ដែលមានការបាត់បង់លើសពីមួយភាគរយក្នុងមួយឆ្នាំ។[38] យោងតាមតួលេខផ្លូវការដែលផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ឆ្នាំ ២០១៦ ព្រៃឈើគ្របដណ្តប់ប្រមាណ ៤៨ ភាគរយនៃផ្ទៃដីប្រទេសទាំងមូល។ ទោះបីជាយ៉ាងណា តួលេខនេះរាប់បញ្ចូលទាំងចម្ការកៅស៊ូ និងដូងប្រេងដែលពុំមានចីរភាពបរិស្ថាន និងដំណាំដែលមានអាយុកាលច្រើនឆ្នាំផ្សេងទៀតផងដែរ។[39] យោងតាមអង្គការឃ្លាំមើលព្រៃឈើសកល (Global Forest Watch) ចាប់តាំងពីឆ្នាំ ២០០១ ដល់ ២០១៩ ប្រទេសកម្ពុជាបានបាត់បង់គម្របព្រៃឈើ ២,៣១ លានហិកតា ដែលស្មើនឹងការធ្លាក់ចុះគម្របព្រៃឈើចំនួន ២៦ ភាគរយ គិតចាប់ពីឆ្នាំ ២០០០។ កត្តានេះបានបណ្តាលឱ្យមានការបំភាយកាបូន (ឌីអុកស៊ីត $CO_2$) បន្ថែម ៩៧៣ តោន។[40] ទោះបីយ៉ាងណា ព្រៃឈើដ៏ធំនៅពុំមានការបាត់បង់ និងមានទេសភាពដែលមានលក្ខណៈពិសេសផ្នែកជីវសាស្ត្រ ជាតំបន់បេតិកភណ្ឌវប្បធម៌ដ៏សំខាន់ និងផ្តល់ទីលំនៅនិងមុខរបរចិញ្ចឹមជីវិត ដល់គ្រួសារខ្មែរក្រីក្រ និងងាយរងគ្រោះបំផុតមួយចំនួន។ សហគមន៍ជនជាតិដើមភាគតិចដែលបានរស់នៅក្នុង និងជុំវិញតំបន់ព្រៃឈើជាច្រើនជំនាន់ កំពុងប្រឈមមុខនឹងការបាត់បង់វប្បធម៌ និងប្រពៃណីរបស់ខ្លួន ដោយសារតែកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ទ្រង់ទ្រាយធំដែលពុំមានចីរភាព។

---

[37] Ibid

[38] "ការវិភាគព្រៃត្រូពិច និងជីវចម្រុះកម្ពុជា 118/119" USAID, ICF, The Cadmus Group and ICEM, 2019, v."

[39] "គម្របព្រៃឈើកម្ពុជា ឆ្នាំ2016" ក្រុមវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ក្រសួងបរិស្ថាន ខែមីនា ឆ្នាំ ២០១៨, ១៣

[40] "សូចនាករបាត់បង់គម្របព្រៃឈើ" អង្គការឃ្លាំមើលព្រៃឈើសាកល ឆ្នាំ ២០១៩

ក្រៅពីបញ្ហាប្រឈម ដែលបង្កឡើងដោយការកាប់បំផ្លាញព្រៃឈើ ការប្រែប្រួលអាកាសធាតុនឹងបន្តធ្វើឱ្យប៉ះពាល់ដល់ប្រទេសកម្ពុជា ដោយផលប៉ះពាល់ខ្លាំងបំផុតអាចនឹងកើនឡើងទាំងសីតុណ្ហភាព និងហេតុការណ៍ដែលមានភ្លៀងធ្លាក់ខ្លាំង។[41] ការប្រែប្រួលសីតុណ្ហភាព និងបរិមាណធ្លាក់ភ្លៀងត្រូវបានព្យាករណ៍ថា នឹងប៉ះពាល់ដល់វិស័យសំខាន់ៗក្នុងប្រទេសកម្ពុជា ដែលរួមមានវិស័យកសិកម្ម និងសន្តិសុខស្បៀង នេសាទ ប្រព័ន្ធអេកូឡូស៊ី សុខភាព និងធនធានទឹក។

ឱកាសនាំមកនូវការផ្លាស់ប្ដូរជាប្រព័ន្ធក្នុងការគ្រប់គ្រងទេសភាពប្រកបដោយចីរភាពនៃប្រទេសកម្ពុជាកំពុងមានការកើនឡើងដោយសារមានការផ្លាស់ប្ដូរច្បាប់ និងបទប្បញ្ញត្តិថ្មីៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការកើនឡើងនាពេលថ្មីៗនៃការអនុវត្តច្បាប់ដើម្បីប្រឆាំងនឹងការទន្ទ្រានយកដី និងការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់អភិរក្ស។ ជាងនេះទៅទៀត ក្រសួងបរិស្ថានកំពុងដឹកនាំការកែសម្រួលយ៉ាងសំខាន់ និងគ្រប់ជ្រុងជ្រោយ ទោះបីមានដំណើរការយឺតៗ នូវច្បាប់ជាច្រើនដែលភ្ជាប់ការអភិវឌ្ឍសេដ្ឋកិច្ចទៅនឹងការអភិរក្ស និងការការពារព្រៃឈើ។ ការបង្កើតប្រាក់ចំណូលពីការអភិរក្សគឺជារក្សាតុល្យភាពដ៏សំខាន់ចំពោះសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច ដូចជា ការជីកយករ៉ែដែលគំរាមកំហែងដល់តំបន់អភិរក្សរបស់កម្ពុជា។ តាមរយៈភាពជោគជ័យដំបូងនៃការបង្កើត និងលក់ឥណទានកាបូននៅក្នុងកម្មវិធីជាតិកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ (REDD+) នៅកម្ពុជា ទើបមានឱកាសក្នុងការពង្រីកកម្មវិធី REDD+ ទៅកាន់តំបន់ថ្មីៗក្នុងប្រទេសកម្ពុជា ក៏ដូចជាជំរុញឱ្យមានចំណាប់អារម្មណ៍ពីវិស័យឯកជនទៅលើឱកាសវិនិយោគប្រកបដោយចីរភាព។ ការបង្កើនការចូលរួមពីវិស័យឯកជននៅក្នុងសកម្មភាពជីវភាពនៅក្នុង និងជុំវិញតំបន់អភិរក្សនឹងជួយពង្រឹងសកម្មភាពសេដ្ឋកិច្ចប្រកបដោយចីរភាពដូចជា ទេសចរណ៍ធម្មជាតិ កសិកម្មប្រកបដោយចីរភាព និងព្រៃឈើ ព្រមទាំងឱកាសរកប្រាក់ចំណូលផ្សេងទៀតពីអនុផលព្រៃឈើផងដែរ។

**បញ្ហាជួញដូរសត្វព្រៃកាន់តែកើនឡើងខ្លាំងនៅក្នុងប្រទេសកម្ពុជា។** នៅក្នុងរបាយការណ៍ឆ្នាំ ២០២០ ទៅកាន់សភាអាមេរិក ក្រោមច្បាប់ស្ដីពីការលុបបំបាត់ ទប់ស្កាត់ និងរារាំងការជួញដូរសត្វព្រៃ (Eliminate, Neutralize, and Disrupt Wildlife Trafficking Act) ឆ្នាំ ២០១៦ ក្រសួងការបរទេសបានកំណត់ប្រទេសកម្ពុជាជាប្រទេសគួរឱ្យព្រួយបារម្ភ។[42] ប្រទេសកម្ពុជាត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាប្រភពដ៏សំខាន់ និងជាប្រទេសឆ្លងកាត់សម្រាប់ការជួញដូរសត្វព្រៃខុសច្បាប់ ដោយសារការអនុវត្តច្បាប់ និងការគោរពច្បាប់ជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិនៅមានភាពទន់ខ្សោយ។ ប្រទេសកម្ពុជាជាប្រភពនៃការជួញដូរសត្វព្រៃទៅកាន់ប្រទេសវៀតណាម និងប្រទេសចិន ដោយមានការដាក់អន្ទាក់ដោយមិនរើសមុខនៅក្នុងព្រៃដែលប៉ះពាល់ទាំងប្រភេទសត្វព្រៃទូទៅ និងប្រភេទដែលជិតផុតពូជ។ លើសពីនេះទៅទៀត កម្ពុជាគឺជាប្រទេសឆ្លងកាត់ដ៏សំខាន់សម្រាប់សត្វព្រៃ និងប្រភេទសត្វមានតម្លៃជាច្រើនរបស់ពិភពលោកដែលត្រូវបានជួញដូរពីទ្វីបអាហ្វ្រិកទៅកាន់ទីផ្សារអាស៊ី។ ការកាប់បំផ្លាញដោយខុសច្បាប់នូវប្រភេទឈើដែលរងការគំរាម

[41] "ការវិភាគអំពីការគ្រប់គ្រងហានិភ័យអាកាសធាតុទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា" ទីភ្នាក់ងារ USAID, ឆ្នាំ ២០២០

[42]នៅក្រោមច្បាប់ស្ដីពីការជួញដូរសត្វព្រៃ END "ប្រទេសយកចិត្តទុកដាក់" ត្រូវបានកំណត់ថាជាប្រទេសប្រភពចម្បង ប្រទេសឆ្លងកាត់ ឬប្រទេសប្រើប្រាស់ផលិតផលជួញដូរសត្វព្រៃ ឬផលិតផលសត្វព្រៃ ប៉ុន្តែការកំណត់ជាប្រទេសយកចិត្តទុកដាក់ មិនមែនជាការកំណត់វិជ្ជមាន ឬអវិជ្ជមានឡើយ។ ទោះបីយ៉ាងណា "ប្រទេសមានការព្រួយបារម្ភ" ត្រូវបានកំណត់ថាជាប្រទេសយកចិត្តទុកដាក់ ដែលរដ្ឋាភិបាលបានចូលរួមយ៉ាងសកម្ម ឬទទួលបានប្រាក់ចំណេញដោយចេតនាពីការជួញដូរសត្វព្រៃដែលជិតផុតពូជ ឬរងគំរាមកំហែង។

កំហែងក៏នៅតែបន្តកើតឡើងនៅទូទាំងប្រទេសផងដែរ។ ទោះបីជាប្រជាជនកម្ពុជានៅតាមតំបន់ជនបទបរិភោគ និងប្រើប្រាស់ផលិតផលសត្វព្រៃសម្រាប់ជាអាហារ និងការប្រតិបត្តិវប្បធម៌ប្រពៃណីយ៉ាងណាក្តី ក៏វិសាលភាពនៃសកម្មភាពទាំងនេះមានបរិមាណតិចតួចប៉ុណ្ណោះបើប្រៀបធៀបទៅនឹងការជួញដូរសត្វព្រៃខុសច្បាប់ឆ្លងដែន។ សកម្មភាពទាំងអស់របស់ទីភ្នាក់ងារ USAID ទាំងអស់ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរសត្វព្រៃ នឹងសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាលអាមេរិក និងអង្គភាពអនុវត្តច្បាប់ដទៃទៀត ស្របទៅតាម “យុទ្ធសាស្ត្រសម្រាប់ប្រឆាំងការជួញដូរសត្វព្រៃនៅកម្ពុជា” (២០១៨)។

**ស្ត្រី និងក្រុមប្រជាជនមិនត្រូវបានយកចិត្តទុកដាក់ នៅតែទទួលបានអត្ថប្រយោជន៍តិចតួចបំផុតពីកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ប៉ុន្តែចំនួនយុវជនដ៏ច្រើនបង្ហាញអំពីឱកាសក្នុងការជំរុញកំណើនប្រកបដោយបរិយាបន្ន និងការកើនឡើងនូវការចូលរួមរបស់ពលរដ្ឋ។** នៅប្រទេសកម្ពុជា ស្ត្រី យុវជន ជនជាតិដើមភាគតិច និងជនជាតិភាគតិច ស្រីស្រលាញ់ស្រីដូចគ្នា បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរភេទ អ្នកមានភេទប្រុសផងស្រីផង (LGBTI) និងជនមានពិការភាព ជួបប្រទះនូវឧបសគ្គដែលរារាំងពួកគេមិនឱ្យចូលរួមពេញលេញនៅក្នុងការអភិវឌ្ឍប្រទេស។ ជារឿយៗ ក្រុមទាំងនេះ មិនត្រូវបានយកចិត្តទុកដាក់ ដោយសារបទដ្ឋាន និងការប្រតិបត្តិវប្បធម៌ ដែលជំរុញឱ្យមានវិសមភាពយេនឌ័រ ការមិនរាប់បញ្ចូលផ្លូវច្បាប់ និងការរើសអើងផ្អែកលើអត្តសញ្ញាណ។ សមភាពយេនឌ័រផ្តោតមិនត្រឹមតែទៅលើស្ត្រី និងក្មេងស្រីប៉ុណ្ណោះទេ។ បុរស និងក្មេងប្រុសជួបប្រទះនូវការលំបាកពីបទដ្ឋានវប្បធម៌ និងសង្គម ដូចជាការទទួលយកការងារដែលមានហានិភ័យ ងាយរងគ្រោះ ហើយពេលខ្លះ គឺការងារដែលមានលក្ខណៈកេងប្រវ័ញ្ច។ បទដ្ឋានយេនឌ័រក៏រារាំងការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិតនៃការដឹកនាំនៅក្នុងជួររដ្ឋាភិបាល វិស័យឯកជន ក៏ដូចជាសង្គមស៊ីវិលផងដែរ។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី ៨៩ ក្នុងចំណោម ១៥៣ ប្រទេស ស្តីពីសមភាពយេនឌ័រទូទៅ[43] ដោយមានពិន្ទុអនុវត្តទាបសម្រាប់អត្រានៃការចូលរួមកម្លាំងពលកម្ម (៥៧ ក្នុងចំណោម ១៥៣) និងពិន្ទុទាបខ្លាំងសម្រាប់ការផ្តល់ភាពអង់អាចផ្នែកនយោបាយ (១១៩ ក្នុងចំណោម ១៥៣)[44] ស្ត្រីកម្ពុជាភាគច្រើនខ្វះខាតជំនាញ និងការបណ្តុះបណ្តាលដែលត្រូវការចាំបាច់ក្នុងវិស័យកសិកម្ម ភាពជាសហគ្រិន ការគ្រប់គ្រងធនធានធម្មជាតិ និងសេវាសុខភាពសាធារណៈ។ លើពីនេះទៅទៀត អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ គឺជាបញ្ហាប្រឈមដ៏សំខាន់នៅក្នុងការអភិវឌ្ឍ និងសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ ស្ត្រីម្នាក់ក្នុងចំណោមប្រាំនាក់បានលើកឡើងថា ខ្លួនធ្លាប់ជួបប្រទះអំពើហិង្សាផ្លូវភេទ និងលើរាងកាយពីដៃគូស្នេហា ហើយវិធានការទៅលើអ្នករំលោភបំពានតែងតែត្រូវបានដោះស្រាយ និងសម្របសម្រួលដោយមេភូមិដែលជាបុរស។ ការរឹតបន្តឹងលើការធ្វើដំណើរ និងការកើនឡើងនូវកម្រិតភាពតានតឹងផ្នែកហិរញ្ញវត្ថុដោយសារតែជំងឺកូវីដ-១៩ បានធ្វើឱ្យស្ត្រីប្រឈមនឹងហានិភ័យកាន់ តែខ្លាំងនៃអំពើហិង្សាពីដៃគូស្នេហានៅផ្ទះ និងកាត់បន្ថយជម្រើសក្នុងការស្វែងរកសេវាគាំទ្រ។[45] ស្ត្រីដែលមានពិការភាព បានលើកឡើងអំពីអត្រាកាន់តែខ្ពស់ខ្លាំងនៃ

[43] “របាយការណ៍គម្លាតយេនឌ័រសាកលសម្រាប់ឆ្នាំ2020” វេទិកាសេដ្ឋកិច្ចសាកល ឆ្នាំ ២០១៩

[44] ចំនួនស្ត្រីនៅក្នុងការិយាល័យសាធារណៈបានកើនឡើងពី ៣២ ទៅ ៤១ ភាគរយនៅឆ្នាំ ២០១៩។ មានឯកអគ្គរដ្ឋទូតស្ត្រីចំនួន ៤ រូប ឧបនាយករដ្ឋមន្ត្រីស្ត្រីម្នាក់ រដ្ឋមន្ត្រីស្ត្រីចំនួន ៣ រូប រដ្ឋលេខាធិការចំនួន ៥៣ រូប និងអនុរដ្ឋលេខាធិការចំនួន ៧៣ រូប។ ប្រភព៖ Niem Chheng, “ការអំពាវនាវឱ្យមានស្ត្រីបន្ថែមទៀតនៅក្នុងមុខតំណែងដឹកនាំ” *ភ្នំពេញ ប៉ុស្តិ៍* ថ្ងៃទី១២ ខែមីនា ឆ្នាំ ២០២០។

[45] “ការវិភាគយេនឌ័ររហ័សរបស់អង្គការ CARE សម្រាប់ជំងឺកូវីដ-19៖ ប្រទេសកម្ពុជា” អង្គការ CARE ខែកក្កដា ឆ្នាំ២០២០

អំពើហិង្សាគ្រប់ទម្រង់។[46] ប្រជាជនកម្ពុជាដែលមានពិការភាពមានចំនួនប្រមាណ ២,០៦ ភាគរយនៃប្រជាជនសរុប (ស្ត្រី ៥២%)។ ពួកគាត់ប្រឈមនឹងការរើសអើងកាន់តែខ្លាំង ដោយសារតែលទ្ធភាពមានកម្រិតនៃការទទួលបានព័ត៌មាន សេវាសុខភាព ការអប់រំ កម្លាំងពលកម្ម និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។[47] ប្រជាជនកម្ពុជាប្រមាណ១០%គឺជាជនជាតិចាម វៀតណាម និងក្រុមជនជាតិដើមភាគតិច។ ពួកគាត់ជួបប្រទះការលំបាកខ្លាំងជាងប្រជាជនកម្ពុជាផ្សេងទៀតក្នុងការទទួលបានសេវាសុខភាព ការអប់រំ និងសិទ្ធិដីធ្លីប្រកបដោយគុណភាព។ បញ្ហាប្រឈមទាំងនេះកើតឡើងមួយផ្នែកដោយសារភាសា វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់សាសនា ខុសៗគ្នា។[48] ទោះបីជនជាតិចាមកាន់សាសនាឥស្លាមមានសញ្ជាតិខ្មែរស្រដៀងនឹងខ្មែរយ៉ាងណាក្តី ជនជាតិវៀតណាម និងកូនៗរបស់គាត់ពុំមានសញ្ជាតិខ្មែរឡើយ ដែលកត្តានេះរារាំងដល់លទ្ធភាពរបស់ពួកគេក្នុងការទទួលបានការអប់រំ និងសេវាផ្សេងៗទៀត។[49] មិនមានទិន្នន័យច្បាស់លាស់អំពីចំនួននៃអ្នកស្រឡាញ់ភេទដូចគ្នាឡើយ ហើយកម្ពុជាក៏មិនទាន់មានការទទួលស្គាល់តាមផ្លូវច្បាប់សម្រាប់ក្រុមប្រជាជនទាំងនេះនៅឡើយដែរ។ ដោយសារមូលហេតុនេះហើយទើបពួកគេនៅតែជួបប្រទះនឹងការរើសអើង ទាំងនៅក្នុង និងក្រៅសាលា ហើយមានលទ្ធភាពតិចតួចក្នុងការទទួលបានការងារ សេវាគាំពារសង្គម និងការការពារផ្នែកច្បាប់ ផ្សេងៗ។ ពាក់ព័ន្ធនឹងយុវជន ប្រជាជនកម្ពុជាប្រមាណពីភាគបីមានអាយុក្រោម ៣៥ ឆ្នាំ[50] ហើយការជំរុញឱ្យយុវជនចូលរួមនៅក្នុងសកម្មភាពរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក គឺមានសារៈសំខាន់ក្នុងការជួយប្រទេសកម្ពុជាឱ្យមានការអភិវឌ្ឍ និងរីកចម្រើន។ យុវជនកម្ពុជាគឺជាកម្លាំងចលករសម្រាប់ បង្កើនសកម្មភាពកែលម្អសេវាសាធារណៈ ក៏ដូចជាកំណែទម្រង់ផ្សេងៗ។ ការគាំទ្រសម្រាប់ស្ត្រីយុវជន និងក្រុមមិនត្រូវបានយកចិត្តទុកដាក់ផ្សេងទៀត គឺជាឱកាសមូលដ្ឋានសម្រាប់យុទ្ធសាស្ត្រថ្មី។

## ចំណុចអាទិភាពអភិវឌ្ឍជាតិរបស់ប្រទេសកម្ពុជា

នៅកម្រិតខ្ពស់បំផុត កម្លាំងជំរុញចម្បងដែលដឹកនាំការអភិវឌ្ឍជាតិរបស់ប្រទេសកម្ពុជា គឺយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី ៤ (RS-IV)[51] និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ២០១៩-២០២៣។[52] នៅក្នុង RS-IV និង NSDP រាជរដ្ឋាភិបាលបានកំណត់គោលដៅយុទ្ធសាស្ត្រចំនួនបួន៖ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការបង្កើតការងារ ការកាត់បន្ថយភាពក្រីក្រ និងការពង្រឹងសមត្ថភាព និងអភិបាលកិច្ចរបស់ស្ថាប័នសាធារណៈដើម្បីផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងបរិយាកាសធុរកិច្ចកាន់តែល្អប្រសើរ។ ការបំពេញបន្ថែមនូវគោលដៅយុទ្ធសាស្ត្រ RS-IV ក៏កំណត់ផ្នែកអាទិភាពចំនួនបួន ឬ "ចតុកោណយុទ្ធសាស្ត្រ" សម្រាប់ការអភិវឌ្ឍ៖ ១) ការអភិវឌ្ឍធនធានមនុស្ស ២) ពិពិធកម្មសេដ្ឋកិច្ច ៣) ការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន និងការងារ និង ៤) ការអភិវឌ្ឍលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព។ រាជរដ្ឋាភិបាលកម្ពុជាក៏បាន

---

46 "ការគាំទ្រដល់ប្រជាជនកម្ពុជាដែលព្យាយាមបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី" ជំនួយអូស្ត្រាលី ចូលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០។

47 "ការវិភាគការអភិវឌ្ឍយេនឌ័រ និងបរិយាបន្ន ទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា" USAID, ២០២០.

48 Ibid

49 Ibid

50 ទិន្នន័យប្រជាសាស្ត្រពី "ការអង្កេតប្រជាសាស្ត្រ និងសុខាភិបាលប្រទេសកម្ពុជា" (ឆ្នាំ២០១៤)។ ទោះបីជំរឿនត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០១៩ ទិន្នន័យផ្លូវការនឹងត្រូវបញ្ចេញនៅក្នុងរដូវរងារឆ្នាំ ២០២១

51 "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី IV" រាជរដ្ឋាភិបាលកម្ពុជា ខែកញ្ញា ឆ្នាំ២០១៨

52 "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ" រាជរដ្ឋាភិបាល ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩

បង្កើតគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ដែលគឺជាគោលដៅជាក់លាក់សម្រាប់កម្ពុជា នៅក្រោមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ[53] (UN) និងកំពុងដំណើរការបញ្ចប់ផែនការស្តារសេដ្ឋកិច្ចសង្គមក្រោយវិបត្តិជំងឺ-១៩។

## ចំណុចអាទិភាពសំខាន់ក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក

សហរដ្ឋអាមេរិកមានគោលដៅលើកកម្ពស់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកសេរី បើកចំហ និងមានយុត្តិធម៌ ដែលជំរុញការអភិវឌ្ឍ និងការពឹងផ្អែកលើខ្លួនឯងរបស់ប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ប្រទេសឱ្យមានឯករាជ្យភាព រឹងមាំ និងមានវិបុលភាព។ នៅក្នុងឆ្នាំ ១៩៩៧ សហរដ្ឋអាមេរិកបានផ្តល់អត្ថប្រយោជន៍ពាណិជ្ជកម្មដល់ប្រទេសកម្ពុជាតាមរយៈប្រព័ន្ធអនុគ្រោះពន្ធទូទៅ (Generalized System of Preferences) ហើយបច្ចុប្បន្នគឺជាទីផ្សារនាំចេញដ៏ធំបំផុតរបស់កម្ពុជា។[54] មានឱកាសសំខាន់ៗដើម្បីពង្រឹងភាពជាដៃគូរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា ដោយជួយដល់ប្រទេសកម្ពុជាឱ្យក្លាយជាដៃគូកាន់តែបើកចំហ មានវិបុលភាព ភាពធន់ និងបរិយាបន្ន នៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

ដោយផ្តោតលើកំណើនសេដ្ឋកិច្ចរួម ការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ច ទីភ្នាក់ងារ USAID មានគោលបំណងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ តាមរយៈការខិតខំពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាប័ន្ន និងចីរភាព ទីភ្នាក់ងារ USAID នឹងជំរុញអាទិភាពសេដ្ឋកិច្ច និងសន្តិសុខនៅក្នុងឥណ្ឌូប៉ាស៊ីហ្វិក ដោយធ្វើការកែលម្អការគ្រប់គ្រងធនធានធម្មជាតិ (រួមទាំងការជួញដូរសត្វព្រៃ) និងការកសាងក្របខ័ណ្ឌសម្រាប់ធ្វើពិពិធកម្មសេដ្ឋកិច្ច។ តាមរយៈការលើកកម្ពស់បទដ្ឋានល្អប្រសើរសម្រាប់ការវិនិយោគសាធារណៈ និងអភិបាលកិច្ចប្រកបដោយតម្លាភាព និងឆ្លើយតបចំពោះតម្រូវការពលរដ្ឋនៅក្នុងគោលបំណងអភិវឌ្ឍន៍ទាំងមូលរបស់ខ្លួន ទីភ្នាក់ងារ USAID ប្រចាំនៅកម្ពុជា នឹងជំរុញឱ្យមានភាពល្អប្រសើរផ្នែកអភិបាលកិច្ច។ នៅក្រោមយុទ្ធសាស្ត្រនេះ ទីភ្នាក់ងារជំនួយអាមេរិក USAID ក៏នឹងពង្រីកកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីផ្សេងទៀត តាមរយៈយន្តការផ្លូវការ និងវិធីសាស្ត្រក្រៅផ្លូវការ ដើម្បីចែករំលែកការអនុវត្ត សម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងអនុវត្តសកម្មភាព ឬមុខតំណែងរួម ដើម្បីលើកកម្ពស់គោលបំណងរួម។

## ដំណើរឆ្ពោះទៅការពឹងផ្អែកលើខ្លួនឯង (J2SR)៖ ការវិភាគផែនទីបង្ហាញផ្លូវប្រទេស

ផែនទីបង្ហាញផ្លូវ (J2SR) របស់ប្រទេសកម្ពុជា បង្ហាញថា ប្រទេសកម្ពុជាមានសមត្ថភាពខ្ពស់គួរសម ប៉ុន្តែពុំសូវមានការប្តេជ្ញាចិត្តឡើយ។ នៅកម្រិតខ្ពស់បំផុត ចំណុចសំខាន់ៗចំនួនពីរនៃផែនទីបង្ហាញផ្លូវថ្នាក់ជាតិ គឺពិន្ទុប្តេជ្ញាចិត្តកម្រិតទាបរបស់ប្រទេសកម្ពុជាសម្រាប់អភិបាលកិច្ចបើកចំហ និងប្រកបដោយគណនេយ្យភាព និងពិន្ទុសមត្ថភាពកម្រិតទាបសម្រាប់សមត្ថភាពរដ្ឋាភិបាល និងសមត្ថភាពសង្គមស៊ីវិល។

[53] "គោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា" រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២០។
[54] "ការនាំចេញរបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិកមានការកើនឡើង" ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០

**តារាង ១៖ សេចក្តីសង្ខេបនៃចំណុចខ្លាំង និងបញ្ហាប្រឈមរបស់ J2SR នៃប្រទេសកម្ពុជា**

| | បញ្ហាប្រឈម | ចំណុចខ្លាំង |
|---|---|---|
| **ការប្តេជ្ញាចិត្ត** | • ប្រជាធិបតេយ្យសេរី (0.0៩)<br>• រដ្ឋាភិបាលបើកចំហរ (0.0៦)<br>• សមភាពក្រុមសង្គម (0.៣៤)<br>• បរិយាកាសធ្វើអាជីវកម្ម និងវិនិយោគ (0.២៧)<br>• សេរីភាពក្នុងការធ្វើជំនួញ (0.៤៦)<br>• គោលនយោបាយបរិស្ថាន (0.១១) | • គម្លាតយេនឌ័រផ្នែកសេដ្ឋកិច្ច (0.៧៣) |
| **សមត្ថភាព** | *បញ្ហាប្រឈមច្បាស់លាស់*<br>• សង្គមស៊ីវិល និងប្រសិទ្ធភាពប្រព័ន្ធផ្សព្វផ្សាយ (0.៣៣)<br>• ផលិតផលក្នុងស្រុកសរុបក្នុងពលរដ្ឋម្នាក់ (0.៣៥)<br>*បញ្ហាប្រឈមកម្រិតមធ្យម*<br>• ប្រសិទ្ធិភាពនៃរដ្ឋាភិបាល (0.៤១)<br>• សុខភាពកុមារ (0.៧៣) | *ចំណុចខ្លាំងច្បាស់លាស់*<br>• សុវត្ថិភាព និងសន្តិសុខ (0.៥៩)<br>• ការដាក់បញ្ចូលបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) (0.៥៤)<br>*ចំណុចខ្លាំងកម្រិតមធ្យម*<br>• ប្រសិទ្ធិភាពនៃប្រព័ន្ធបង់ពន្ធ (0.៣៥)<br>• គុណភាពនៃការអប់រំ (0.៤៤) |

*កំណត់សម្គាល់៖ បញ្ហាប្រឈម និងចំណុចខ្លាំងដែលទាក់ទងត្រូវបានកំណត់ដោយផ្អែកលើពិន្ទុរបស់ប្រទេសកម្ពុជាសម្រាប់អនុវិស័យផ្សេងៗគ្នាបើប្រៀបធៀបទៅនឹងពិន្ទុមធ្យមសម្រាប់ប្រទេសមានចំណូលទាប និងចំណូលមធ្យមផ្សេងៗសម្រាប់អនុវិស័យនោះ ដូចមានកំណត់នៅលើផែនទីបង្ហាញផ្លូវរបស់ប្រទេស។ "បញ្ហាប្រឈម/ចំណុចខ្លាំងកម្រិតមធ្យម" ត្រូវបានកំណត់ថាបានពិន្ទុស្មើតែមធ្យម ចំណែកឯ "បញ្ហាប្រឈម/ចំណុចខ្លាំងច្បាស់លាស់" គឺនៅក្រោមកម្រិតមធ្យម។*

## ការប្តេជ្ញាចិត្ត

ទោះបីជា RS-IV ទទួលស្គាល់គោលការណ៍នៃប្រជាធិបតេយ្យពហុបក្ស និងនីតិរដ្ឋដែលត្រូវបានតំណាងដោយរដ្ឋធម្មនុញ្ញកម្ពុជា ពិន្ទុទាបបំផុតសម្រាប់ទាំងលទ្ធិប្រជាធិបតេយ្យសេរី និងអនុវិស័យរដ្ឋាភិបាលបើកចំហរ បង្ហាញពីតម្រូវការសម្រាប់សកម្មភាពធំជាងនេះ។ ខណៈពេលដែលគន្លងសម្រាប់ភាពប្រសើរឡើងនៃសមាសធាតុទាំងនេះមិនមានភាពជឿនលឿនក្នុងរយៈពេលខ្លី វិធីសាស្រ្តយុទ្ធសាស្រ្តត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់ប្រទេសកម្ពុជាក្នុងការជំរុញប្រទេសនេះក្នុងរយៈពេលយូរ។ បញ្ហាប្រឈមដ៏ធំបំផុតបន្ទាប់របស់ប្រទេសកម្ពុជាក្នុងរង្វាស់ទាំងនេះគឺភូមិសាស្រ្តបរិស្ថាន ដែលឆ្លុះបញ្ចាំងពីបញ្ហាប្រឈមដែលកំពុងបន្តរបស់ប្រទេសជាមួយនឹងការពង្រឹងច្បាប់ការពារបរិស្ថានជាច្រើន រួមទាំងច្បាប់ដែលត្រូវបានបង្កើតឡើងដើម្បីការពារការកាប់ព្រៃឈើខុសច្បាប់។ យើងនៅតែមិនទាន់អាចសម្រេចបានថាតើកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងបរិស្ថាន ក្នុងការកែប្រែច្បាប់ជាច្រើននឹងនាំមកនូវពិន្ទុប្រសើរឡើងសម្រាប់សមាសភាគនេះ និងបង្កើនការអភិរក្ស និងការការពារព្រៃឈើ។ ខណៈពេលដែលមាត្រដ្ឋានសម្រាប់សមាសធាតុរងនៃគម្លាតយេនឌ័រផ្នែកសេដ្ឋកិច្ច គឺមានអត្រាខ្ពស់ ប្រភពទិន្នន័យជាច្រើនបញ្ជាក់ថាចំណុចនេះគឺមិនត្រឹមត្រូវជាមួយនឹងស្ថានភាពផ្ទាល់នោះឡើយ។ បញ្ហាប្រឈមជាច្រើននៅតែមាននៅក្នុងតំបន់នេះ បើយោងទៅតាមការវិភាគបន្ថែម។[55]

[55] "USAID/ ការវិភាគការអភិវឌ្ឍយេនឌ័រ និងបរិយាបន្ននៅប្រទេសកម្ពុជា" USAID ឆ្នាំ ២០២០

## សមត្ថភាព

ការអនុវត្តរបស់ប្រទេសកម្ពុជាលើមាត្រដ្ឋានសមត្ថភាពគឺមានលក្ខណៈប្លែកជាងគេ។ បញ្ហាប្រឈមចម្បងគឺជាមួយនឹង*សង្គមស៊ីវិល និងប្រសិទ្ធភាពប្រព័ន្ធផ្សព្វផ្សាយ* ដែលឆ្លុះបញ្ចាំងពីបរិយាកាសមានឧបសគ្គនៅក្នុងវិស័យទាំងនេះ។ មាត្រដ្ឋាននេះមិនត្រូវបានគេរំពឹងថា នឹងមានភាពប្រសើរឡើងយ៉ាងខ្លាំងក្នុងអំឡុងអាយុកាលនៃយុទ្ធសាស្ត្រនោះទេ។ ទោះជាយ៉ាងណាក៏ដោយ គោលបំណងនៃយុទ្ធសាស្ត្រ គឺដើម្បីរក្សាលំហពលរដ្ឋបច្ចុប្បន្ន និងពង្រីកលំហនោះប្រសិនបើអាចធ្វើបាន។ សម្រាប់សមាសធាតុរងមួយចំនួន - រួមទាំងប្រសិទ្ធភាពរបស់រដ្ឋាភិបាល ប្រសិទ្ធភាពប្រព័ន្ធពន្ធដារ គុណភាពអប់រំ គុណភាពសុខភាព និងភាពទំនើបនៃការនាំចេញ - ពិន្ទុគឺនៅជិតមធ្យមភាគសម្រាប់ប្រទេសដែលមានចំណូលទាប និងមធ្យម។ ជាចុងក្រោយវិស័យទាំងពីរនៃកម្លាំងច្បាស់លាស់សម្រាប់កម្ពុជាទាក់ទងនឹងការប្តេជ្ញាចិត្តគឺ*សុវត្ថិភាព និងសន្តិសុខ និងការអនុម័ត ICT* ដោយការអនុម័តនេះ គឺជាឱកាសមួយដែល USAID កំពុងស្វែងរកជាការផ្លាស់ប្តូរនៅក្នុងយុទ្ធសាស្ត្រ។

## ផែនការអន្តរកាលប្រទេស

ទីភ្នាក់ងារ USAID រំពឹងថា អន្តរកាលយុទ្ធសាស្ត្រនិងកម្មវិធីខាងក្រោមនេះ នឹងកើតឡើងនៅក្នុងរយៈពេលពេលវេលានិងកម្រិតខុសៗគ្នាក្នុងអំឡុងពេលអនុវត្តយុទ្ធសាស្ត្រ៖

- ការផ្តោតការយកចិត្តទុកដាក់ថ្មីទៅលើកំណើនសេដ្ឋកិច្ច នឹងដាក់បញ្ចូលការគាំទ្រជីវភាពរស់នៅផ្ទាល់របស់ប្រជាជនដើម្បីកាត់បន្ថយផលប៉ះពាល់បន្ទាប់បន្សំនៃជំងឺកូវីដ-១៩។ សកម្មភាពក្នុងរយៈពេលមធ្យមនេះ នឹងគាំទ្រភាពជាដៃគូ និងវិធីសាស្ត្រដែលកៀរគរមូលធនឯកជន និងពង្រឹងទំនាក់ទំនងពាណិជ្ជកម្មឱ្យកាន់តែស៊ីជម្រៅ និងការចូលទៅកាន់ទៅទីផ្សារអន្តរជាតិ ដោយមិនធ្វើឱ្យបញ្ហាប្រឈមដែលកម្ពុជាជួបប្រទះកាន់តែធ្ងន់ធ្ងរឡើងនៅក្នុងការពង្រីកវិសាលភាពហិរញ្ញវត្ថុរបស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹងភាពជំពាក់បំណុលហួសកម្រិតរបស់ក្រុមគ្រួសារប្រជាជន។[56]

- ការផ្តោតទៅលើបញ្ហាដែលមានលក្ខណៈអន្តរវិស័យថ្មីមួយ ដូចជាការអភិវឌ្ឍសមត្ថភាពការងារ នឹងជួយលើកកម្ពស់ភាពជាដៃគូ ក៏ដូចជាការផ្លាស់ប្តូរទៅវិញទៅមកផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងការផ្តោតលើ ICT ផងដែរ។

- នៅក្នុងទិដ្ឋភាពពហុវិស័យ ដូចជាសុខភាព អប់រំ កសិកម្ម និងបរិស្ថាន ទីភ្នាក់ងារ USAID នឹងធ្វើការតស៊ូមតិយ៉ាងមុតមាំជាមួយនឹងរដ្ឋាភិបាលថ្នាក់ជាតិ តាមរយៈការចូលរួមជាមួយនឹងក្រសួងស្ថាប័នដើម្បីការប្តេជ្ញាចិត្តចំពោះតម្លាភាពនិងគណនេយ្យភាព តាមរយៈគោលនយោបាយនិងការកែទម្រង់អភិបាលកិច្ចដែលកំពុងមានតម្រូវការ។

[56] "កំណត់សម្គាល់គោលនយោបាយមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ," World Bank Group ឆ្នាំ ២០១៩

- តាមរយៈខិតខំប្រឹងប្រែងបំពេញបន្ថែម ដើម្បីពង្រឹងគណនេយ្យភាព និងតម្លាភាពនៅក្នុងរដ្ឋាភិបាល ទីភ្នាក់ងារ USAID នឹងបន្តខិតខំប្រឹងប្រែងពង្រឹងអង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមាននៅក្នុង *អភិបាលកិច្ចបើកចំហនិងមានគណនេយ្យភាព* ដែលកំណត់នៅក្នុងផែនទីបង្ហាញផ្លូវថ្នាក់ជាតិ។

- ទីភ្នាក់ងារ USAID នឹងបន្តគាំទ្របំណងរបស់ប្រជាជនកម្ពុជា តាមរយៈការគាំទ្រភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការដោះស្រាយ គ្រប់គ្រង និងផ្តល់មូលនិធិដល់ការអភិវឌ្ឍរបស់ប្រទេសកម្ពុជា និង

- តាមរយៈគំនិតផ្តួចផ្តើមភាពជាដៃគូថ្មី ទីភ្នាក់ងារ USAID នឹងបន្តធ្វើការយ៉ាងជិតស្និតជាមួយនឹងអង្គការក្នុងស្រុកដើម្បីរួមគ្នាបង្កើតសកម្មភាពថ្មីៗ ដើម្បីពង្រឹងគំរូការអភិវឌ្ឍដែលដឹកនាំដោយខ្លួនឯង និងជាម្ចាស់ផ្ទាល់ខ្លួន ដែលដាក់បញ្ចូលតួអង្គក្នុងស្រុកឱ្យនាំមុខគេក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ពួកគេ។

## វិធីសាស្ត្រយុទ្ធសាស្ត្រ

ចំណុចផ្តោតជាយុទ្ធសាស្ត្ររបស់ទីភ្នាក់ងារ USAID គឺបានបន្សុីជាមួយនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី IV របស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីជំរុញ J2SR របស់កម្ពុជាតាមរយៈការអភិវឌ្ឍប្រកបដោយចីរភាព និងពង្រឹងអធិបតេយ្យភាព។ យុទ្ធសាស្ត្រមានបំណងកំណត់ឡើងវិញនូវទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល វិស័យឯកជន និងអង្គការក្នុងស្រុក ដើម្បីពង្រីកការរីកចម្រើនផ្នែកសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងចីរភាព ពង្រឹងវិស័យសុខាភិបាល អប់រំ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា តាមរយៈការពង្រឹងសេវា និងការពារសិទ្ធិមនុស្ស និងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋាភិបាល។ រូបភាពទី ២ សង្ខេបអំពីគោលបំណងអភិវឌ្ឍន៍កម្រិតខ្ពស់ និងគោលដៅនៃវិធីសាស្ត្រយុទ្ធសាស្ត្រថ្មី។

### រូបភាពទី ២៖ វិធីសាស្ត្រយុទ្ធសាស្ត្រ

| គោលដៅ៖ ប្រទេសកម្ពុជា ក្លាយជាដៃគូកាន់តែបើកចំហ មានវិបុលភាព ភាពធន់ និងបរិយាបន្ននៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក | | |
|---|---|---|
| គោលបំណងអភិវឌ្ឍន៍ទី ១៖ ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព | គោលបំណងអភិវឌ្ឍន៍ទី ២៖ កែលម្អសុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា | គោលបំណងអភិវឌ្ឍន៍ទី ៣៖ ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល |

គោលបំណងអភិវឌ្ឍន៍របស់ទីភ្នាក់ងារ USAID គឺមានភាពចាំបាច់ក្នុងការសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រទេស (CDCS) និងស្របតាមចំណុចអាទិភាពអភិវឌ្ឍន៍នៅក្នុងផែនការយុទ្ធសាស្ត្រប្រកបដោយចីរភាពដំណាក់កាលទី IV របស់រដ្ឋាភិបាល។ CDCS ថ្មីក៏នឹងរក្សាការប្តេជ្ញាចិត្ត

ក្នុងការគោរពតាមសិទ្ធិមនុស្ស និងនីតិរដ្ឋ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។ ស្របតាមទិដ្ឋភាពតូចៗនៃផែនទីបង្ហាញផ្លូវថ្នាក់ជាតិ ទីភ្នាក់ងារ USAID នឹងគាំទ្រគោលនយោបាយសេដ្ឋកិច្ចកាន់តែល្អប្រសើរ ពង្រឹងសមត្ថភាពសេដ្ឋកិច្ច ជំរុញកំណើនសេដ្ឋកិច្ច ព្រមទាំងពង្រឹងការគ្រប់គ្រងធនធានធម្មជាតិតាមរយៈគោលបំណងអភិវឌ្ឍន៍ទី ១៖ <u>ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព</u>។ ទីភ្នាក់ងារ USAID នឹងពង្រឹងសមត្ថភាពប្រជាជន តាមរយៈសមាសធាតុសុខភាព អប់រំ និងការការពារកុមាររបស់គោលបំណងអភិវឌ្ឍន៍ទី ២៖ <u>កែលម្អសុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា</u> និងសមាសធាតុជីវភាពរស់នៅរបស់គោលបំណងអភិវឌ្ឍន៍ទី ១។ គោលបំណងអភិវឌ្ឍន៍ទី ២ ក៏នឹងគាំទ្រការពឹងផ្អែកលើស្វ័យហិរញ្ញប្បទាន តាមរយៈការផ្តោតលើការពង្រឹងប្រព័ន្ធសុខាភិបាល និងអប់រំ។ ទីភ្នាក់ងារ USAID នឹងពង្រឹងប្រព័ន្ធប្រជាធិបតេយ្យ ធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចប្រកបដោយទំនួលខុសត្រូវ និងភាពបើកចំហ លើកកម្ពស់ប្រសិទ្ធភាពរបស់រដ្ឋាភិបាល កសាងសមត្ថភាពសង្គមស៊ីវិល និងពង្រឹងការការពារសិទ្ធិមនុស្ស រួមមានការប្រឆាំងការជួញដូរមនុស្ស តាមរយៈគោលបំណងអភិវឌ្ឍន៍ទី ៣៖ <u>ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល</u>។

សូមមើលតារាងទី ២ សេចក្តីសង្ខេបអំពីរបៀបដែលក្របខ័ណ្ឌលទ្ធផល USAID មានភាពសមស្របទៅនឹងចំណុចអាទិភាពរបស់ទីភ្នាក់ងារទាំងមូល រួមមានគោលចំណុចអាទិភាពសំខាន់ៗសម្រាប់តំបន់ឥណ្ឌូប៉ាស៊ីហ្វិក, J2SR, និងចំណុចអាទិភាពយុទ្ធសាស្រ្តរាជរដ្ឋាភិបាលកម្ពុជា។

**តារាងទី ២៖ ការបន្ស៊ីគោលបំណងអភិវឌ្ឍន៍របស់ទីភ្នាក់ងារ USAID ជាមួយនឹងគោលនយោបាយកម្រិតខ្ពស់របស់រដ្ឋាភិបាលអាមេរិក និង USAID និងចំណុចអាទិភាពរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ**

| គោលបំណងអភិវឌ្ឍន៍ CDCS | ទិដ្ឋភាពរង J2SR | ចំណុចអាទិភាពសំខាន់៖ តំបន់ឥណ្ឌូប៉ាស៊ីហ្វិក | ការបន្ស៊ីជាមួយ RS-IV នៃរដ្ឋាភិបាលកម្ពុជា |
|---|---|---|---|
| គោលបំណងអភិវឌ្ឍន៍ទី ១៖ ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព | *ការប្តេជ្ញាចិត្ត*<br>• ការអភិវឌ្ឍប្រកបដោយបរិយាបន្ន<br>• គោលនយោបាយសេដ្ឋកិច្ច<br><br>*សមត្ថភាព*<br>• សមត្ថភាពរដ្ឋាភិបាល<br>• សមត្ថភាពពលរដ្ឋ<br>• សមត្ថភាពសង្គមស៊ីវិល<br>• សមត្ថភាពសេដ្ឋកិច្ច | • អភិបាលកិច្ច<br>• សេដ្ឋកិច្ច៖ ពាណិជ្ជកម្ម និងភាពប្រកួតប្រជែង<br>• សន្តិសុខ៖ ការគាំពារនិងរក្សាធនធានធម្មជាតិ | *ចំណុចអាទិភាពបរិយាកាសស្នូល*<br>• ការពង្រឹងអភិបាលកិច្ចវិស័យឯកជន<br>• ការពង្រឹងប្រសិទ្ធភាពការងារ<br><br>*ចំណុចអាទិភាពបរិយាកាសគ្រប់ជ្រុងជ្រោយ*<br>• បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច វិនិយោគ និងការអភិវឌ្ឍន៍<br><br>*យុទ្ធសាស្ត្រចតុកោណ*<br>• ការអភិវឌ្ឍធនធានធម្មជាតិ<br>• ពិពិធកម្មសេដ្ឋកិច្ច<br>• ការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន និងការងារ<br>• ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព |
| គោលបំណងអភិវឌ្ឍន៍ទី ២៖ កែលម្អសុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា | *ការប្តេជ្ញាចិត្ត*<br>• រដ្ឋាភិបាលដែលប្រកបដោយទំនួលខុសត្រូវ និងភាពបើកចំហ<br>• ការអភិវឌ្ឍប្រកបដោយបរិយាបន្ន<br><br>*សមត្ថភាព*<br>• សមត្ថភាពរដ្ឋាភិបាល<br>• សមត្ថភាពសង្គមស៊ីវិល<br>• សមត្ថភាពពលរដ្ឋ | • អភិបាលកិច្ច<br>• សេដ្ឋកិច្ច៖ ពាណិជ្ជកម្ម និងភាពប្រកួតប្រជែង | *ចំណុចអាទិភាពបរិយាកាសស្នូល*<br>• ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ<br><br>*ចំណុចអាទិភាពបរិយាកាសគ្រប់ជ្រុងជ្រោយ*<br>• ការពង្រឹងភាពម្ចាស់ការ និងភាពជាដៃគូក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ<br><br>*យុទ្ធសាស្ត្រចតុកោណ*<br>• ការអភិវឌ្ឍធនធានមនុស្ស<br>• ការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន និងការងារ<br>• ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព |
| គោលបំណងអភិវឌ្ឍន៍ទី ៣៖ ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល | *ការប្តេជ្ញាចិត្ត*<br>• រដ្ឋាភិបាលបើកចំហ និងមានគណនេយ្យភាព<br>• ការអភិវឌ្ឍប្រកបដោយបរិយាបន្ន<br>• គោលនយោបាយសេដ្ឋកិច្ច<br><br>*សមត្ថភាព*<br>• សមត្ថភាពរដ្ឋាភិបាល<br>• សមត្ថភាពសង្គមស៊ីវិល<br>• សមត្ថភាពសេដ្ឋកិច្ច | • អភិបាលកិច្ច | *ចំណុចអាទិភាពបរិយាកាសស្នូល*<br>• ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ<br><br>*ចំណុចអាទិភាពបរិយាកាសគ្រប់ជ្រុងជ្រោយ*<br>• សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ រួមទាំងប្រជាធិបតេយ្យសេរីពហុបក្ស គោរពសិទ្ធិមនុស្ស និងការបោះឆ្នោតដោយសេរី និងយុត្តិធម៌<br><br>*យុទ្ធសាស្ត្រចតុកោណ*<br>• ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព |

**កំណត់ឡើងវិញនូវទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដើម្បីពង្រឹងអភិបាលកិច្ច និងកសាងការប្តេជ្ញាចិត្តចំពោះការពឹងផ្អែកលើខ្លួនឯង។** ទីភ្នាក់ងារ USAID ធ្វើការយ៉ាងជិតស្និតជាមួយនឹងរចនាសម្ព័ន្ធសម្របសម្រួលម្ចាស់ជំនួយរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីអនុវត្ត និងបន្សុំកម្មវិធីជាមួយនឹងចំណុចអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទីភ្នាក់ងារ USAID ក៏មានទំនាក់ទំនងការងារប្រកបដោយកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងស្ថាប័នជាច្រើន និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ដើម្បីដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្តេជ្ញាចិត្ត និងសមត្ថភាព ដូចមានលើកឡើងនៅក្នុងផែនទីបង្ហាញផ្លូវថ្នាក់ជាតិ J2SR ទីភ្នាក់ងារ USAID នឹងគាំទ្រដល់សង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការគាំទ្របំណងប្រាថ្នារបស់ប្រជាជនកម្ពុជា។ សង្គមស៊ីវិលនឹងចូលរួមក្នុងការពង្រឹងការការពាររដ្ឋធម្មនុញ្ញ និងសិទ្ធិស្របច្បាប់ ដោយបំពេញបន្ថែមទៅលើកិច្ចខិតខំប្រឹងប្រែងផ្អែកការទូតដើម្បីពង្រឹងចំណុចអាទិភាពទាំងនេះដោយផ្ទាល់ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ ប្រជាពលរដ្ឋ ក៏នឹងត្រូវចូលរួម ព្រមទាំងគាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការកែលម្អសេវា និងគណនេយ្យភាពរដ្ឋាភិបាល បង្កើនការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ និងការប្រាស្រ័យទាក់ទងជាមួយនឹងថ្នាក់ដឹកនាំរបស់ពួកគេ។ ក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញបន្ថែមដើម្បីលើកកម្ពស់ការពឹងផ្អែកលើខ្លួនឯង ទីភ្នាក់ងារ USAID នឹងកសាងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់សេវាប្រកបដោយគុណភាព និងការពារធនធាននៅក្នុងលក្ខណៈមួយដែលលើកកម្ពស់ភាពម្ចាស់ការ និងមានតម្លាភាព និងគណនេយ្យភាពជូនប្រជាជនកម្ពុជា។

ទីភ្នាក់ងារ USAID នឹងជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាចូលរួមក្នុងការកែទម្រង់ស៊ីជម្រៅក្នុងក្រសួងសំខាន់ៗ នៅពេលដែលមានភាពចាំបាច់និងការប្តេជ្ញាចិត្ត។ ដើម្បីសម្រេចឱ្យបាននូវគោលបំណងអភិវឌ្ឍន៍ទី ១ នេះ យើងចាំបាច់ត្រូវធ្វើការងារជាមួយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធានាឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន លើកកម្ពស់បរិយាកាសអំណោយផលសម្រាប់វិស័យឯកជន និងពង្រឹងការកាពារបរិស្ថាន។ ដើម្បីពង្រឹងគោលបំណងអភិវឌ្ឍន៍ទី ២ USAID នឹងរក្សាទំនាក់ទំនងប្រកបដោយផលិតភាពជាមួយនឹងក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលបានលទ្ធផលយ៉ាងល្អប្រសើរលើការកែទម្រង់គោលនយោបាយ រួមទាំងការធ្វើអន្តរកាលនៃភាពម្ចាស់ការកម្មវិធីហិរញ្ញប្បទានសុខាភិបាលជូនក្រសួងសុខាភិបាល និងការអនុវត្តស្តង់ដារអំណានថ្នាក់ដំបូងដោយក្រសួងអប់រំ យុវជន និងកីឡា។ USAID នឹងធ្វើការងារជាមួយនឹងស្ថាប័នកំណែទម្រង់ និងអ្នកធ្វើគោលនយោបាយសំខាន់ៗនៅតាមក្រសួងនិងភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងអស់ ដើម្បីពង្រឹងគណនេយ្យភាព និងតម្លាភាព និងលើកកម្ពស់ការពឹងផ្អែកលើកខ្លួនឯងផ្នែកហិរញ្ញវត្ថុ និងភាពម្ចាស់ការលើកម្មវិធីសំខាន់ៗនៅក្នុងវិស័យសំខាន់ៗ។ ការលើកកម្ពស់សេដ្ឋកិច្ចនៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ១ នឹងគាំទ្រការពឹងផ្អែកលើខ្លួនឯងផ្នែកហិរញ្ញវត្ថុ តាមរយៈការពង្រីកមូលដ្ឋានពន្ធដារ និងធាតុចេញផ្នែកសេដ្ឋកិច្ច។ កិច្ចខិតខំប្រឹងប្រែងនៃគោលបំណងអភិវឌ្ឍន៍ទី ៣ ក្នុងការលើកកម្ពស់គណនេយ្យភាព គឺត្រូវបានបន្សុំជាមួយនឹងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំ និងគណនេយ្យភាពកាន់តែល្អប្រសើរឡើង។

**ការចូលរួមរបស់វិស័យឯកជនបានគាំទ្រការផ្តល់ដំណោះស្រាយអភិវឌ្ឍន៍នៅគ្រប់គោលបំណងអភិវឌ្ឍន៍ទាំងបី។** វិធីសាស្រ្តក្នុងការដាក់បញ្ចូលវិស័យឯកជនឱ្យចូលរួមរបស់ទីភ្នាក់ងារ USAID នឹងផ្តោតទៅលើការសហការជាមួយនឹងតួអង្គវិស័យឯកជន ដែលចំណាប់អារម្មណ៍និងគុណតម្លៃរបស់តួអង្គទាំងនោះ មានភាពស្របគ្នាទៅនឹងចំណាប់អារម្មណ៍និងគុណតម្លៃរបស់សហរដ្ឋអាមេរិក ក្នុងការបង្កើតឱ្យមានការវិនិយោគទៅក្នុងប្រព័ន្ធនិងទីផ្សារក្នុងស្រុក ដោយតាមរយៈការធ្វើបែបនេះនឹងធ្វើឱ្យពួកគេអាចរក្សាចីរភាពខ្លួនឯង និងពន្លឿនវឌ្ឍនភាពរបស់ប្រទេសកម្ពុជាទៅលើ J2SR។

នៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ១ USAID នឹងបន្តជំរុញឱ្យមានការចូលរួមពីសំណាក់វិស័យឯកជន អមជាមួយនឹងខ្សែច្រវាក់គុណតម្លៃសាកវប្បកម្ម ដើម្បីពង្រឹងប្រព័ន្ធទីផ្សារ និងគាំទ្រដល់ភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន ព្រមទាំងសន្តិសុខស្បៀងអាហារផងដែរ។ ទីភ្នាក់ងារ USAID នឹងបន្តពង្រឹងការចូលរួមរបស់វិស័យឯកជន ដើម្បីពង្រីកជីវភាពរស់នៅប្រកបដោយចីរភាពនិងបរិយាបន្ន (ឧ. អនុផលព្រៃឈើ) និងប្រយុទ្ធប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ និងការប្រែប្រួលអាកាសធាតុ។ ដើម្បីបន្តឆ្ពោះទៅមុខបាន ទីភ្នាក់ងារ USAID នឹងបន្តគាំទ្រពិពិធកម្មកសិកម្មជំរុញទីផ្សារ ដើម្បីលើកកម្ពស់សន្តិសុខស្បៀង កំណើនសេដ្ឋកិច្ច ការបង្កើតការងារ និងឱកាសធ្វើពាណិជ្ជកម្ម ព្រមទាំងពង្រឹងភាពជាដៃគូរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិកឱ្យកាន់តែរឹងមាំ ដើម្បីបង្កើនឱកាសការងារនិងសេដ្ឋកិច្ចសម្រាប់ប្រជាជនកម្ពុជា និង ប្រជាជនអាមេរិក រួមបញ្ចូលទាំង ICT ផងដែរ។ ទីភ្នាក់ងារ USAID ក៏នឹងផ្តល់ការលើកទឹកចិត្តដល់អង្គភាព វិស័យឯកជន ដើម្បីបង្កើត ឬពង្រីកអាជីវកម្មប្រកបដោយចីរភាព ដែលបង្កើតបានជាអត្ថប្រយោជន៍សម្រាប់សហគមន៍ និងអភិរក្សជីវចម្រុះរបស់ប្រទេសកម្ពុជា។

នៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ២ USAID នឹងបន្តជំរុញការធ្វើកំណែទម្រង់នៅក្នុងប្រព័ន្ធសុខាភិបាលកម្ពុជា ដើម្បីអនុញ្ញាតឱ្យមានការចូលរួមពីវិស័យឯកជននៅក្នុងការអភិវឌ្ឍគោលនយោបាយ និងសេចក្តីណែនាំ ការគ្របដណ្តប់សេវា និងការពង្រឹងគុណភាព។ ដោយសារភាគច្រើននៃប្រជាជនកម្ពុជាប្រើប្រាស់សេវាសុខាភិបាលឯកជន ទីភ្នាក់ងារ USAID នឹងគាំទ្រតួអង្គវិស័យឯកជន និងកសាងសមត្ថភាពរបស់ពួកគេក្នុងការផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាពដែលបំពេញបន្ថែមទៅលើប្រព័ន្ធសាធារណៈ ដោយផ្តល់ជូននូវជម្រើសកាន់តែទូលំទូលាយជូនបុគ្គលម្នាក់ៗ។ សម្រាប់វិស័យអប់រំ ទីភ្នាក់ងារ USAID នឹងគៀងគរឱ្យមានការចូលរួមពីតួអង្គវិស័យឯកជន និងភាគីពាក់ព័ន្ធ ដើម្បីគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុវត្តកំណែទម្រង់វិស័យអប់រំសំខាន់ៗដែលចាំបាច់សម្រាប់ចីរភាពរយៈពេលវែងនៃកម្មវិធីអំណានថ្នាក់ដំបូង។ ទីភ្នាក់ងារ USAID ក៏នឹងបញ្ចូលតួអង្គវិស័យឯកជន និងភាគីពាក់ព័ន្ធ ដើម្បីគាំទ្រដោយផ្ទាល់ និងពង្រីកវិសាលភាពកម្មវិធីអំណានថ្នាក់ដំបូង។

នៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ៣ ទីភ្នាក់ងារ USAID នឹងបន្តជំរុញឱ្យមានការចូលរួមពីវិស័យឯកជនរបស់ប្រទេសកម្ពុជា ដើម្បីផ្តល់ភាពអង់អាចដល់សហគ្រិនជាស្រ្តី លើកទឹកចិត្តការចូលរួមរបស់ពលរដ្ឋ និងលើកកម្ពស់សិទ្ធិ ក៏ដូចជាបង្កើតភាពជាដៃគូជាមួយនឹងវិស័យបច្ចេកវិទ្យារបស់ប្រទេសកម្ពុជា ដើម្បីលើក

កម្ពស់គណនេយ្យភាពសង្គម និងតម្លាភាពវិស័យសាធារណៈ។ នៅក្នុងដំណើរការឆ្ពោះទៅមុខ ទីភ្នាក់ងារ USAID នឹងស្វែងរកឱកាសក្នុងការចាប់ដៃគូជាមួយនឹងវិស័យបច្ចេកវិទ្យារបស់ប្រទេសកម្ពុជា ជាមួយនឹងគ្រឹះស្ថានអប់រំថ្នាក់ឧត្តមរបស់សហរដ្ឋអាមេរិកដើម្បីលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។

ឱកាសសម្រាប់ការចូលរួមពីវិស័យឯកជននៅក្រោមគោលបំណងអភិវឌ្ឍន៍នីមួយៗមានរៀបរាប់នៅក្នុងតារាងទី ៣ ខាងក្រោម។

**តារាងទី ៣៖ វិធីសាស្រ្តយុទ្ធសាស្រ្តអំពីការចូលរួមរបស់វិស័យឯកជននៅក្នុងគោលបំណងអភិវឌ្ឍន៍**

| | ឱកាសសម្រាប់ការចូលរួមពីវិស័យឯកជន |
|---|---|
| គោលបំណង អភិវឌ្ឍន៍ទី ១ | • ពិគ្រោះ និងចូលរួមជាមួយក្រុមហ៊ុនវិស័យឯកជននិងស្ថាប័នក្នុងស្រុក ដើម្បីរួមគ្នាបង្កើតសកម្មភាពថ្មី ដែលនឹងផ្តល់ជូនយុវជនកម្ពុជានូវបច្ចេកវិទ្យាព័ត៌មានជំរុញសហគ្រាស ការគិតពិចារណាត្រិះរិះ និងជំនាញទន់ ហើយភ្ជាប់ពួកគេទៅនឹងឱកាសការងារនៅក្នុងសេដ្ឋកិច្ចឌីជីថល។<br>• គាំទ្រការអនុវត្តការវិនិយោគប្រកបដោយចីរភាព និងការលើកកម្ពស់ការអភិវឌ្ឍសហគ្រាស ដែលផ្តល់នូវជម្រើសសំខាន់ៗដោយផ្អែកលើទៅផ្សារ ចំពោះប្រភពចំណូលពីព្រៃឈើ និងសត្វព្រៃខុសច្បាប់នៅក្នុងតំបន់ការពារ និងទេសភាពទូលំទូលាយ។<br>• ចាប់ដៃគូជាមួយនឹងវិស័យឯកជននៅក្នុងវិស័យកសិកម្ម នៅលើទិដ្ឋភាពដែលរួមមានយន្តកម្មកសិកម្ម ការដឹកជញ្ជូន ការរក្សាទុកត្រជាក់ និងគំនិតផ្តួចផ្តើមផ្សេងៗដែលនឹងបង្កើតភាពប្រកួតប្រជែងនៃអាជីវកម្មឯកជន ដើម្បីបង្កើតការងារ និងឱកាសការងារឱ្យបានច្រើនជាងមុន។<br>• ធ្វើការងារជាមួយនឹងអ្នកផ្គត់ផ្គង់ធាតុចូល អ្នកប្រមូល អ្នកទិញ អ្នកកែច្នៃ សហគមន៍កសិកម្ម និងតួអង្គប្រព័ន្ធទីផ្សារផ្សេងៗ ដើម្បីបង្កើតសមត្ថភាពការចូលរួមក្នុងទីផ្សារ ការភ្ជាប់ទីផ្សារ និងការវិនិយោគឯកជន |
| គោលបំណង អភិវឌ្ឍន៍ទី ២ | • គៀងគរឲ្យមានការចូលរួម និងពង្រឹងសមាគមវិជ្ជាជីវៈសុខាភិបាល និងសេវាសុខាភិបាលឯកជននៅក្នុងដំណើរការអភិវឌ្ឍគោលនយោបាយ ដើម្បីធានាសុវត្ថិភាព និងគុណភាពនៃសេវាសុខភាពឯកជន។<br>• គាំទ្រតួអង្គវិស័យឯកជន និងកសាងសមត្ថភាពរបស់ពួកគេក្នុងការផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាព ដែលបំពេញបន្ថែមទៅលើប្រព័ន្ធសាធារណៈ ដោយផ្តល់ជូននូវជម្រើសកាន់តែទូលំទូលាយដល់បុគ្គលម្នាក់ៗ<br>• បង្កើនធនធានវិស័យឯកជន នវានុវត្តន៍ និងការវិនិយោគតាមរយៈការរួមបញ្ចូលគ្នានូវវិធីសាស្រ្តហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការផ្តល់សេវាអភិវឌ្ឍន៍កុមារតូចដែលដឹកនាំដោយរដ្ឋាភិបាលប្រកបដោយចីរភាព។<br>• បង្កើនភាពជាដៃគូជាមួយវិស័យសាធារណៈ និងឯកជន ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍និងប្រតិបត្តិនូវគម្រោងអំណានថ្នាក់ដំបូងក្នុងកម្រិតថ្នាក់ជាតិ ពង្រឹងការសិក្សាពីចម្ងាយ និងតាមរយៈប្រព័ន្ធឌីជីថល ព្រមទាំងគាំទ្រសិស្សដែលត្រូវបានកំណត់តាមរយៈដំណើរការត្រួតពិនិត្យបឋម ឲ្យទទួលបានសេវាបញ្ជូនសមស្រប និងការប្រើប្រាស់បច្ចេកវិទ្យាជំនួយ។ |
| គោលបំណង អភិវឌ្ឍន៍ទី ៣ | • ធ្វើការងារជាមួយនឹងសហជីព និងអាជីវកម្ម ជាពិសេសតួអង្គផលិត និងវាយនភ័ណ្ឌ ដើម្បីទប់ទល់នឹងការរំលោភបំពានកន្លែងធ្វើការងារ និងលើកកម្ពស់ការគោរពសិទ្ធិការងារ។<br>• ជួយអាជីវកម្មខ្នាតមីក្រូ និងខ្នាតតូចដែលដឹកនាំដោយស្រ្តី និងមានម្ចាស់អាជីវកម្មជាស្រ្តី ដែល និងកម្មវិធីពន្លឿន។ ចាប់ដៃគូជាមួយនឹងសមាគមអាជីវកម្ម ដើម្បីផ្តល់ការបង្ហាត់បង្ហាញ និងបណ្តុះបណ្តាលការលើកកម្ពស់ការពង្រីកអាជីវកម្មខ្នាតមីក្រូ និងខ្នាតតូច ដែលគ្រប់គ្រងដោយស្រ្តី។<br>• ចាប់ដៃគូជាមួយនឹងក្រុមហ៊ុនបច្ចេកវិទ្យាក្រុមហ៊ុនដើម្បីលើកកម្ពស់គណនេយ្យភាពសង្គម តម្លាភាពវិស័យសាធារណៈ និងការផ្តល់ភាពអង់អាចនៃប្រព័ន្ធឌីជីថល។ |

**CDCS គាំទ្រ FSR ជាការបំពេញបន្ថែមទៅលើការចូលរួមរបស់វិស័យឯកជន (PSE)។** ការគាំទ្រនេះ គឺជាការគាំទ្រដោយផ្ទាល់និងដោយប្រយោល តាមរយៈការធ្វើការងារដើម្បីពង្រឹងប្រាក់ចំណូលសាធារណៈ និងធានាថាធនធានសាធារណៈទាំងនេះ គឺត្រូវបានចំណាយលើសេវាដែលផ្តល់អត្ថប្រយោជន៍ជូនប្រជាជនកម្ពុជា នៅក្នុងលក្ខណៈមួយដែលមានគណនេយ្យភាព និងតម្លាភាពក៏ដូចជាការបង្កើតលក្ខខណ្ឌអំណោយផលដែលវិស័យឯកជនអាចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។ វិធីសាស្ត្រដែលមានលក្ខណៈអន្តរវិស័យក្នុងការគៀងគរវិស័យឯកជនឲ្យចូលរួម (PSE) គាំទ្រដោយផ្ទាល់ទៅលើសរសរស្តម្ភ IV ៖ "បរិយាកាសអំណោយផលសម្រាប់ការវិនិយោគឯកជន" នៃក្របខ័ណ្ឌ FSR។[57] កម្មវិធីនៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ១ នឹងខិតខំពង្រឹងបរិយាកាសអាជីវកម្មអំណោយផលតាមរយៈការកែទម្រង់គោលនយោបាយ និងបង្កើតការប្តេជ្ញាចិត្តចំពោះពិពិធកម្មសេដ្ឋកិច្ចកាន់តែធំទៅៗ។ លើសពីនេះទៅទៀត តាមរយៈការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់វិស័យឯកជន និងការលើកទឹកចិត្តឱ្យមានការវិនិយោគផ្ទាល់ពីបរទេសប្រកបដោយភាពចម្រុះ និងចីរភាពនៅក្នុងប្រទេសកម្ពុជា ទីភ្នាក់ងារ USAID នឹងធ្វើការងារដើម្បីពង្រីកធនធានក្នុងស្រុកដែលមានសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់សេវាសង្គមនៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ២ (សរសរស្តម្ភ I៖ "ការកៀរគរប្រាក់ចំណូលក្នុងស្រុក")។ ជាការពិតណាស់ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតផែនការច្បាស់លាស់ ដើម្បីពង្រឹងសេវាប្រកបដោយគុណភាព និងទទួលខុសត្រូវកាន់តែធំសម្រាប់ការប៉ាន់ស្មានអំពីការបង់ប្រាក់ និងគ្រប់គ្រងគម្រោងនានាដែលគាំទ្រដោយទីភ្នាក់ងារ USAID នៅក្នុងវិស័យសុខាភិបាល អប់រំ និងការគាំពារកុមារ។ ដូច្នេះ គោលបំណងអភិវឌ្ឍន៍ទី ២ មានគោលដៅទាញផលចំណេញទៅលើវឌ្ឍនភាពនេះ និងជំរុញឱ្យមានការកៀរគរប្រាក់ចំណូលក្នុងស្រុកកាន់តែធំនៅក្រោមសរសរស្តម្ភទី ១ ដើម្បីផ្តល់ថវិកាដល់សេវាសំខាន់ៗ។ ជាចុងក្រោយ ភាពខ្វះខាតផ្នែកតម្លាភាព និងគណនេយ្យភាពនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ក៏ជាបញ្ហាប្រឈមចម្បង ហើយដូច្នេះ ការលើកឡើងអំពីសរសរស្តម្ភទី ៣៖ "តម្លាភាព និងគណនេយ្យភាពហិរញ្ញវត្ថុ" គឺជាដំណើរការទៅវិញទៅមករវាងគោលបំណងអភិវឌ្ឍន៍ទី ១ និងទី ៣។ កំណែទម្រង់គោលនយោបាយបរិយាកាសអំណោយផលសម្រាប់អាជីវកម្មនៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ១ នឹងបំពេញបន្ថែមទៅលើវិធីសាស្ត្រនៅក្នុងគោលបំណងអភិវឌ្ឍន៍ទី ៣ ដើម្បីកសាងសមត្ថភាពរបស់សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីពង្រឹងគណនេយ្យភាពរដ្ឋាភិបាលសម្រាប់ការផ្តល់សេវា និងការតាមដានតម្លាភាពរដ្ឋាភិបាល នៅក្នុងការបង្កើត និងអនុវត្តគោលនយោបាយ រួមទាំងការបង្កើតថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ។

**ភាពគីពាក់ព័ន្ធដែលចូលរួមនៅក្នុងវិស័យឯកជន សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ សហជីពការងារ អង្គការសិទ្ធិជីវ និងតួអង្គផ្សេងទៀត ដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាព។** ការខិតខំប្រឹងប្រែងដើម្បីពង្រឹង និងកសាងតម្លាភាពនិងគណនេយ្យភាព ដែលជាចំណុចអាទិភាពទៅវិញទៅមកនៅក្នុងដំណើរការយុទ្ធសាស្ត្រទាំងមូល នឹងផ្តល់ជូនប្រជាជនកម្ពុជានូវព័ត៌មាន និងមធ្យោបាយដែលពួកគេត្រូវការ ដើម្បីធ្វើការតស៊ូមតិ និងរួមចំណែកដល់ការលើកកម្ពស់សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្នរបស់ប្រទេស។ ការកសាងសម្ព័ន្ធភាគីពាក់ព័ន្ធនៅក្នុងវិស័យនានា រួមមានស្ថាប័នដែលដឹកនាំដោយស្ត្រី និងយុវជន សហជីព

[57] "យុទ្ធសាស្ត្រទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិសម្រាប់ការពឹងផ្អែកលើខ្លួនឯងលើការផ្តល់ហិរញ្ញវត្ថុ" ទីភ្នាក់ងារ USAID, ខែមករា ឆ្នាំ ២០២០

ការងារ អង្គការសិទ្ធិដីធ្លី ហើយតួអង្គផ្សេងៗ ក៏មានភាពសំខាន់នៅក្នុងការសម្រេចឱ្យបាននូវការធ្វើកំណែទម្រង់ ដែលផ្តោតលើការបង្កើនតម្លាភាព និងពង្រឹងគណនេយ្យភាពរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា។ ទីភ្នាក់ងារ USAID នឹងកសាងសមត្ថភាពរបស់ស្ថាប័នកម្ពុជានិងភាគីពាក់ព័ន្ធ ដើម្បីនិយាយនិងដើរតួនាទីជំនួសមុខឱ្យប្រជាពលរដ្ឋ ដែលជាចំណុចដ៏សំខាន់ក្នុងការលើកកម្ពស់ភាពធន់។

**គោលដៅក្នុងការពង្រឹងវិបុលភាព ភាពធន់ និងភាពបើកចំហរនៅក្នុងប្រទេសកម្ពុជា ត្រូវតែផ្តោតទៅលើបរិយាបន្នដើម្បីឱ្យមានប្រសិទ្ធភាព។** ដើម្បីធានាឱ្យមានប្រសិទ្ធភាពអភិវឌ្ឍន៍ទូលំទូលាយ ទីភ្នាក់ងារ USAID នឹងខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយឧបសគ្គចំពោះស្ត្រីនិងយុវជន ដើម្បីផ្តល់ភាពជាអ្នកដឹកនាំ និងការចូលរួមនៅក្នុងដំណើរការគោលនយោបាយសាធារណៈ ស្វែងរកការពង្រឹងសមត្ថភាពក្នុងការចូលរួមប្រកបដោយអត្ថន័យនៅក្នុងវិស័យសេដ្ឋកិច្ច (ទាំងនៅតាមទីតាំងជនបទនិងទីប្រជុំជន) គាំទ្រឱ្យមានការចូលរួមក្នុងការសម្រេចចិត្ត និងភាពជាអ្នកដឹកនាំនៅក្នុងសកម្មភាពដែលគាំទ្រដល់ការអភិរក្សជីវចម្រុះ និងធនធានធម្មជាតិ និងសម្របសម្រួលលទ្ធភាពទទួលបានការអប់រំ និងសេវាសុខាភិបាលដើម្បីអភិវឌ្ឍន៍។ នៅក្នុងការសហការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន និងដៃគូសង្គមស៊ីវិល ទីភ្នាក់ងារ USAID នឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីអនុវត្តគោលនយោបាយសមភាពយេនឌ័រថ្នាក់ជាតិ ហើយប្រសិនបើសមស្រប គាំទ្រដល់ការកសាងសមត្ថភាពក្នុងការធ្វើការងារនេះ។ យុទ្ធសាស្ត្រនេះ នឹងជួយរក្សាការផ្តោតការយកចិត្តទុកដាក់លើសិទ្ធិ និងការចូលរួមរបស់ក្រុមប្រជាជនដែលមិនត្រូវបានគេគិតគូរ រួមទាំងជនជាតិដើមភាគតិច ជនជាតិដើម និងក្រុមសាសនា ជនមានពិការភាព និងសមាជិកសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា។

**ដៃគូអន្តរទីភ្នាក់ងារ និងចំណុចអាទិភាព គឺបំពេញបន្ថែមទៅលើវិធីសាស្ត្រយុទ្ធសាស្ត្ររបស់ទីភ្នាក់ងារ USAID។** ទីភ្នាក់ងារ USAID នឹងបន្តធ្វើការងារយ៉ាងជិតស្និតជាមួយនឹងដៃគូអន្តរទីភ្នាក់ងារ ដើម្បីគាំទ្រដល់គោលដៅបំពេញបន្ថែមនិងគោលបំណង ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រប្រទេសរួមបញ្ចូល (ICS)។ សេចក្តីសង្ខេបអំពីកិច្ចសហការនេះ គឺមានបង្ហាញនៅក្នុងតារាងទី ៤។

**តារាងទី ៤៖ សេចក្តីសង្ខេបអំពីចំណុចអាទិភាពអន្តរទីភ្នាក់ងារ ដៃគូ និងទំនាក់ទំនងជាមួយនឹង CDCS**

| គោលដៅ ICS | ចំណុចអាទិភាព និងដៃគូអន្តរទីភ្នាក់ងារ | ទំនាក់ទំនង CDCS |
|---|---|---|
| គោលដៅបេសកកម្មទី ១៖ ជំរុញឥទ្ធិពលអាមេរិកតាមរយៈការចូលរួមជាមួយនឹងអ្នកដឹកនាំជំនាន់ក្រោយរបស់កម្ពុជា ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់អនាគតប្រជាធិបតេយ្យនាពេលអនាគត | • គោលបំណងបេសកកម្ម ១.១៖ ផ្តល់ឥទ្ធិពលដល់មេដឹកនាំអនាគតដើម្បីសម្រួចទស្សនាទានរបស់សហរដ្ឋអាមេរិក តាមរយៈការអប់រំ ជំនួយបច្ចេកទេស ការគាំទ្រសង្គមស៊ីវិល យុវជន សហគ្រាស និងស្ត្រី និងបង្កើនយការយល់ដឹងអំពីវប្បធម៌ និងគុណតម្លៃសហរដ្ឋអាមេរិក តាមរយៈការផ្លាស់ប្តូរបទពិសោធន៍។<br>• ដៃគូ៖ ក្រសួងការបរទេសអាមេរិក ការិយាល័យកិច្ចសហប្រតិបត្តិការយោធា អង្គការ Peace Corps | គោលបំណងអភិវឌ្ឍន៍ទី ៣៖ ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល |
| គោលដៅបេសកកម្មទី ២៖ កំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្ម៖ ជំរុញផលប្រយោជន៍អាជីវកម្មអាមេរិក និងកំណើនសេដ្ឋកិច្ចកម្ពុជា | • គោលបំណងបេសកកម្ម ២.១៖ បើកចំហឱកាសថ្មីសម្រាប់អាជីវកម្មសហរដ្ឋអាមេរិក តាមរយៈការលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម និងពិពិធកម្មសេដ្ឋកិច្ចកាន់តែប្រសើរ តាមរយៈការបង្កើនពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី និងការសម្របសម្រួលការធ្វើដំណើរស្របច្បាប់ទៅកាន់សហរដ្ឋអាមេរិក<br>• គោលបំណងបេសកកម្ម ២.២៖ ធ្វើឱ្យល្អប្រសើរនូវបរិយាកាសបទប្បញ្ញត្តិ ការងារ និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា លើកកម្ពស់តម្លាភាព និងផ្តល់លទ្ធភាពល្អប្រសើរលើការនាំចេញទៅកាន់សហរដ្ឋអាមេរិក និងលើកកម្ពស់ភាពជាសហគ្រិន។<br>• ដៃគូ៖ ក្រសួងការបរទេសអាមេរិក ក្រសួងយុត្តិធម៌ សេវាកសិកម្មការបរទេស សេវាពាណិជ្ជកម្មការបរទេស | គោលបំណងអភិវឌ្ឍន៍ទី ១៖ ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព |
| គោលដៅបេសកកម្មទី ៣៖ រក្សាសន្តិភាព និងសន្តិសុខ និងការពារបូរណភាពទឹកដី | • គោលបំណងបេសកកម្ម ៣.១៖ ពង្រឹងភាពឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងគ្រោះធម្មជាតិនិងកត្តាគំរាមកំហែងសន្តិសុខសុខាភិបាល<br>• ដៃគូ៖ នាយកដ្ឋានប្រយុទ្ធប្រឆាំងជម្ងឺឆ្លង CDC អង្គភាពស្រាវជ្រាវវេជ្ជសាស្ត្រ Unit Two វិទ្យាស្ថានជាតិសុខភាពសាធារណៈ ទីភ្នាក់ងារផ្តល់សេវាត្រួតពិនិត្យសុខភាពរុក្ខជាតិ និងសត្វរបស់នាយកដ្ឋានកសិកម្មរបស់សហរដ្ឋអាមេរិច។ | គោលបំណងអភិវឌ្ឍន៍ទី ២៖ កែលម្អសុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា |

**ការគាំទ្រកម្ពុជាដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (TIP)។** ទោះបីជាកំពុងជួបប្រទះបញ្ហាជាបន្តបន្ទាប់ក្នុងការបង្ការ TIP ស្ថានទូតអាមេរិកបានបង្កើតនូវកិច្ចខិតខំប្រឹងប្រែងបេសកម្មជារួម ដើម្បីជំរុញឱ្យអាជ្ញាធរចូលរួមក្នុងការអនុម័ត និងអនុវត្តអនុសាសន៍របាយការណ៍ TIP ឆ្នាំ ២០២០ ដោយចាត់វិធានការចាំបាច់ក្នុងការចៀសវាងការធ្លាក់ចុះចំណាត់ថ្នាក់មក Tier 3 និងការរឹតត្បិតលើជំនួយបរទេសដែលជាលទ្ធផល។ ការឆ្លើយតបរាជរដ្ឋាភិបាលកម្ពុជា មានភាពជោគជ័យ។ សម្រាប់រយៈពេលប៉ុន្មានឆ្នាំដំបូងនេះ ក្រសួងយុត្តិធម៌ កំពុងផ្តល់ទិន្នន័យអំពីការស៊ើបអង្កេតការជួញដូរ ការកាត់ទោស និងការចោទប្រកាន់សម្រាប់រយៈពេលពាក់កណ្តាលឆ្នាំ ២០២០ ដែលជាការស្នើសុំខ្ពស់បំផុតនៅក្នុងរបាយការណ៍ TIP។ រាជរដ្ឋាភិបាលកម្ពុជា កាន់តែមានឆន្ទៈជាងមុនក្នុងការទទួលស្គាល់អំពីចំណុចខ្វះខាតនៅក្នុងយុទ្ធសាស្ត្រទប់ស្កាត់ការជួញដូរ និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបំពេញទៅតាមអនុសាសន៍ផ្សេងៗនៅក្នុងរបាយការណ៍។ ព័ត៌មានលម្អិតបន្ថែមអំពីវិធីសាស្ត្រក្នុងការដោះស្រាយ TIP របស់ទីភ្នាក់ងារ USAID អាចរកបាននៅក្រោមផ្នែកសេចក្តីសង្ខេបសម្រាប់គោលដៅអភិវឌ្ឍន៍គោលបំណងអភិវឌ្ឍន៍ទី ៣។

## ការរៀបចំផែនការសេណារីយ៉ូ

បញ្ហាប្រឈមដ៏លំបាកមួយក្នុងចំណោមបញ្ហាផ្សេងៗដែលទីភ្នាក់ងារ USAID ជួបប្រទះក្នុងអំឡុងពេលអនុវត្តកម្មវិធី គឺការបន្តដាក់សម្ពាធលើធនធានធម្មជាតិ ពោលគឺព្រៃឈើ និងកង្វះខាតរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិប្រកបដោយសង្គតិភាពលើការគ្រប់គ្រងលើតំបន់ការពារ ដើម្បីបង្ការការកាប់ព្រៃឈើខុសច្បាប់។ សង្គមស៊ីវិលបានរាយការណ៍អំពីការកើនឡើងនៃសកម្មភាពរបស់រាជរដ្ឋាភិបាលមកលើតួអង្គសង្គមស៊ីវិលនៅក្នុងវិស័យនេះ។[58] ទីភ្នាក់ងារ USAID នឹងស្វែងយល់អំពីសេណារីយ៉ូសក្តានុពល ដែលវិភាគអំពីជម្រើសនិងប្រតិកម្ម ប្រសិនបើគម្រោងកំពុងបន្តក្នុងការការពារធនធានធម្មជាតិប្រកប ដោយចីរភាព តម្លាភាព និងបរិយាបន្នកាន់តែមានការលំបាកជាមុន។

## ក្របខ័ណ្ឌលទ្ធផល

### គោលដៅ៖ ប្រទេសកម្ពុជា ក្លាយជាដៃគូកាន់តែបើកចំហ មានវិបុលភាព ភាពធន់ និងបរិយាបន្ននៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក

គោលដៅរបស់ទីភ្នាក់ងារ USAID គឺដើម្បីគាំទ្រប្រទេសកម្ពុជាក្លាយជាដៃគូកាន់តែបើកចំហ មានវិបុលភាព មានភាពធន់និងបរិយាបន្ននៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក និងធានាថាប្រជាជនកម្ពុជាមានសមត្ថភាពក្នុងការខិតខំប្រឹងប្រែង ទោះបីជាមានភាពមិនច្បាស់លាស់ និងវិបត្តិពាក់ព័ន្ធនឹងសេដ្ឋកិច្ច នយោបាយ និងកត្តាសង្គម។ ការសម្រេចបាននូវគោលដៅនេះ តម្រូវឱ្យមានមានសេដ្ឋកិច្ចបរិយាបន្ននិងទូលំទូលាយ ពង្រឹងការទទួលបានសេវាសុភាពប្រកបដោយគុណភាព អប់រំនិងសេវាគាំពារ និងតម្លាភាព គណនេយ្យភាព និងការឆ្លើយតបបានល្អប្រសើររបស់រាជរដ្ឋាភិបាលចំពោះប្រជាជនកម្ពុជា ដោយពង្រឹងភាពពឹងពាក់លើខ្លួនឯងរបស់ប្រទេស។ តាមរយៈការផ្តោតលើបរិយាបន្ន[59] ទីភ្នាក់ងារ USAID ខិតខំធានាឱ្យបានថាប្រជាជនកម្ពុជាចូលរួមរួមចំណែក និងទទួលបានអត្ថប្រយោជន៍ពីការស្តារសេដ្ឋកិច្ចប្រទេស និងវឌ្ឍនភាពសេដ្ឋកិច្ចនាពេលអនាគតថែមទាំងអនុវត្តសេរីភាពដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ បញ្ហាប្រឈមចម្បងក្នុងការសម្រេចគោលដៅនេះ រួមមានផលប៉ះពាល់ពីជំងឺកូវីដ-១៩ បញ្ហាសិទ្ធិមនុស្ស រួមបញ្ចូលទាំង GBV វិសមភាពសង្គម និងសេដ្ឋកិច្ចកម្រិតខ្ពស់ ការគំរាមកំហែងជាបន្តបន្ទាប់លើតំបន់ព្រៃត្រូពិក ធនធានទឹក និងជីវៈចម្រុះ រួមទាំងផលប៉ះពាល់លើការប្រែប្រួលអាកាសធាតុ និងវដ្តរយៈពេលវែងរាប់ទស្សវត្សរ៍នៃភាពបើកចំហ និងការរឹតត្បិតលំហពលរដ្ឋ។ ដើម្បីពង្រឹងភាពធន់នៅក្នុងប្រទេសកម្ពុជា ទីភ្នាក់ងារ USAID នឹងបន្តពង្រឹងសន្តិសុខស្បៀងអាហារពិពិធនកម្មសេដ្ឋកិច្ច ការពារសិទ្ធិមនុស្ស បង្កើនតម្លាភាពប្រព័ន្ធសេដ្ឋកិច្ច កែលម្អគណនេយ្យភាពរដ្ឋាភិបាល និងការទទួលបានប្រកបដោយបរិយាបន្ននូវសេវាសុខាភិបាល អប់រំ និងសេដ្ឋកិច្ច សម្រាប់ប្រជាពលរដ្ឋ តាមរយៈវិស័យសាធារណៈ និងឯកជន។ បន្ថែមពីនេះ នៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខនេះ ទីភ្នាក់ងារ USAID នឹងលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសង្គមនៅគ្រប់វិស័យទាំងអស់ជាលក្ខណៈប្រព័ន្ធ។ ប្រទេស

[58] "ប្រទេសកម្ពុជា៖ យុវជនត្រូវបានកំណត់ជាមុខសញ្ញានៅក្នុង វិបត្តិ" នៃការចាប់ខ្លួនយ៉ាងច្រើន"" អង្គការលើកលែងទោសអន្តរជាតិ ថ្ងៃទី១០ខែកញ្ញា ២០២០

[59] តាមរយៈពាក្យថាបរិយាបន្ន ទីភ្នាក់ងារ USAID ចង់មានន័យថាបរិយាបន្នស្ត្រី យុវជន ក្រុមដែលមិនត្រូវបានគេគិតគូ និងក្រុមងាយរងគ្រោះ។ ក្រុមទាំងនេះ រួមមានជនជាតិដើមភាគតិច សហគមន៍ LGBTI ក្រុមជនជាតិ និងសាសនា និងជនមានពិការភាព។ ន័យនេះ ក៏រាប់បញ្ចូលអ្នកដែលមិនទទួលបានអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជារហូតមកដល់ចំណុចនេះផងដែរ ឧ. ប្រជាជនក្រីក្រ និងអ្នកដែលរស់នៅតាមទីជនបទ ដែលមិនទទួលបានសេវាសារវន្ត និងឱកាសសេដ្ឋកិច្ច។ .

នេះ បានបោះជំហានយ៉ាងសំខាន់ក្នុងការគ្រប់គ្រងជំងឺឆ្លង ដោយក្នុងនោះរួមមានទាំងជំងឺគ្រុនចាញ់ និងមេរោគអេដស៍/ជំងឺអេដស៍ផងដែរ និងលើកកម្ពស់សុខភាពមាតានិងទារក។ ឱកាសដែលមានសម្រាប់ការរក្សាកំណើនដ៏គួរឱ្យកត់សម្គាល់និងការស្តារវឌ្ឍនភាពសេដ្ឋកិច្ចនេះ ខណៈកាត់បន្ថយការដើរថយក្រោយ តាមរយៈការផ្តោតលើឱកាសដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យជាច្រើន ដូចជាវិស័យអប់រំ សុខភាព កសិកម្ម និងបរិស្ថាន។ កិច្ចខិតខំប្រឹងប្រែងពង្រឹងបន្ថែម និងកសាងតម្លាភាពនិងគណនេយ្យភាព ដែលជាចំណុចអាទិភាពទៅវិញទៅមកនៅក្នុងវិស័យទាំងនេះ នឹងជួយកសាងភាពធន់របស់ប្រជាជនកម្ពុជា និងជំរុញឱ្យបុគ្គលម្នាក់ៗរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិ្ចច ការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការសាធារណៈ និងតស៊ូមតិសម្រាប់សិទ្ធិស្របតាមរដ្ឋធម្មនុញ្ញ។ ការផ្តល់ភាពអំណាចដល់ស្ថាប័នកម្ពុជាក្នុងការនិយាយ និងដើរតួនាទីជំនួសឱ្យប្រជាជន គឺជាគន្លឹះដ៏សំខាន់នៅក្នុងការសម្រេចឱ្យបាននូវគោលដៅនេះ។

## គោលបំណងអភិវឌ្ឍន៍ទី ១៖ ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព

ទោះបីជាអត្រាកំណើន ផ.ស.ស. ប្រចាំឆ្នាំជាមធ្យមចំនួនប្រាំពីរភាគរយនៅក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ សេដ្ឋកិច្ចកម្ពុជានៅពឹងផ្អែកជាខ្លាំងទៅលើការវិនិយោគផ្ទាល់ពីបរទេស ដែលមិនអាចមាននិរន្តរភាព និងកង្វះនូវពិពិធកម្ម និងភាពធន់នៅឡើយ។[60] សេដ្ឋកិច្ចប្រទេសកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យទេសចរណ៍ និងការផលិតខ្នាតតូច ដែលភ្ជាប់ទៅនឹងវិស័យខ្សែប្រវាក់ផ្គត់ផ្គង់ក្នុងតំបន់នានា ដែលបានដួលរលំដោយសារតែជំងឺកូវីដ-១៩។ ជាលទ្ធផល ប្រទេសកម្ពុជាត្រូវបានរំពឹងថានឹងមានកំណើនអវិជ្ជមានក្នុងឆ្នាំដំបូង ដែលមិនធ្លាប់មានចាប់តាំងពីឆ្នាំ១៩៩៤ មក។ អត្រាកម្រិតមធ្យមនៅក្នុងអនុវិស័យគោលនយោបាយសេដ្ឋកិច្ចចេញពីផែនទីបង្ហាញផ្លូវថ្នាក់ជាតិ J2SR បានឆ្លុះបញ្ចាំងពីភាពខ្វះខាតនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជំរុញឱ្យមានបរិយាកាសអំណោយផលសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព ជាពិសេសសម្រាប់កំណើនដែលដឹកនាំដោយវិស័យឯកជន ជីវភាពរស់នៅប្រកបដោយចីរភាព និងវិស័យកសិកម្មបែបទំនើប។[61] លើសពីនេះទៅទៀត កំណើនសេដ្ឋកិច្ចនៅក្នុងរយៈពេលមួយទស្សវត្សរ៍ចុងក្រោយនេះ គឺមិនបានផ្តល់អត្ថប្រយោជន៍ស្មើៗគ្នាដល់ប្រជាជនទាំងអស់នោះទេ ពោលគឺ ដូចមានបង្ហាញជូនដោយចំណាត់ថ្នាក់ពិន្ទុមធ្យមសម្រាប់អនុវិស័យការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចំណាត់ថ្នាក់កម្រិតទាប ពោលគឺ ១២១ លើ ១៥៧ សម្រាប់សន្ទស្សន៍នៃការប្តេជ្ញាចិត្តកាត់បន្ថយវិសមភាព។[62] ភាពមិនស្មើគ្នាផ្នែកសេដ្ឋកិច្ច អមជាមួយនឹងបន្ទាត់យេនឌ័រ គឺជាចំណុចដ៏សំខាន់ផងដែរ ហើយទោះបីជាការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ចមានកម្រិតខ្ពស់ក្តី ក៏ប្រទេសកម្ពុជានៅតែទទួលបានពិន្ទុខ្ពស់ពាក់ព័ន្ធនឹងអនុវិស័យគម្លាតសេដ្ឋកិច្ចយេនឌ័រ - ស្ត្រីអាចរកប្រាក់បានជាមធ្យម ៨០% នៃប្រាក់ចំណូលបុរស មានការកាន់កាប់ដីធ្លីតិចតួច មានលទ្ធភាពទទួលបានហិរញ្ញវត្ថុតិចតួចជាង ព្រមទាំងបន្តទទួលបន្ទុកការងារផ្ទះដែលគ្មានប្រាក់កម្រៃ ក្នុងចំណោមវិសមភាពជាប់ជាប្រចាំជាច្រើនផ្សេងទៀត។[63]

---

[60] "ទស្សនាទាននៃការអភិវឌ្ឍន៍អាស៊ីឆ្នាំ ២០២០៖ សុខុមាលភាពនៅក្នុងពេលមានវិបត្តិ" ធនាគារអភិវឌ្ឍន៍អាស៊ី ខែកញ្ញា ឆ្នាំ ២០២០

[61] ការវិភាគបែបវាស់វែងបន្ទាប់បន្សំ បានបង្ហាញអំពីពិន្ទុការធ្វើធុរកិច្ចរបស់ប្រទេសកម្ពុជាឆ្នាំ២០១៨ ដោយទទួលបានពិន្ទុ ៥២ លើ ១០០ (ធនាគារពិភពលោក) និងភាពអំណោយផលផ្នែកធុរកិច្ចនៃពិន្ទុកសិកម្មទទួលបាន ៣៩.៥ លើ ១០០។ ប្រភព៖ទិន្នន័យធនាគារពិភពលោក។

[62] "ការប្តេជ្ញាចិត្តកាត់បន្ថយសន្ទស្សន៍វិសមភាពឆ្នាំ2018," អង្គការអុកស្វាមអន្តរជាតិ ថ្ងៃទី៨ ខែតុលា ឆ្នាំ ២០១៨

[63] "របាយការណ៍វិភាគទិន្នន័យវិស័យ CDCS៖ យេនឌ័រ និងការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន" USAID/ឥទ្ធិពលសង្គម ឆ្នាំ ២០២០

ចន្លោះប្រហោងក៏នៅមានសម្រាប់ការការពារបរិស្ថានផងដែរ។ ប្រទេសកម្ពុជាទទួលបានពិន្ទុខ្ពស់ក្នុងការកាប់បំផ្លាញព្រៃឈើនៅលើពិភពលោក។ ចាប់តាំងពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០១៩ ប្រទេសកម្ពុជាបានបាត់បង់គម្របព្រៃឈើប្រមាណ ២,៣១លានហិចតា ដែលស្មើនឹងការធ្លាក់ចុះ ២៦% ចាប់តាំងពីឆ្នាំ ២០០០ មក ដែលនាំឱ្យមានការបំភាយ ឧស្ម័នកាបូនិចបន្ថែមប្រមាណ973 តោនបន្ថែមទៀត។[64] ការកាប់បំផ្លាញព្រៃឈើនេះ គឺបានកើតមានឡើងដោយសារតែកត្តាសេដ្ឋកិច្ច[65] ដែលបង្ហាញអំពីកំហុសនៃតម្រូវការសម្រាប់ការរស់នៅប្រកបដោយចីរភាពសម្រាប់សហគមន៍ ដែលពឹងផ្អែកលើព្រៃឈើ។ បញ្ហាប្រឈមដ៏សំខាន់នេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងពិន្ទុទាបរបស់ប្រទេសកម្ពុជាសម្រាប់អនុវិស័យគោលនយោបាយបរិស្ថាន។ ប្រព័ន្ធអេកូឡូស៊ីចម្រុះនៅក្នុងប្រទេសកម្ពុជា អាចនឹងទទួលរងនូវការគំរាមកំហែងដោយសារផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ។ ការកើនឡើងនៃសីតុណ្ហភាពនិងគ្រោះរាំងស្ងួតរយៈពេលវែង ត្រូវបានព្យាករណ៍ថានឹងនាំឱ្យមានកំណើនបាត់បង់ជីវចម្រុះ ក៏ដូចជាកំណើនហានិភ័យនៃភ្លើងឆេះព្រៃ។[66]

ជាចុងក្រោយ ផែនទីបង្ហាញផ្លូវថ្នាក់ជាតិ J2SR បង្ហាញថាសមត្ថភាពនៃវិស័យសេដ្ឋកិច្ចគឺស្ថិតនៅក្រោមកម្រិតមធ្យម ដោយឆ្លុះបញ្ចាំងឱ្យឃើញថាទិដ្ឋភាពនៃសមត្ថភាពរបស់កម្ពុជាគ្មានចីរភាព ហើយងាយនឹងរងគ្រោះដោយសារតែវិបត្តិនិងភាពតានតឹង ដូចជាការធ្លាក់ចុះសេដ្ឋកិច្ច គ្រោះធម្មជាតិ ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការផ្លាស់ប្តូរនយោបាយ និងកត្តាផ្សេងៗទៀត។ ជំងឺកូវីដ-១៩ បានបង្ហាញអំពីគុណវិបត្តិនៃការពឹងផ្អែកផ្អែកសេដ្ឋកិច្ចទៅលើវិស័យជ្រើសរើស និងការបែងចែកអត្ថប្រយោជន៍សេដ្ឋកិច្ចមិនស្មើគ្នាក្នុងចំណោមប្រជាជន។ បន្ថែមពីនេះ ខណៈពេលដែលបំណុលរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន គឺមានទំហំ ៣០% នៃ ផសស ហើយខណៈដែលហានិភ័យនៃការលំបាកនៃបំណុលគឺមានកម្រិតទាប បំណុលខាងក្រៅបានធ្វើឱ្យប្រទេសកម្ពុជាប្រឈមនឹងហានិភ័យខ្ពស់ ដោយសារតែការអភិវឌ្ឍសេដ្ឋកិច្ចប្រឈមនឹងវិបត្តិខាងក្រៅដូចជាជំងឺកូវីដ-19 ជាដើម។ លើសពីនេះ ការពឹងផ្អែកលើសលុបលើប្រទេសតែមួយសម្រាប់ការវិនិយោគ និងកំណើនសេដ្ឋកិច្ច នឹងគំរាមកំហែងដល់អធិបតេយ្យភាព ឯករាជ្យភាពសេដ្ឋកិច្ច និងភាពធន់។ ប្រតិបត្តិការដែលមិនមានតម្លាភាព និងមិនមានការដាក់ដេញថ្លៃបែបប្រកួតប្រជែង នឹងកាត់បន្ថយនូវវិនិយោគិនដែលមានចីរភាព ឱ្យចូលមកក្នុងទីផ្សារ។ ឱកាសសម្រាប់ភាពរីកចម្រើនសក្តានុពល ដែលមាននៅក្នុងចំណោមប្រជាជនវ័យក្មេង ទោះបីជាបច្ចុប្បន្ន ពួកគេមិនបានត្រៀមលក្ខណៈរួចរាល់សម្រាប់បញ្ហាប្រឈមផ្អែកសេដ្ឋកិច្ចនាពេលខាងមុខ។[67]អត្រាភាពគ្មានការងារធ្វើរបស់យុវជនជាផ្លូវការគឺមានកម្រិតទាបត្រឹម ១.១ ភាគរយ[68] ប៉ុន្តែចំនួននេះ មិនឆ្លុះបញ្ចាំងអំពីលទ្ធផលរកឃើញនាពេលថ្មីៗនេះ:[69] ដែលបង្ហាញថាយុវជន ៤១ ភាគរយមានការងារធ្វើមិនផ្លូវការ និង ៧៥ ភាគរយ ធ្វើការងារដែលមានប្រាក់ខែទាប។ ការវាយតម្លៃយុវជនរបស់ទីភ្នាក់ងារ USAID និងការពិគ្រោះយោបល់ភាគីពាក់ព័ន្ធមុន CDCS គឺបានជំរុញបន្ថែមលើលទ្ធផលនេះ ដោយ

[64] “សូចនាករបាត់បង់គម្របដើមឈើ,” Global Forest Watch, ២០១៩

[65] “ច្បាប់ស្តីពីជំនួយបរទេស 118/119 ព្រៃត្រូពិច និងការវិភាគជីវៈចម្រុះ” ទីភ្នាក់ងារ USAID ឆ្នាំ ២០១៩

[66] “ការវិភាគការគ្រប់គ្រងហានិភ័យអាកាសធាតុទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា” ទីភ្នាក់ងារ USAID ឆ្នាំ ២០២០

[67] ការវាស់វែងបន្ទាប់បន្សំ “គុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ” ទទួលបានពិន្ទុ 3.7 លើ 7។ ប្រភព៖ វេទិកាសេដ្ឋកិច្ចពិភពលោក។

[68] “សូចនាករអភិវឌ្ឍន៍ពិភពលោក,” ធនាគារពិភពលោក។

[69] “បញ្ហាសំខាន់ៗដែលប៉ះពាល់ដល់យុវជនក្នុងប្រទេសកម្ពុជា” OECD។

បានធ្វើសេចក្តីសន្និដ្ឋានថាយុវជនមានអារម្មណ៍ថា ពួកគេមិនបានត្រៀមលក្ខណៈរួចរាល់ក្នុងការធ្វើការងារ និងមានការលំបាកក្នុងការរក្សាការងារដែលមានប្រាក់ចំណូលល្អប្រសើរ។[70]

ការរក្សានូវអត្រាកំណើនកសិកម្មកម្រិតខ្ពស់ គឺជាចំណុចអាទិភាពទីមួយសម្រាប់រដ្ឋាភិបាលកម្ពុជា។ វិស័យកសិកម្ម នៅតែមានចំណែកធំជាងគេនៅក្នុង ផសស ពាណិជ្ជកម្ម និងកម្លាំងពលកម្ម ហើយវិស័យកសិកម្មរឹងមាំនៅតែជាគន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។ វិស័យកសិកម្ម គឺជាវិស័យដែលងាយរងគ្រោះបំផុតទៅនឹងការកើនឡើងកម្តៅដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលលំនាំទឹកភ្លៀង ក្រៅពីទឹកជំនន់ ផលប៉ះពាល់ពីហេតុការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចជាព្យុះ ការកើនឡើងនៃកម្រិតទឹកសមុទ្រជាដើម។[71] ដើម្បីសម្រេចបានកិច្ចការទាំងនេះ វិស័យកសិកម្មនៃប្រទេសកម្ពុជា ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ចីរភាព ផលិតភាព ភាពប្រកួតប្រជែង និងកំណើនប្រាក់ចំណូល។

ជារួម ការពិគ្រោះយោបល់ភាគីពាក់ព័ន្ធ CDCS ជាមុន និងការពិនិត្យកម្មវិធីផ្ទៃក្នុងបង្ហាញថា យើងត្រូវការដំណោះស្រាយ ដើម្បីពង្រីក និងធ្វើពិពិធកម្មឱកាសសេដ្ឋកិច្ចសម្រាប់ប្រជាជនកម្ពុជា រួមទាំងការពង្រីកការគាំទ្រទៅលើវិស័យសេដ្ឋកិច្ចឱ្យលើសពីវិធីសាស្ត្រដាំដុះបែបប្រពៃណីនៃ CDCS ពីមុនៗ និងការផ្តោតលើការអភិវឌ្ឍកសិធុរកិច្ចផ្អែកលើទីផ្សារ។

*<u>សម្មតិកម្មនៃការអភិវឌ្ឍ</u>*

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ទីភ្នាក់ងារ USAID នឹងកំណត់អាទិភាព “គោលបំណងអភិវឌ្ឍន៍ទី ១៖ ពង្រីកកំណើនសេដ្ឋកិច្ចលក្ខណៈបរិយាបន្ន និងប្រកបដោយចីរភាព” ដែលភ្ជាប់ទៅនឹងគោលដៅ CDCS តាមរយៈការគាំទ្រលក្ខខណ្ឌសេដ្ឋកិច្ចចាំបាច់សម្រាប់ការកើនឡើងនូវវិបុលភាព និងភាពធន់នៅក្នុងប្រទេស និងតាមរយៈការផ្តោតទៅលើបញ្ហាអភិបាលកិច្ចល្អ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ។

សម្មតិកម្មនៃអភិវឌ្ឍន៍គោលបំណងអភិវឌ្ឍន៍ទី១ បញ្ជាក់ថា *ប្រសិនបើ* សេដ្ឋកិច្ចកាន់តែមានភាពចម្រុះ បរិយាកាសអំណោយផលផ្នែកធុរកិច្ច នឹងមានភាពល្អប្រសើរ ហើយធនធានធម្មជាតិ នឹងកាន់តែអាចគ្រប់គ្រងបានប្រកបដោយចីរភាព *នោះ* កំណើនសេដ្ឋកិច្ចកម្ពុជានឹងកាន់តែមានភាពបរិយាបន្ន និងភាពធន់។

វិធីសាស្ត្រអន្តរទំនាក់ទំនង និងអនុវត្តទាំងបីដែលមាននៅក្នុងសម្មតិកម្មការអភិវឌ្ឍគោលបំណងអភិវឌ្ឍន៍ទី ១ នឹងផ្តល់ភាពអង់អាចដល់តួអង្គចម្រុះ ដើម្បីគាំទ្រការស្តារសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាពីជំងឺកូវីដ-១៩ និងការកសាងមូលដ្ឋានគ្រឹះសម្រាប់ភាពរីកមច្រើនប្រកបដោយចីរភាពនិងមានភាពទូលំទូលាយ។ ទីមួយ “ពន្លឿនពិពិធកម្មសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ជីវភាព” លទ្ធផលរំពឹងទុក (IR) ១.១ ផ្តោតទៅលើការធ្វើការងារជាមួយនឹងធុរកិច្ចនិងសហគមន៍ ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការផ្តោតទៅលើវិធីសាស្ត្រផ្អែកលើទីផ្សារនៅក្នុងវិស័យកសិកម្ម ដែលខិតខំប្រឹងប្រែងសម្របសម្រួលការភ្ជាប់ទំនាក់ទំនងរវាងអ្នកផ្គង់ផ្គង់ និងអ្នកទិញក្នុង

[70] ការវាយតម្លៃយុវជនកម្ពុជាឆ្លងវិស័យទីភ្នាក់ងារUSAID/ប្រទេសកម្ពុជា ឆ្នាំ ២០១៩

[71] “ការវិភាគការគ្រប់គ្រងហានិភ័យអាកាសធាតុទីភ្នាក់ងារUSAID/ប្រទេសកម្ពុជា” ទីភ្នាក់ងារ USAID ឆ្នាំ ២០២០

ស្រុកនិងអន្តរជាតិ ក៏ដូចជាការលើកកម្ពស់ការទទួលបានបច្ចេកវិទ្យាកសិកម្មប្រកបដោយប្រសិទ្ធភាពនិងចីរភាពសម្រាប់កសិករ អភិវឌ្ឍន៍សមត្ថភាពរបស់ប្រជាជនកម្ពុជា ជាពិសេសយុវជននិងស្ត្រី ដើម្បីទទួលបានការងារមានប្រាក់បៀវត្សរ៍ល្អ និងការវិនិយោគគោលដៅនៅក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល។[72] ទីពីរ "កែលម្អបរិយាកាសធុរកិច្ច ដើម្បីទាក់ទាញការវិនិយោគ និងបង្កើតការងារ" (IR ២.២) អភិបាលកិច្ចសេដ្ឋកិច្ចគោលដៅ តាមរយៈការពង្រឹងបរិយាកាសអភិបាលកិច្ច សេដ្ឋកិច្ច។ ចំណុចផ្តោតនេះ មានភាពសមស្របទៅនឹងលទ្ធផលរកឃើញរបស់គ្រុបធនាគារពិភពលោក ដែលកែលម្អបរិយាកាសអំណោយផលផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា គឺមានភាពសំខាន់ ដើម្បីគាំទ្រភាពអាសន្ននៃសហគ្រាសដែលមានសក្តានុពលកម្រិតខ្ពស់ ផ្តោតលើភាពរីកចម្រើន និងមានភាពប្រកួតប្រជែងជាសកល។[73] ទីបី "កែលម្អការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងគណនេយ្យភាព" (IR ១.៣) ផ្តោតលើការប្រើប្រាស់ធនធានធម្មជាតិដ៏សម្បូរបែបរបស់ប្រទេសកម្ពុជាប្រកបដោយចីរភាព និងគណនេយ្យភាព ដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់ភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព។ ទីភ្នាក់ងារ USAID សង្ឃឹមថានឹងពង្រីកភាពជាដៃគូជាមួយនឹងវិស័យឯកជន ហើយធ្វើការងារតាមរយៈគំនិតផ្តួចផ្តើមភាពជាដៃគូថ្មីនៅក្នុងការគាំទ្រគោលបំណងអភិវឌ្ឍន៍នេះ។ តារាងទី ៥ សង្ខេបអំពីការប៉ាន់ស្មាននិងហានិភ័យសំខាន់ៗ ដែលបានកំណត់រកឃើញនៅក្នុងការអនុវត្តគោលបំណងអភិវឌ្ឍន៍ទី ១។

**តារាងទី ៥៖ ការប៉ាន់ស្មាន និងហានិភ័យសំខាន់ៗសម្រាប់គោលបំណងអភិវឌ្ឍន៍ទី ១**

| ការប៉ាន់ស្មាន | ហានិភ័យ |
|---|---|
| • ការងើបឡើងវិញនូវសេដ្ឋកិច្ចពិភពលោកពីជំងឺកូវីដ-១៩ ការស្តារតម្រូវការទីផ្សារសម្រាប់ផលិតផលដែលផលិតក្នុងប្រទេសកម្ពុជា និងការស្តារកម្រិតចំណូល<br>• ឱកាសដែលមានដើម្បីជំរុញឱ្យមានការចូលរួមពីអ្នកដឹកនាំដែលមានគំនិតកែទម្រង់ ដើម្បីអនុវត្តច្បាប់ និងធានាឱ្យបាននូវអភិបាលកិច្ចធនធានធម្មជាតិ | • ការងើបឡើងវិញនូវសេដ្ឋកិច្ចពិភពលោកពីជំងឺកូវីដ-១៩ គឺមានភាពយឺតយ៉ាវ និងបន្តប៉ះពាល់ដល់ទេសចរណ៍អន្តរជាតិ និងតម្រូវការផលិតផលដែលផលិតក្នុងប្រទេសកម្ពុជា<br>• ការវិនិយោគ និងការអភិវឌ្ឍពីបរទេសមិនមានចីរភាព ជាពិសេសការវិនិយោគនៅតាមតំបន់មេគង្គ មានសក្តានុពលក្នុងការធ្លាក់ចុះនូវអត្ថប្រយោជន៍សម្រាប់ការអភិរក្ស និងការគំរាមកំហែងជីវភាពរស់នៅ<br>• រាជរដ្ឋាភិបាលកម្ពុជា អាចនឹងរឹតត្បិតសកម្មភាពមួយចំនួនរបស់ក្រុមក្នុងស្រុក អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត ។ |

[72] សារសំខាន់នៃយុទ្ធសាស្ត្រនៃការកែលម្អ និងធ្វើពិពិធកម្មសេដ្ឋកិច្ច ក៏ដូចជាការកសាងកម្លាំងពលកម្មធនធានប្រកបដោយជំនាញ និងមានផលិតភាពដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន គឺត្រូវបានផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់ដោយធនាគារ ADB និងទីភ្នាក់ងារពហុភាគី និងការអភិវឌ្ឍន៍។ ប្រភព៖ ប្រទេសកម្ពុជាឆ្នាំ2019-2023៖ ផ្លូវទៅកាន់សេដ្ឋកិច្ចប្រកួតប្រជែងប្រកបដោយបរិយាបន្ន" ធនាគារ ADB, ឆ្នាំ2019, 12ការធ្វើបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ ការអភិវឌ្ឍន៍ និងទស្សនវិស័យសេដ្ឋកិច្ច " "ថ្មីៗWorld Bank Group, ឆ្នាំ២០១៨

[73] សហគ្រិនភាពប្រទេសកម្ពុជា៖ កំណត់សម្គាល់គោលនយោបាយកម្ពុជា," World Bank Group, ខែកក្កដា ឆ្នាំ ២០១៨

របៀបដែលគោលបំណងអភិវឌ្ឍន៍ទី ១ ជំរុញ J2SR របស់ប្រទេសកម្ពុជា

ការវិភាគលើផែនទីបង្ហាញផ្លូវថ្នាក់ជាតិ J2SR របស់ប្រទេសកម្ពុជា បានបង្ហាញអំពីគម្លាតនៅក្នុងការប្តេជ្ញាចិត្ត របស់រដ្ឋាភិបាលចំពោះការអភិវឌ្ឍប្រកបដោយបរិយាបន្ន និង*គោលនយោបាយសេដ្ឋកិច្ចរឹងមាំជាងមុន រួមទាំងគោលនយោបាយស្តីពីបរិស្ថាន*ដែលមានពិន្ទុទាបជាងគេបំផុតនៅក្នុងផ្នែកអនុវិស័យ។ ខណៈពេលដែលប្រទេសកម្ពុជាមានសមត្ថភាពខ្លះៗហើយនោះ *សមត្ថភាព សេដ្ឋកិច្ច*មិនមានចីរភាព និងងាយរងគ្រោះទៅនឹងវិបត្តិ និងភាពតានតឹងនានា។ ភាពតានតឹងនៃ ជំងឺកូវីដ-១៩ បានបង្ហាញពីភាពពឹងផ្អែកខ្លាំងទៅលើវិស័យជ្រើសរើស និងកង្វះនូវការចូលរួមស្មើភាពគ្នានៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលកន្លងមក។

ការចូលរួមរបស់វិស័យឯកជន គឺជាធាតុផ្សំ និងជាមាត់ FSR ដ៏សំខាន់ដែលស្ថិតក្រោមគោលបំណងអភិវឌ្ឍន៍ន៍នេះ ហើយការចូលរួមនេះ ក៏មានទំនាក់ទំនងយ៉ាងទូលំទូលាយជាមួយគោលបំណងអភិវឌ្ឍន៍ផ្សេងទៀតផងដែរ ជាពិសេសការចូលរួមពីវិស័យឯកជនក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល (គោលបំណងអភិវឌ្ឍន៍ទី ២) និងការបង្កើតតម្រូវការសម្រាប់លើកកម្ពស់តម្លាភាព និងគណនេយ្យភាព (គោលបំណងអភិវឌ្ឍន៍ទី ៣)។ លទ្ធផលនៃ គោលបំណងអភិវឌ្ឍន៍ន៍នេះ គាំទ្រដោយផ្ទាល់ដល់សរសរស្តម្ភទី IV៖ "បរិយាកាសអំណោយផលសម្រាប់ការវិនិយោគឯកជន" របស់ក្របខ័ណ្ឌ FSR។ តាមរយៈការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់វិស័យឯកជន និងការលើកទឹកចិត្តឱ្យមានការវិនិយោគផ្ទាល់ពីបរទេស បែបចម្រុះ និងមានចីរភាព ចូលមកក្នុងប្រទេសកម្ពុជា ទីភ្នាក់ងារ USAID បានខិតខំធ្វើការងារ ដើម្បីពង្រីកធនធានក្នុងស្រុកដែលមាន (សរសរស្តម្ភ I៖ "ការកៀរគរចំណូលក្នុងស្រុក") សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់សេវាសង្គមក្រោមគោលបំណងអភិវឌ្ឍន៍ន៍ទី ២។ ជាពិសេស អនុ IR ១.២.១ គឺផ្តោតលើការចូលរួម និងភាពជាដៃគូជាមួយវិស័យឯកជន ដើម្បីជំរុញឱ្យមានកំណែទម្រង់ ដើម្បីពង្រឹងទីផ្សារ និងពាណិជ្ជកម្ម។ គោលបំណងសុខភាព និងការអប់រំរបស់គោលបំណងអភិវឌ្ឍន៍ន៍ទី ២ ក៏មានសារៈសំខាន់ផងដែរក្នុងការពង្រឹងធនធានមនុស្សដែលចាំបាច់សម្រាប់ចំណុចអាទិភាពនៃការបង្កើតកម្លាំងពលកម្មប្រកបដោយប្រសិទ្ធភាពនៅក្នុងគោលបំណងអភិវឌ្ឍន៍ទី ១។ ជាចុងក្រោយ អភិបាលកិច្ច គឺជាប្រធានបទដែលមានភាពពាក់ព័ន្ធគ្នាទៅវិញទៅមកនៅគ្រប់គោលបំណងអភិវឌ្ឍន៍ន៍ ទាំងបី ហើយ IR ១.២ មានភាពស្របគ្នាទៅគោលបំណងនេះ និងរួមបញ្ចូលគ្នាជាមួយសកម្មភាពប្រកបដោយគណនេយ្យភាព និងតម្លាភាពនៃគោលបំណងអភិវឌ្ឍន៍ទី ៣។

តារាងទី ៦ សង្ខេបពីរបៀបដែលគោលបំណងអភិវឌ្ឍន៍ទី១ នឹងរួមចំណែកទៅនឹងសមាសធាតុ J2SR នីមួយៗ។

**តារាងទី ៦៖ សមាសធាតុ J2SR សម្រាប់គោលបំណងអភិវឌ្ឍន៍ទី ១**

| សមាសធាតុ J2SR | អភិក្រមគោលបំណងអភិវឌ្ឍន៍ទី 1 |
|---|---|
| ការកែលម្អទំនាក់ទំនង | ចូលរួមក្នុងការកែទម្រង់ជាមួយនឹងក្រសួងសំខាន់ៗ ដូចជាក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភាគីខាងក្រៅដូចជាវិស័យឯកជន និងសង្គមស៊ីវិល ដើម្បីតស៊ូមតិឱ្យមានការកែប្រែគោលនយោបាយ/បទប្បញ្ញត្តិសមស្រប ដែលលើកកម្ពស់កំណើនសេដ្ឋកិច្ច និងការពារបរិស្ថាន ដែលការប្តេជ្ញាចិត្តនេះគឺជាមានភាពពិតប្រាកដ។ |
| ការផ្តល់ហិរញ្ញប្បទានប្រកបដោយការជឿជាក់លើខ្លួនឯង | ពង្រឹងបរិយាកាសអំណោយផលសម្រាប់វិស័យឯកជន ដើម្បីលើកទឹកចិត្តឱ្យមានការវិនិយោគឯកជន ដែលកាន់តែមានដំណើរការប្រកបដោយតម្លាភាព អាចបង្កើតលំហូរប្រាក់ចំណូលបានកាន់តែទូលំទូលាយសម្រាប់ការផ្តល់ហិរញ្ញប្បទានសេវារដ្ឋាភិបាលសំខាន់ៗ។ |
| ការចូលរួមពីវិស័យឯកជន | ចាប់ដៃគូជាមួយនឹងក្រុមហ៊ុនកម្ពុជា និងសហរដ្ឋអាមេរិក ដើម្បីពង្រីកភាពជាដៃគូរួមទុន ដើម្បីបង្កើនឱកាសការងារសម្រាប់ប្រជាជនកម្ពុជា និងប្រជាជនអាមេរិក។ បង្កើតភាពជាដៃគូវិស័យឯកជននៅក្នុងវិស័យកសិកម្ម និងបរិស្ថាន។ |
| ការចាប់ដៃគូប្រកបដោយប្រសិទ្ធភាព និងការកែទម្រង់លទ្ធកម្ម | បន្តស្វែងរកឱកាសថ្មីជាមួយនឹងដៃគូមិនមែនប្រពៃណី ដូចជា តាមរយៈកម្មវិធី Development Impact Bond។ ពង្រីក REDD+ និងការលក់ឥណទានកាបូន ដែលផ្តោតលើអាជីវកម្មវិស័យឯកជនធំៗមកពីសហរដ្ឋអាមេរិក និងប្រទេសដែលមានការគិតដូចគ្នា។ |

<u>របៀបដែលគោលបំណងអភិវឌ្ឍន៍ទី ១ ជំរុញឱ្យមានសេរីភាព និងបើកចំហនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក</u>

បច្ចុប្បន្ននេះ កង្វះប្រព័ន្ធដែលមានតម្លាភាព និងគណនេយ្យភាពសម្រាប់ភាពរីកចម្រើននៃវិស័យឯកជន បានរារាំងការវិនិយោគរបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ គោលបំណងអភិវឌ្ឍន៍នេះ នឹងជួយរៀបចំកែសម្រួលចំណុចទាំងនេះ ដើម្បីឱ្យក្រុមហ៊ុនអាមេរិកវិនិយោគនៅក្នុងប្រទេសនេះ លើកកម្ពស់គំនិតផ្តួចផ្តើមតម្លាភាព និងដើរតួនាទីជាអ្នកឆ្លើយតបទៅនឹងសកម្មភាពពាណិជ្ជកម្មមិនមានតម្លាភាព និងការទទួលខុសត្រូវសក្តានុពល ដែលអាចធ្វើឱ្យប៉ះពាល់ដល់ទីផ្សារក្នុងតំបន់ និងរារាំងការវិនិយោគប្រកបដោយចីរភាព។ វិធីសាស្ត្រក្រោមគោលបំណងអភិវឌ្ឍន៍នេះ នឹងធ្វើអោយប្រសើរឡើងនូវបរិយាកាសអំណោយផលផ្នែកធុរកិច្ច ធ្វើការងារដើម្បីកសាងប្រព័ន្ធទីផ្សារដែលមានភាពធន់នឹងការរក្សាអធិបតេយ្យភាពរបស់រដ្ឋកម្ពុជា និងផ្តល់នូវអំណាចនៃការធ្វើពិពិធកម្ម និងភាពរីកចម្រើនដែលដឹកនាំដោយសហគ្រាសឯកជន និងអនុញ្ញាតឱ្យប្រទេសកម្ពុជាបន្តទទួលបានការវិនិយោគសាធារណៈប្រកបដោយគណនេយ្យភាព ដែលផ្តល់នូវគុណតម្លៃដ៏ល្អបំផុត។ ជាចុងក្រោយ ទីភ្នាក់ងារ USAID នឹងធ្វើការកែលម្អការគ្រប់គ្រងធនធានធម្មជាតិ និងពង្រឹងចំណុចផ្តោតសរសរស្តម្ភសន្តិសុខនៃការការពារ និងសន្តិសុខធនធានធម្មជាតិ តាមរយៈការបង្កើនតម្លាភាព និងគណនេយ្យភាពរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីបរិស្ថាន និងការពារទេសភាព និងតំបន់រងទឹកភ្លៀងសំខាន់ៗ ហើយក្នុងពេលជាមួយគ្នានោះ ថែមទាំង ជំរុញសរសរស្តម្ភអភិបាលកិច្ច តាមរយៈការគាំទ្រសង្គមស៊ីវិល ឱ្យចូលរួមត្រួតពិនិត្យរបស់រដ្ឋាភិបាល។

## ចំណុចអាទិភាពរបស់រដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ

គោលបំណងនៃគោលបំណងអភិវឌ្ឍន៍ទី ១ ថ្មីរបស់ទីភ្នាក់ងារ USAID ត្រូវបានបន្សុីយ៉ាងខ្លាំងទៅជាមួយនឹងយុទ្ធសាស្រ្តវិតាមស័យរបស់រាជរដ្ឋាបាលកម្ពុជា ដូចមានបង្ហាញនៅក្នុងតារាងទី ៧ ពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស ពិពិធកម្មសេដ្ឋកិច្ច ការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជននិងការងារ និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព។ វិធីសាស្រ្តថ្មីរបស់ទីភ្នាក់ងារ USAID ចំពោះកំណើនសេដ្ឋកិច្ច នឹងជួយសម្រេចឱ្យបាននូវចំណុចអាទិភាពទាំងនេះ តាមរយៈការលើកកម្ពស់ការស្តារឡើងវិញនូវសេដ្ឋកិច្ចរបស់កម្ពុជាពីជំងឺកូវីដ-១៩ តាមរយៈការលើកកម្ពស់សេដ្ឋកិច្ចចម្រុះ និងមានភាពធន់ ដែលបង្កើនជីវភាពរស់នៅប្រកបដោយចីរភាពសម្រាប់ប្រជាជនកម្ពុជា ។

**តារាងទី ៧៖ ការបន្សុីគោលបំណងអភិវឌ្ឍន៍ទី ១ ជាមួយនឹងយុទ្ធសាស្រ្តកម្រិតវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាសំខាន់ៗ**

| យុទ្ធសាស្រ្តរាជរដ្ឋាភិបាលកម្ពុជាសំខាន់ៗ | ភាពស្របគ្នាទៅនឹងគោលបំណងអភិវឌ្ឍន៍ទី ១ |
|---|---|
| គោលនយោបាយអភិវឌ្ឍន៍វិស័យ | IR ១.១, ១.២ |
| ផែនការអភិវឌ្ឍយុទ្ធសាស្រ្តវិស័យកសិកម្ម | IR ១.១ |
| ផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុប្រទេសកម្ពុជា | IR ១.៣ |

## តួអង្គអភិវឌ្ឍន៍ផ្សេងទៀត

ទីភ្នាក់ងារ USAID នឹងធ្វើការងារនៅក្នុងរចនាសម្ព័ន្ធសម្របសម្រួលជំនួយ ដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមការងារបច្ចេកទេស ជាពិសេសសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ នេសាទ ធនធានទឹក និងការប្រែប្រួលអាកាសធាតុ។ ទីភ្នាក់ងារ USAID នឹងបន្តសម្របសម្រួលជាមួយនឹងម្ចាស់ជំនួយដែលមានគំនិតដូចគ្នា រួមមាន ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប ប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស ជាដើម។ ផ្អែកលើការពិគ្រោះយោបល់ CDCS គ្រប់ជ្រុងជ្រោយ និងការស្ទង់មតិផ្អែកលើប្រជាជន ដើម្បីកំណត់អាទិភាពសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា ការកែលម្អផ្លូវថ្នល់និងហេដ្ឋារចនាសម្ព័ន្ធនានា គឺជាការតម្រូវការសំខាន់។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែមានម្ចាស់ជំនួយ និងអ្នកវិនិយោគផ្សេងទៀតកំពុងចូលរួមចំណែកក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូច្នេះឧត្តមភាពប្រៀបធៀបរបស់ទីភ្នាក់ងារ USAID គឺជាការគាំទ្រការពង្រឹងកិច្ចការពារបរិស្ថាន និងសង្គម ដើម្បីធានាចីរភាពនៃការវិនិយោគទាំងនេះ។ លើសពីនេះ ទីភ្នាក់ងារ USAID មានឧត្តមភាពប្រៀបធៀបក្នុងការគាំទ្រដល់ការពង្រីកឱកាសការងារ និងការលើកកម្ពស់សន្តិសុខស្បៀងនិងទឹក ដែលជាក្តីបារម្ភដ៏សំខាន់សម្រាប់គ្រួសារកម្ពុជាដែលមានចំណូលទាប និងជាសមាសធាតុដ៏សំខាន់ក្នុងការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ភាពធន់ និងកំណើនសេដ្ឋកិច្ចទូលំទូលាយ។

## IR ១.១៖ ពន្លឿនពិពិធកម្មសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ជីវភាព

អនុ-IR ១.១.១៖ ពង្រីកកំណើនវិស័យកសិកម្មផ្អែកលើទីផ្សារ
អនុ-IR ១.១.២៖ ពង្រីកជំនាញការងារពាក់ព័ន្ធទីផ្សារ
អនុ-IR ១.១.៣៖ ពង្រឹងសមត្ថភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់ស្ត្រី និងយុវជន

ដើម្បីពង្រីកវិសាលភាពកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព ជាចាំបាច់ត្រូវពង្រីកវិសាលភាពកំណើនដោយផ្អែកលើទីផ្សារនៅក្នុងវិស័យកសិកម្ម តាមរយៈការកែលម្អពីការអន្តរាគមន៍កម្រិតកសិដ្ឋាន ទៅជាការអន្តរាគមន៍ដែលដឹកនាំដោយវិស័យឯកជនប្រកបដោយគុណតម្លៃបន្ថែម កសាងសមត្ថភាពកម្លាំងពលកម្មកម្ពុជាតាមរយៈការពង្រឹងជំនាញ និងការបណ្តុះបណ្តាលការងារក្នុងវិស័យរីកចម្រើន និងទាញយកសក្តានុពលនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ជាពិសេសសម្រាប់ស្ត្រី និងយុវជន។ ប្រទេសកម្ពុជាមានលក្ខខណ្ឌទីផ្សារអំណោយផលសម្រាប់ការពង្រីកសេដ្ឋកិច្ចឌីជីថល រួមទាំងកម្រិតអក្ខរកម្មឌីជីថលក្នុងចំណោមយុវជន គឺមានកម្រិតខ្ពស់ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ មានតែស្ថាបនិកក្រុមហ៊ុនបច្ចេកវិទ្យាចំនួន ២០ ភាគរយប៉ុណ្ណោះ ដែលជាស្ត្រី ដែលកត្តានេះឆ្លុះបញ្ចាំងឱ្យឃើញអំពីតម្រូវការក្នុងការដោះស្រាយឧបសគ្គដែលស្ត្រីជួបប្រទះនៅក្នុងការអភិវឌ្ឍអាជីពផ្នែកបច្ចេកវិទ្យា។[74]

បញ្ហាប្រឈមធំៗមួយចំនួនដែលប្រទេសកម្ពុជាកំពុងប្រឈមមុខនៅក្នុងផ្លូវឆ្ពោះទៅរកការធ្វើពិពិធកម្មសេដ្ឋកិច្ច រួមមានកង្វះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពធនធានមនុស្សនៅខ្សោយ និងគម្លាតជំនាញ និងការពឹងផ្អែកខ្លាំងទៅលើវិស័យជ្រើសរើសដែលកម្រិតសេដ្ឋកិច្ច និងធ្វើឱ្យប្រទេសនេះប្រឈមទៅនឹងវិបត្តិ និងភាពតានតឹងពីខាងក្រៅ។ លើសពីនេះ អំពើហិង្សាលើយេនឌ័រ និងអាពាហ៍ពិពាហ៍ក្នុងវ័យក្មេងពេក គឺជាបញ្ហាដែលកំពុងរីករាលដាល ដែលចាំបាច់ត្រូវតែដោះស្រាយ ដើម្បីពង្រីកសមិទ្ធិផលអប់រំ និងការចូលរួមកម្លាំងពលកម្មដោយជោគជ័យពីសំណាក់ស្ត្រី និងយុវជន។ រាជរដ្ឋាភិបាលកម្ពុជា កំពុងបន្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់ខ្លួនឆ្នាំ ២០១៥-២០២៥ ដែលផ្តោតលើការបង្កើន និងធ្វើពិពិធកម្មការនាំចេញផលិតផលមិនមែនវាយនភ័ណ្ឌ និងជំរុញការនាំចេញផលិតផលកែច្នៃកសិកម្ម។ IR មានភាពស្របគ្នាទៅនឹងគោលការណ៍នេះ ដោយការបង្កើតជំនាញរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ឱកាសការងារកាន់តែល្អប្រសើរ និងចូលរួមជាមួយវិស័យឯកជន ដើម្បីពង្រីកភាពរីកចម្រើននៃវិស័យកសិកម្មផ្អែកលើទីផ្សារនេះ។ យើងក៏នឹងធ្វើការជាមួយរដ្ឋាភិបាល ដើម្បីពង្រឹងបរិយាកាសធុរកិច្ចអំណោយផលផងដែរ តាមរយៈការកែទម្រង់គោលនយោបាយ និងបង្កើនការប្តេជ្ញាចិត្តឆ្ពោះទៅរកការធ្វើពិពិធកម្មសេដ្ឋកិច្ចបន្ថែមទៀត។ អនុលទ្ធផលអន្តរការីនៅក្រោមលទ្ធផលអន្តរការីនេះ ក៏នឹងរួមចំណែកដល់លទ្ធផលអាហារូបត្ថម្ភ តាមរយៈកំណើនដែលដឹកនាំដោយវិស័យកសិកម្ម និងជីវភាពរស់នៅប្រកបដោយចីរភាព ដែលបន្តការងាររបស់របស់ទីភ្នាក់ងារ USAID លើដំណាំសាកវប្បកម្ម និងអាហារដែលលើកកម្ពស់អាហារូបត្ថម្ភ។ ការងារនេះនឹងមានភាពជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយ និងបំពេញបន្ថែមលើការងារដែលត្រូវធ្វើក្រោម IR

[74] Bora Kem, et. al, "ធុរកិច្ចថ្មីកម្ពុជា៖ ធុរកិច្ចបច្ចេកវិទ្យាកំពុងមានកំណើនក្នុងប្រទេសកម្ពុជាសម្រាប់ឆ្នាំ2018," ដៃគូយុទ្ធសាស្ត្រទន្លេមេគង្គ, ខែមករា ឆ្នាំ2019; Tiffany Tsang និង Chansocheata Poum, "កត្តាប៉ះពាល់ដល់ស្ត្រីដែលចូលរួមក្នុងវិស័យបច្ចេកវិទ្យានៅក្នុងប្រទេសកម្ពុជា," នវានុវត្តន៍អភិវឌ្ឍន៍ ខែមិថុនា ឆ្នាំ2018។

២.១ ដែលផ្តោតលើការកែលម្អគុណភាព និងការប្រើប្រាស់សេវាសុខភាព រួមទាំងអាហារូបត្ថម្ភផងដែរ។ សមត្ថភាពរបស់កម្ពុជាក្នុងការសម្រេចឱ្យបាននូវការពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ចផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក្នុងនោះរួមបញ្ចូលទាំងព្រឹត្តិការណ៍ដែលចាប់ផ្តើមយឺតៗ (ឧ .ការកើនឡើងកម្រិតទឹកសមុទ្រ) និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ (ដូចជាភ្លៀងធ្លាក់ខ្លាំង ឬទឹកជំនន់)។ ការប្រែប្រួលសីតុណ្ហភាព និងរបបទឹកភ្លៀងអាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើទិន្នផលវិស័យកសិកម្ម ពោលគឺអាចកាត់បន្ថយកំណើនសេដ្ឋកិច្ចតែម្តង។ លើសពីនេះ ការធ្វើចំណាកស្រុករបស់ប្រជាជនពីកន្លែងមួយទៅកន្លែងមួយទៀត ដោយសារទឹកជំនន់ ឬគ្រោះរាំងស្ងួត អាចធ្វើឱ្យប៉ះពាល់ដល់កម្លាំងពលកម្មរបស់ប្រទេសកម្ពុជាផងដែរ។ ដោយសាររាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមអនុវត្តវិធានការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាពិសេសគឺបញ្ហាគ្រោះរាំងស្ងួត និងទឹកជំនន់នាពេលថ្មីៗនេះ កត្តានេះបានផ្តល់នូវឱកាសមួយក្នុងការចូលរួមក្នុងជម្រើសនៃការគ្រប់គ្រង។ ជម្រើសទាំងនេះ អាចរួមបញ្ចូលការបង្កើតឱកាសសម្រាប់កម្មវិធីធានារ៉ាប់រងដំណាំ ការលើកទឹកចិត្តឱ្យប្រើបច្ចេកទេសកសិកម្មឆ្លាតវៃផ្នែកអាកាសធាតុ និងការផ្តល់នូវកម្មវិធីបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីបញ្ចូលព័ត៌មានអាកាសធាតុទៅក្នុងការអភិវឌ្ឍកម្លាំងពលកម្ម។

## IR ១.២៖ កែលម្អបរិយាកាសធុរកិច្ចដើម្បីទាក់ទាញការវិនិយោគ និងបង្កើតការងារ

> អនុ-IR ១.២.១៖ កែលម្អគោលនយោបាយ និងការអនុវត្តសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគប្រកបដោយសេរី យុត្តិធម៌ និងបើកចំហ
>
> អនុ-IR ១.២.២៖ ពង្រឹងសមត្ថភាព និងគណនេយ្យភាពសម្រាប់ការវិនិយោគសាធារណៈ រួមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

IR ១.២ គាំទ្រដល់ចីរភាពនៃការពង្រីកការធ្វើពិពិធកម្មសេដ្ឋកិច្ច និងឱកាសក្រោមចំណុច IR ១.១ តាមរយៈការកែទម្រង់បរិយាកាសធុរកិច្ចអំណោយផលសំខាន់ៗ ដើម្បីទាក់ទាញការវិនិយោគ និងបង្កើតការងារ។ តាមរយៈការធ្វើការងារជាមួយភ្នាក់ងារផ្លាស់ប្តូរទាំងក្នុងជួររដ្ឋាភិបាល និងខាងក្រៅ (ដូចជាវិស័យឯកជន និងសង្គមស៊ីវិល) IR ១.២ នឹងគាំទ្រដល់គោលនយោបាយដែលបានកែលម្អ សម្រាប់ការធ្វើពាណិជ្ជកម្ម និងការវិនិយោគដោយសេរី និងយុត្តិធម៌ ព្រមទាំងពង្រឹងសមត្ថភាព និងគណនេយ្យភាពសម្រាប់ការវិនិយោគសាធារណៈ រួមទាំងហេដ្ឋារចនាសម្ព័ន្ធផងដែរ។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទាបលើសន្ទស្សន៍ធ្វើអាជីវកម្មជារួម (១៤៤ ក្នុងចំណោម ១៩០) និងទទួលបានពិន្ទុទាបលើការទទួលបានអគ្គិសនី (១៤៦) ការចាប់ផ្តើមអាជីវកម្ម (១៨៧) ការជួញដូរឆ្លងកាត់ព្រំដែន (១១៨) និងការអនុវត្តកិច្ចសន្យា (១៨២) - គ្រប់ផ្នែកសំខាន់ៗដែលត្រូវការដើម្បីបង្កើនសេដ្ឋកិច្ចបន្ថែមទៀត។[75] កង្វះតម្លាភាព និងគណនេយ្យភាពផ្នែកលទ្ធកម្មសាធារណៈ ក៏ជាបញ្ហាប្រឈមដ៏សំខាន់ផងដែរ។ តម្រូវការក្នុងការលើកកម្ពស់ការងារសមរម្យដែលផ្តល់នូវសមធម៌នៃប្រាក់ បៀវត្សរ៍ កាលវិភាគដែលអាចបត់បែនបាន ការបណ្តុះបណ្តាលជំនាញរបស់កម្មករបច្ចុប្បន្ន និងបរិយាកាសការងារដែលមានសុវត្ថិភាព និងគ្មានការបៀតបៀន ក៏មានភាពសំខាន់ ដើម្បីពង្រឹងបរិយាបន្ន

[75] "ពិន្ទុភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម," ធនាគារពិភពលោក, ឆ្នាំ2020។

និងការផ្តល់ភាពអង់អាចដល់ស្ត្រី និងប្រជាជនដែលមិនត្រូវបានគេគិតគូរផងដែរ។[76] ជំងឺរាតត្បាតបានបង្ហាញអំពី តម្រូវការក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងស្វែងរកឱកាសដើម្បីលើកកម្ពស់តម្លាភាពរបស់រដ្ឋាភិបាល និងកែលម្អគោលនយោបាយជំរុញដំណើរការធុរកិច្ច តាមរយៈការចូលរួមជាគោលដៅជាមួយអ្នកបច្ចេកទេសដែលមានគំនិតកែទម្រង់នៅក្នុងរដ្ឋាភិបាល ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។ IR នេះនឹងជួយដោះស្រាយភាពពឹងផ្អែកលើការវិនិយោគបរទេសដែលមិនមានចីរភាព បង្កើនតម្លាភាព និងបង្កើតបរិយាកាសកាន់តែអំណោយផលសម្រាប់ក្រុមហ៊ុនអាមេរិកក្នុងការធ្វើអាជីវកម្មនៅកម្ពុជា។

## IR ១.៣៖ ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងគណនេយ្យភាព

អនុ-IR ១.៣.១៖ ពង្រីកជីវភាពរស់នៅប្រកបដោយចីរភាពសម្រាប់ប្រជាជនងាយរងគ្រោះ
អនុ-IR ១.៣.២៖ ពង្រឹងសមត្ថភាព និងគណនេយ្យភាពសម្រាប់ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងតំបន់រងទឹកភ្លៀង
អនុរ-IR ១.៣.៣៖ ជំរុញការអភិវឌ្ឍដែលមានការបំភាយឧស្ម័នកម្រិតទាប ពីវិស័យឯកជន

កំណើនសេដ្ឋកិច្ចកម្ពុជាភាគច្រើន ត្រូវបានផ្សារភ្ជាប់ទៅនឹងការទាញយកធនធានធម្មជាតិ ដ៏សម្បូរបែបនៅកម្ពុជា។[77] ការអាស្រ័យផលជាប់ជាបន្តបន្ទាប់គឺនឹងអាស្រ័យទៅលើការវិនិយោគដោយចីរភាព ដែលគួរតែធ្វើឡើងដោយតម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ IR ១.៣ នឹងគាំទ្រដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចទៅលើការពង្រីកជីវភាពរស់នៅប្រកបដោយចីរភាព ដើម្បីប្រយុទ្ធប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ (ដូចជាតាមរយៈទេសចរណ៍ធម្មជាតិ អនុផលព្រៃឈើ ការលក់ឥណទានកាបូន និងសកម្មភាពផលិតប្រាក់ចំណូលផ្សេងទៀត)[78] បង្កើនសមត្ថភាព និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលសម្រាប់ការការពារទេសភាពសំខាន់ៗ និងតំបន់រងទឹកភ្លៀង រួមទាំងការប្រឆាំងការជួញដូរសត្វព្រៃ ជំរុញការអភិវឌ្ឍការបំភាយឧស្ម័នទាបដែលដឹកនាំដោយវិស័យឯកជន តាមរយៈកិច្ចអន្តរាគមន៍ ដូចជាការលក់ឥណទានកាបូន និងការលើកកម្ពស់ដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតតាមរយៈថាមពលកកើតឡើងវិញ។ IR នេះក៏នឹងផ្លាស់ប្តូរវិធីសាស្ត្ររបស់ទីភ្នាក់ងារ USAID ទៅជាការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាន ដើម្បីចៀសឆ្ងាយពីការផ្តោតតែលើចំនួនកម្រិតនៃទេសភាពដែលបានកំណត់ ដែលជាវិធីសាស្ត្រក្រោមយុទ្ធសាស្ត្រមុន។[79] អនុ-IR ១.២.២ នឹងពង្រឹងការអភិរក្សជីវចម្រុះនិងកាត់បន្ថយការជួញដូរសត្វព្រៃ តាមរយៈកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់រវាងសហគមន៍ និង មន្ត្រីមូលដ្ឋាន។ ការផ្តោតសំខាន់លើការគ្រប់គ្រងតំបន់រងទឹកភ្លៀង គឺជាតំបន់គោលដៅថ្មីដើម្បីផ្តោតលើធនធានដែលនៅលើផ្លូវទឹកសំខាន់ៗ ដូចជាទន្លេមេគង្គ និងទន្លេសាប ស្របតាមភាពជាដៃគូ

[76] "យេនឌ័រ និងការវិភាគការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន ទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា," USAID, ឆ្នាំ2020។

[77] "ក្របខ័ណ្ឌភាពជាដៃគូប្រចាំប្រទេសសម្រាប់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ2019-203," The World Bank Group, ថ្ងៃទី01 ខែឧសភា ឆ្នាំ2019, ដកស្រង់ចេញពី - https://openknowledge.worldbank.org/handle/10986/31789.

[78] ការវាយតម្លៃឥទ្ធិពលច្រើនឆ្នាំនៃកិច្ចអន្តរាគមន៍ជីវភាពរស់នៅប្រកបដោយចីរភាពស្រដៀងគ្នាដែលមានគោលដៅភ្ជាប់ទំនាក់ទំនងកិច្ចខិតខំប្រឹងប្រែងអភិរក្សដើម្បីកាត់បន្ថយភាពក្រីក្រដែលបានរកឃើញ ដែលជះឥទ្ធិពលសំខាន់ទៅលើជីវភាពរស់នៅ បើធៀបទៅនឹងការគ្រប់គ្រង។ Clements, et al, "ការវាស់វែងផលប៉ះពាល់នៃកិច្ចអន្តរាគមន៍អភិរក្សលើសុខុមាលភាពមនុស្ស និងបរិស្ថាននៅតំបន់ជើងប្រទេសកម្ពុជា," 3ie, ខែមីនា ឆ្នាំ2020។

[79] វិធីសាស្ត្រផ្អែកលើទេសភាព ក៏ត្រូវបានមើលឃើញថាមិនសូវមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការកាប់ព្រៃឈើ ជាជាងវិធីសាស្ត្រផ្តោតលើសហគមន៍នោះទេ។ Porter-Bolland L, et al, អេកូឡូស៊ី និងការគ្រប់គ្រងព្រៃឈើ 268:6-17, 2012.

តំបន់ទន្លេមេគង្គ-សហរដ្ឋអាមេរិក ថ្មី[80] ទាំងសារៈសំខាន់សម្រាប់ជីវភាពរស់នៅ (ឧ .ការនេសាទ និងផលផល) និងជាប្រភព អាហារូបត្ថម្ភដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា។[81]

ប្រទេសកម្ពុជាមានភាពខ្វះខាតក្នុងការបែងចែកធនធានឱ្យបានគ្រប់គ្រាន់ដើម្បីគ្រប់គ្រង និងការពារដែនជម្រកសត្វព្រៃ និងតំបន់ការពារក្នុងប្រទេស ដោយជាមធ្យម គឺមានឧទ្យានុរក្សតែម្នាក់ប៉ុណ្ណោះសម្រាប់ផ្ទៃដីទំហំ ៥.៧៦៣ ហិកតា[82] ពោលគឺ ទាបជាងអនុសាសន៍ណែនាំជាសកលដែលណែនាំឱ្យមានឧទ្យានុរក្សចំនួនបីនាក់សម្រាប់ផ្ទៃដីទំហំដប់ហិកតា។ ភាពខ្វះខាតផ្នែកសមត្ថភាពក្នុងចំណោមសមភាគីរដ្ឋាភិបាលក្នុងការគ្រប់គ្រងធនធានធម្មជាតិ រួមជាមួយនឹងកង្វះគណនេយ្យភាព និងតម្លាភាព គឺជាបញ្ហាអភិបាលកិច្ចដ៏សំខាន់នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ បញ្ហាប្រឈមទាំងនេះរួមចំណែកដល់ការកាប់ឈើខុសច្បាប់ ការកាប់ទន្ទ្រានដីព្រៃខុសច្បាប់សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម ការជួញដូរសត្វព្រៃខុសច្បាប់ ការចេញដីសម្បទាន សេដ្ឋកិច្ច និងការជីកយករ៉ែ និងខ្សែបន្ទាត់បញ្ជូនក្នុងតំបន់ការពារ។ នៅក្រោមរាជរដ្ឋាភិបាលកម្ពុជា មានក្រសួងជាច្រើនដែលមានទំនួលខុសត្រូវទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិក្រៅតែពីក្រសួងបរិស្ថាន ដែលរួមមានដូចជា ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ក្រសួងរ៉ែ និងថាមពល និងក្រសួងធនធានទឹក និងឧតុនិយមជាដើម។ ប្រព័ន្ធធ្វើការសម្រេចចិត្តប្រកបដោយតម្លាភាព និងការចូលរួមរបស់សាធារណៈជនកាន់តែប្រសើរឡើង ក៏ដូចជាការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៅទូទាំងស្ថាប័នរដ្ឋាភិបាលទាំងនេះ នឹងធ្វើឱ្យប្រសើរឡើងទាំងការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការប្រែប្រួលនិងការផ្លាស់ប្តូរអាកាសធាតុ។[83] ជីវចម្រុះ ការគ្រប់គ្រងតំបន់រងទឹកភ្លៀង និងការគ្រប់គ្រងជលផល ក៏នឹងទទួលរងផលប៉ះពាល់ពីការប្រែប្រួលសីតុណ្ហភាព លំនាំទឹកភ្លៀង និងទឹកជំនន់ផងដែរ។ ទីភ្នាក់ងារ USAID មានជំហររឹងមាំក្នុងការគាំទ្រការដាក់បញ្ចូលបម្រែបម្រួលអាកាសធាតុទៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ និងលើកទឹកចិត្តឱ្យមានការអនុវត្តល្អបំផុត ក្នុងការបញ្ចូលព័ត៌មានអាកាសធាតុទៅក្នុងការងារអភិរក្ស និងជីវចម្រុះ និងគំនិតផ្តួចផ្តើមផ្សេងៗទៀត។

## ឧត្តមភាពប្រៀបធៀបរបស់ទីភ្នាក់ងារ USAID នៅក្នុងកំណើនសេដ្ឋកិច្ច កសិកម្ម និងបរិស្ថាន

ទីភ្នាក់ងារ USAID ត្រូវបានគេមើលឃើញថាមានលក្ខណៈល្អពីសំណាក់សមភាគី ក្រសួង រដ្ឋាភិបាលជាច្រើន ដែលជួយសម្រួលដល់សមត្ថភាពរបស់យើងក្នុងការអភិវឌ្ឍសកម្មភាពប្រកបដោយប្រសិទ្ធភាពក្នុងវិស័យកំណើនសេដ្ឋកិច្ច កសិកម្ម និងបរិស្ថាន។ លើសពីនេះទៅទៀត ដោយផ្អែកលើភាពជាដៃគូរបស់យើង

---

[80] "ភាពជាដៃគូមេគង្គ-សហរដ្ឋអាមេរិក៖ តំបន់មេគង្គសមនឹងទទួលបានឈ្មោះថាជាដៃគូល្អ," ក្រសួងការបរទេសសហរដ្ឋអាមេរិក សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី14 ខែកញ្ញា ឆ្នាំ2020។

[81] ត្រីមានប្រូតេអ៊ីនសរុបចំនួន 37 ភាគរយ ហើយ 67 ភាគរយនៃប្រូតេអ៊ីនសត្វសរុបនៅក្នុងម្ហូបអាហារកម្ពុជា។ ប្រភព៖ World Fish Center.

[82] ប្រទេសកម្ពុជា បច្ចុប្បន្នមានឧទ្យានុរក្សចំនួន 1,260 នាក់ដែលស្ថិតនៅក្រោមក្រសួងបរិស្ថាន ពួកគេមានភារកិច្ចការពារច្រករបៀងជីវៈចម្រុះចំនួន 69 ទីតាំងដែលមានផ្ទៃដីសរុបចំនួន 7.3 លានហិចតា។ ប្រភព៖ ក្រសួងបរិស្ថាន។

[83] "ការវិភាគការគ្រប់គ្រងហានិភ័យនៃការប្រែប្រួលអកាសធាតុ ទីភ្នាក់ងារUSAID/ប្រទេសកម្ពុជា" ទីភ្នាក់ងារ USAID, ឆ្នាំ2020។

ជាមួយក្រុមហ៊ុន ទំនាក់ទំនងជាមួយសមាគមធុរកិច្ច និងការផ្តោតជាយុទ្ធសាស្ត្រថ្មីលើការអភិវឌ្ឍកម្លាំងពលកម្ម ទីភ្នាក់ងារ USAID បានបង្ហាញភាពរឹងមាំនៅក្នុងការចូលរួមពីវិស័យឯកជន។ ទំនាក់ទំនងទាំងនេះបានធ្វើឱ្យទីភ្នាក់ងារ USAID ស្ថិតនៅក្នុងជំហរជាក់លាក់មួយដែល អាចធ្វើការប្រកបដោយប្រសិទ្ធភាពនៅទូទាំងវិសាលគមទូលំទូលាយរបស់ភាគីពាក់ព័ន្ធ។

<u>តើទីភ្នាក់ងារ USAID នឹងកំណត់ទំនាក់ទំនងឡើងវិញជាមួយតួអង្គក្នុងស្រុក ដើម្បីពង្រីកកំណើនសេដ្ឋកិច្ចប្រកប ដោយចីរភាព និងបរិយាបន្នយ៉ាងដូចម្តេច?</u>

ទីភ្នាក់ងារ USAID នឹងស្វែងរកការចាប់ដៃគូជាមួយវិស័យឯកជន និងស្ថាប័នធុរកិច្ចលើគ្រប់ទិដ្ឋភាពនៃគោលបំណងអភិវឌ្ឍន៍។ ចំណុចនេះ នឹងរួមបញ្ចូលកម្មវិធីបើកដំណើរការដែលបង្កើនមូលនិធិពីវិស័យឯកជន ដើម្បីផ្គូរផ្គងឱ្យត្រូវនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេសជាមួយនឹងគំនិតផ្តួចផ្តើមការងារ ដោះស្រាយបញ្ហាប្រឈមផ្នែកហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យកសិកម្ម រួមទាំងការដឹកជញ្ជូន និងឃ្លាំងត្រជាក់ និងការចាប់ដៃគូជាមួយស្ថាប័នហិរញ្ញវត្ថុ ដើម្បីពង្រីកឱកាសវិនិយោគក្នុងវិស័យកែច្នៃ និងវិស័យនាំចេញដែលមានគុណតម្លៃខ្ពស់។ ពាក់ព័ន្ធនឹងបរិយាកាសអំណោយផល កិច្ចអន្តរាគមន៍នឹងធ្វើការតាមរយៈសភាពាណិជ្ជកម្ម និងស្ថាប័នធុរកិច្ចដ៏មានឥទ្ធិពលផ្សេងទៀត ដើម្បីធ្វើការតស៊ូមតិសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការកែទម្រង់បរិយាកាសអំណោយផលផ្នែកធុរកិច្ច។ ទាំងអស់នេះនឹងរួមបញ្ចូលកិច្ចសន្ទនាសាធារណៈ និងឯកជន ភាពជាដៃគូជាមួយនឹងក្រុមអ្នកជំនាញ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត លើការវិភាគសេដ្ឋកិច្ចលើឧបសគ្គពាណិជ្ជកម្មមិនមែនពន្ធ និងធ្វើការជាមួយរដ្ឋាភិបាលលើការកសាងសមត្ថភាពសម្រាប់ការវិនិយោគសាធារណៈ រួមទាំងហេដ្ឋារចនាសម្ព័ន្ធផងដែរ។ ពាក់ព័ន្ធនឹងការកែលម្អការគ្រប់គ្រងធនធានធម្មជាតិ កិច្ចអន្តរាគមន៍ នឹងប្រើប្រាស់វិធីសាស្ត្រផ្អែកលើទីផ្សារឆ្ពោះទៅរកការលើកកម្ពស់ជីវភាព តាមរយៈការភ្ជាប់អ្នកទិញជាមួយសហគមន៍មូលដ្ឋានលើផលិតផលអនុផលព្រៃឈើ ភ្ជាប់ទំនាក់ទំនងក្រុមហ៊ុនទេសចរណ៍ជាមួយនឹងគំនិតផ្តួចផ្តើមអេកូទេសចរណ៍ ដើម្បីលើកកម្ពស់ភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិ និងធ្វើការជាមួយក្រុមហ៊ុនអន្តរជាតិពាក់ព័ន្ធនឹងការលក់ឥណទានកាបូន។ ទីភ្នាក់ងារ USAID ក៏នឹងគាំទ្រដល់អង្គការសង្គមស៊ីវិលដើម្បីជួយពង្រឹងគណនេយ្យភាព និងតម្លាភាពទាក់ទងនឹងការគ្រប់គ្រងតំបន់រងទឹកភ្លៀង និងទេសភាពផងដែរ។

## គោលបំណងអភិវឌ្ឍន៍ទី ២៖ កែលម្អសុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា

ប្រទេសកម្ពុជា សម្រេចបាននូវសមិទ្ធិផលសំខាន់ៗលើវិស័យសុខាភិបាល អប់រំ និងការពារកុមារ។ ទីភ្នាក់ងារ USAID គឺជាដៃគូដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគាំទ្រដល់ការសម្រេចបានគួរឲ្យកត់សំគាល់លើការកាត់បន្ថយអត្រាមរណភាពមាតានិងទារកអាយុក្រោម ៥ឆ្នាំ អ្នកឆ្លងជំងឺរបេង ជំងឺអេដស៍ និងជំងឺគ្រុនចាញ់។ ទីភ្នាក់ងារ USAID បានពង្រឹងប្រព័ន្ធ និងគោលនយោបាយ ជាតិ ពង្រីកការផ្សព្វផ្សាយដល់សហគមន៍ និងធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាប្រកបដោយគុណភាព។ ជាមួយនឹងការវិនិយោគជាង ៣០ ឆ្នាំកន្លងមកនេះ ទីភ្នាក់ងារ USAID បានធ្វើការយ៉ាងជិតស្និទ្ធ ដើម្បីជួយប្រទេសកម្ពុជាក្នុងការបង្កើនអត្រានៃការសម្រាលកូនដោយឆ្មបជំនាញលើសពីពីរដង ពី ៣២ ទៅ ៨៩ ភាគរយ និងអត្រានៃការ

ប្រើប្រាស់មធ្យោបាយពន្យារកំណើតបែបទំនើបពី ១៩ ទៅ ៣៩ ភាគរយនៅចន្លោះឆ្នាំ ២០០០ និង ២០១៤។[84] អត្រាអ្នកជំងឺរបេងប្រចាំឆ្នាំដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងប្រទេសកម្ពុជាមានអត្រាថយចុះប្រចាំឆ្នាំជាមធ្យម ២,៥ ភាគរយ ហើយកិច្ចខិតខំប្រឹងប្រែងក៏ទទួលបានជោគជ័យក្នុងការទប់ស្កាត់ជំងឺរបេងស៊ាំថ្នាំ។[85] អត្រា ប្រេវ៉ាឡង់អ្នកជំងឺអេដស៍សម្រាប់មនុស្សពេញវ័យបានធ្លាក់ចុះជាលំដាប់មកត្រឹម ០,៥ ភាគរយក្នុងឆ្នាំ ២០១៩ ជាមួយនឹងអត្រាថយចុះចំនួន ៦១%នៃចំនួនអ្នកឆ្លងមេរោគអេដស៍ថ្មី ពី ២.០០០ នាក់ក្នុងឆ្នាំ ២០១០ ដល់ ៧៨០ ក្នុងឆ្នាំ ២០១៩។ ប្រទេសកម្ពុជាមិនមានការស្លាប់ពាក់ព័ន្ធនឹងជំងឺគ្រុនចាញ់នោះទេចាប់តាំងពីឆ្នាំ ២០១៧ មក ហើយប្រទេសកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅរកការលុបបំបាត់ជំងឺគ្រុនចាញ់ហ្វាល់ស៊ីប៉ារូម នៅឆ្នាំ ២០២៣ ខាងមុខនេះ។ ទីភ្នាក់ងារ USAID បានបង្កើតគំរូដ៏មានប្រសិទ្ធភាពដែលកាត់បន្ថយជំងឺក្រិនបាន ១៩ ភាគរយ នៅក្នុងស្រុកគោលដៅ និងបានជួយក្នុងការពង្រីកមូលនិធិសមធម៌សម្រាប់សុខភាពដល់គ្រប់មូលដ្ឋានសុខាភិបាលទូទាំងប្រទេស ដោយការបង្កើនលទ្ធភាពទទួលបានសេវាសុខភាពដោយឥតគិតថ្លៃទៅដល់ប្រជាជនកម្ពុជាក្រីក្រជាងបីលាននាក់ ។ ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលចាត់ទុកវិស័យនេះជាកត្តាជំរុញស្នូលនៃការអភិវឌ្ឍរបស់កម្ពុជា និងសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍សហស្សវត្សរ៍ក្នុងការអប់រំកម្រិតបឋមសិក្សាជាសកលនៅឆ្នាំ ២០១៥។ ចាប់តាំងពីពេលនោះមក រាជរដ្ឋាភិបាលបានធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានការអប់រំជាបន្តបន្ទាប់ ជាមួយនឹងអត្រាចុះឈ្មោះចូលរៀនសុទ្ធក្នុងឆ្នាំ ២០១៩ ឈានដល់ ៩៧,៣ ភាគរយសម្រាប់បឋមសិក្សា ៥៩,៩ ភាគរយសម្រាប់អនុវិទ្យាល័យ និង ៣០,៩ ភាគរយសម្រាប់វិទ្យាល័យ។

ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នានៅតែមានរវាងប្រជាជនជនបទ និងទីក្រុង និងក្នុងចំណោមក្រុមមនុស្សដែលមិនត្រូវបានគេគិតគូរ និងងាយរងគ្រោះ។ ក្នុងវិស័យសុខាភិបាល ការចំណាយលើផ្នែកសុខាភិបាលរបស់រដ្ឋាភិបាលមិនបានរក្សាល្បឿន[86] ដោយសារការចំណាយប្រាក់ក្នុងហោប៉ៅនៅតែបន្តកើនឡើង។[87] លើសពីនេះទៀត ក្នុងវិស័យអប់រំ សិស្សានុសិស្សកម្ពុជាភាគច្រើនប្រឈមនឹងវិបត្តិក្នុងការសិក្សា និងមិនអាចបំពេញតាមស្តង់ដារអប្បបរមានៃការអាន និងគណិតវិទ្យា។ ប្រព័ន្ធការពារកុមាររបស់កម្ពុជាក៏កំពុងប្រឈមជាមួយនឹងអត្រាខ្ពស់នៃកុមារដែលរស់នៅក្នុងការថែទាំតាមស្ថាប័ន និងកុមារដែលបន្តជួបប្រទះនូវអំពើហិង្សា រួមជាមួយនឹងអត្រាភាពក្រីក្រខ្ពស់ និងលទ្ធភាពទទួលបានការអប់រំទាប ដែលជាកត្តាជំរុញចម្បងនៃការដាក់កុមារនៅក្នុងមណ្ឌល។[88] អំពើហិង្សាលើកុមារ ការជួញដូរកុមារ ពលកម្មកុមារ ការរៀប

[84] មរណភាពកុមារនៃការស្ទង់មតិរងក្នុងផែនទីបង្ហាញផ្លូវ ទទួលបានពិន្ទុ 94 លើ 100 ដែលពិន្ទុនេះមានភាពល្អប្រសើរពីមួយពេលទៅមួយពេល (ការថយចុះនៃចំនួនមរណភាពកុមារ)។ ប្រភព៖ CIESIN, ការការពារធនធានធម្មជាតិ និងសូចនាករសុខភាពកុមារ ឆ្នាំ2018។

[85] អង្គការសុខភាពពិភពលោក (WHO)។

[86] ការចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាល គឺមានចំនួន 1.4 ភាគរយនៃ ផសស ហើយចំនួននេះមិនមានការប្រែប្រួលឡើងនៅក្នុងរយៈពេលមួយទស្សវត្សរ៍កន្លងមកនេះ។ ប្រភព៖ សូចនាករអភិវឌ្ឍន៍ពិភពលោក ធនាគារពិភពលោក ឆ្នាំ2017។

[87] ការចំណាយប្រាក់ក្នុងហោប៉ៅ គឺមានចំនួន 60 នៃការចំណាយលើវិស័យសុខាភិបាលសរុប ដែលចំនួននេះមានការកើនឡោះងនៅក្នុងរយៈពេលជាមួយទស្សវត្សន៍កន្លងមកនេះ។ ប្រភព៖ សូចនាករអភិវឌ្ឍន៍ពិភពលោក ធនាគារពិភពលោក ឆ្នាំ2017។

[88] យោងតាមផែនទីឆ្នាំ 2015 មូលដ្ឋានថែទាំសុខភាពតាមផ្ទះគឺមានចំនួន 639 ទីតាំង ដែលទទួលបន្ទុកកុមារចំនួន 26,187 នាក់ ដែល 63 ភាគរយនៃកុមារទាំងនេះ រស់នៅក្នុងវិទ្យាស្ថាន។ មូលហេតុចម្បងសម្រាប់កុមារដែលបានដាក់ឱ្យនៅក្នុងមណ្ឌលថែទាំ គឺមកពីភាពក្រីក្រ ក្នុងនោះរួមបញ្ចូលទាំងការទទួលបានការសិក្សាចំនួន 75 ភាគរយផងដែរ។ ចំណុចនេះ ធ្វើឱ្យកុមារចំនួន 79 ភាគរយដែលរស់នៅក្នុងមណ្ឌលថែទាំមានឪពុកម្តាយចិញ្ចឹមម្នាក់។

អាពាហ៍ពិពាហ៍ក្នុងវ័យក្មេង និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅតែជាបញ្ហាដែលគួរឱ្យព្រួយបារម្ភសម្រាប់កម្ពុជា។[89]

## *សម្មតិកម្មនៃការអភិវឌ្ឍ*

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមជាច្រើនទាំងនេះ និងកសាងបន្ថែមទៅលើការវិនិយោគ និងភាពជោគជ័យ នាពេលកន្លងមក ទីភ្នាក់ងារ USAID នឹងផ្តល់អាទិភាពទៅលើ "គោលបំណងអភិវឌ្ឍន៍ទី ២៖ កែលម្អ សុខភាព ការអប់រំ និងសុខុមាលភាពពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សេវា" ដែលផ្សារភ្ជាប់ទៅនឹងគោលដៅយុទ្ធសាស្ត្រ CDCS តាមរយៈការគាំទ្រលទ្ធផលនៃការអភិវឌ្ឍសង្គម និងធនធានមនុស្សដែលចាំបាច់សម្រាប់ បង្កើនវិបុលភាព និងភាពធន់នឹងវិបត្តិក្នុងប្រទេសកម្ពុជា។ ខណៈពេលកំពុងបន្តការផ្លាស់ប្តូរពីការផ្តល់សេវាដោយផ្ទាល់ទៅជាការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធសុខាភិបាល អប់រំ និងការពារកុមារ[90] ដែលផ្ទុយពីយុទ្ធសាស្ត្រពីមុន គោលបំណងអភិវឌ្ឍន៍ទី ២ នឹងបង្កើនការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងទៅលើបញ្ហាដែលមានលក្ខណៈអន្តរវិស័យ ដូចជាការធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ច និងគណនេយ្យភាពនៃប្រព័ន្ធសុខាភិបាល អប់រំ និងការពារកុមាររបស់ប្រទេសកម្ពុជា។

សម្មតិកម្មនៃការអភិវឌ្ឍគោលបំណងអភិវឌ្ឍន៍ទី ២ បានលើកឡើងថា *ប្រសិនបើ* ប្រព័ន្ធសុខាភិបាល អប់រំ និងសុខុមាលភាពសង្គមរបស់កម្ពុជាមានសមត្ថភាព និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ *ហើយប្រសិនបើ* ប្រជាជនកម្ពុជាត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការតស៊ូមតិ ដើម្បីការផ្តល់សេវាកាន់តែប្រសើរឡើង *នោះ* សុខភាព ការអប់រំ និងសុខុមាលភាពរបស់ប្រជាជននឹងមានភាពប្រសើរឡើងតាមរយៈការទទួលបានសេវាកម្មល្អប្រសើរ។

ដើម្បីពង្រឹងវឌ្ឍនភាពឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ពហុវិស័យ និងការកសាងភាពធន់នឹងហេតុការណ៍គ្រោះមហន្តរាយដែលដែលពុំបានព្រៀងទុក ដូចជាជំងឺកូវីដ-១៩ ទីភ្នាក់ងារ USAID នៅកម្ពុជា នឹងផ្តោតទៅលើការសម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោមក្នុងរយៈពេល ៥ ឆ្នាំខាងមុខ។ ទីមួយ គុណភាព និងការប្រើប្រាស់សេវាសុខភាពអាទិភាពត្រូវតែប្រសើរឡើង (IR ២.១)។ កិច្ចការនេះរួមបញ្ចូលទាំងសុខភាពមាតាទារក និងកុមារ កម្មវិធីជំងឺរបេង និងការការធ្វើឲ្យប្រសើរឡើងនូវសេវាកម្មវិស័យឯកជន ព្រមទាំងទាមទារឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាដែលជាអ្វីដែលប្រជាពលរដ្ឋត្រូវការ និងស្វែងរកការថែទាំសុខភាពប្រកបដោយ គុណភាពពីវិស័យសាធារណៈ និងឯកជន។ ទីពីរ អភិបាលកិច្ច និងគណនេយ្យភាពនៃប្រព័ន្ធសុខាភិបាល អប់រំ និងការពារកុមារត្រូវតែពង្រឹងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន (IR ២.២)។ ដោយសារតែរដ្ឋបាលថ្នាក់ខេត្តនិងស្រុក ទទួលនូវទំនួលខុសត្រូវច្រើនជាងមុន ដែលពីមុនមកធ្លាប់តែស្ថិតនៅក្រោមការគ្រប់គ្រង ផ្ទាច់មុខដោយក្រសួង (ក្រសួងសុខាភិបាល ក្រសួងអប់រំ និងក្រសួងសង្គមកិច្ច) រដ្ឋបាលថ្នាក់ខេត្ត និងស្រុក ត្រូវតែប្រើប្រាស់ភស្តុតាងដើម្បីផ្តល់អាទិភាពធនធានក្នុងស្រុកសម្រាប់វិស័យសុខាភិបាល

[89] "ការស្ទង់មតិអំពីអំពើហិង្សាលើកុមាររបស់ប្រទេសកម្ពុជា ឆ្នាំ2013", UNICEF, ខែតុលា ឆ្នាំ2014។

[90] ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិបានទទួលស្គាល់ពីសារៈសំខាន់នៃវិធីសាស្ត្រការពង្រឹងប្រព័ន្ធសុខាភិបាលនេះ។ "ចក្ខុវិស័យរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិដើម្បីពង្រឹងប្រព័ន្ធសុខាភិបាល USAID ឆ្នាំ2019។

វិស័យអប់រំ និង វិស័យការពារកុមារ ដើម្បីកាត់ផ្តាច់វដ្តនៃការពឹងផ្អែកលើម្ចាស់ជំនួយ ការកសាងភាពធន់នឹងបញ្ហាហិរញ្ញវត្ថុ ជំងឺរាតត្បាត និងគ្រោះមហន្តរាយដែលពុំបានព្រៀងទុកផ្សេងៗ ព្រមទាំងពង្រឹងប្រព័ន្ធថ្នាក់ក្រោមជាតិដើម្បីបន្តដំណើររបស់ប្រទេសកម្ពុជាទៅរកការពឹងផ្អែកលើខ្លួនឯង។ ដើម្បីបំពេញការងារជាមួយរដ្ឋាភិបាល កិច្ចការគាំទ្រដល់ប្រជាពលរដ្ឋកម្ពុជា និងអង្គការសង្គមស៊ីវិលត្រូវតែផ្តោតលើការត្រួតពិនិត្យគុណភាពនៅក្នុងការបង្កើនលទ្ធភាពទទួលបានសេវាកម្ម។

វិធីសាស្ត្រនេះតំណាងឱ្យចំណុចប្រសព្វនៃការផ្តល់សេវា អភិបាលកិច្ចល្អ និងគណនេយ្យភាព។ ទីបី គុណភាពនៃសេវាអប់រំ និងសេវាការពារកុមារត្រូវតែកែលម្អឱ្យប្រសើរឡើង (IR ២.៣)។ កិច្ចការនេះទាមទារឱ្យមានការបង្កើន និងការពង្រឹងសមត្ថភាពប្រព័ន្ធផ្តល់សេវារបស់រដ្ឋាភិបាល ខណៈពេលកំពុងកសាងដំណាលគ្នានូវសមត្ថភាព និងជំនាញរបស់អ្នកអប់រំវិជ្ជាជីវៈ និងអ្នកផ្តល់សេវាសង្គមដើម្បីបង្កើនលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានសេវាមានគុណភាពសម្រាប់កុមារទាំងអស់ ជាពិសេសកុមារមានពិការភាព និងកុមារងាយរងគ្រោះបំផុត។ វិធីសាស្ត្រនេះនឹងតម្រូវឱ្យទីភ្នាក់ងារ USAID ធ្វើការងារជាដៃគូជាមួយសង្គមស៊ីវិល វិស័យឯកជន សហគមន៍ និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើនការឆ្លើយតប និងពង្រឹងសមត្ថភាពរបស់ស្ថាប័នក្នុងការការពារកុមារឱ្យរួចផុតពីអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច។ តារាងទី ៨ សង្ខេបអំពីការសន្មត និងហានិភ័យសំខាន់ៗដែលបានកំណត់សម្រាប់ការអនុវត្ត គោលបំណងអភិវឌ្ឍន៍ទី ២។

### តារាងទី ៨៖ ការសន្មត និងហានិភ័យសំខាន់ៗសម្រាប់គោលបំណងអភិវឌ្ឍន៍ទី ២

| ការសន្មត | ហានិភ័យ |
|---|---|
| • រាជរដ្ឋាភិបាលកម្ពុជារក្សានូវកម្រិតធនធានក្នុងស្រុកគ្រប់គ្រាន់ (ថវិកា) ដើម្បីផ្តល់អាទិភាពដល់កម្មវិធី សុខភាព អប់រំ និងការពារកុមារ ទោះបីជាមានការថមថយផ្នែក សេដ្ឋកិច្ចដោយសារជំងឺកូវីដ-១៩ យ៉ាងណាក្តី។<br>• រាជរដ្ឋាភិបាលកម្ពុជាបន្តប្តេជ្ញាចិត្ត វិនិយោគលើវិស័យសង្គមជាអាទិភាព និងរក្សាបាននូវស្ថានភាពបច្ចុប្បន្នដែលអនុញ្ញាតឱ្យមានស្វ័យភាព និងទំនួលខុសត្រូវកាន់តែច្រើនឡើងចំពោះរដ្ឋបាលមូលដ្ឋានក្នុងការផ្តល់សេវាកម្ម។<br>• រាជរដ្ឋាភិបាលរក្សាបាននូវកិច្ចសហប្រតិបត្តិការរឹងមាំ និងការប្តេជ្ញាចិត្តចំពោះវិស័យសុខាភិបាល។ | • ការបង្វែទិសដៅធនធានរបស់រាជរដ្ឋាភិបាលដើម្បីរដោះស្រាយវិបត្តិសេដ្ឋកិច្ចដែលពុំបានដឹងមុនដោយសារជំងឺកូវីដ-១៩ ដោយដាក់ការចំណាយនៅក្នុងការវិនិយោគរបស់កម្មវិធីសុខភាព អប់រំ និងការពារកុមារ។<br>• កង្វះគោលការណ៍ណែនាំច្បាស់លាស់ពីរាជរដ្ឋាភិបាល អំពីរបៀបដែលវចនាសម្ព័ន្ធវិមជ្ឈការនឹងគ្រប់គ្រងទំនួលខុសត្រូវនៅកម្រិតមូលដ្ឋាន ដែលនាំឱ្យមានការថយចុះនូវគុណភាពនៃការផ្តល់សេវា។<br>• ការចែករំលែកទិន្នន័យមិនពេញលេញ និងគន្លាតព័ត៌មានផ្សេងទៀតអាចរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរបស់ម្ចាស់ជំនួយនៅក្នុងកិច្ចសហការ និងការជំរុញការផ្ទេរពីការវិនិយោគរបស់ទីភ្នាក់ងារ USAID ឱ្យប្រែក្លាយទៅជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ក៏ដូចជាការលើកកម្ពស់ដល់ការពង្រីកវិសាលភាព និងបរិយាបន្នដល់ប្រជាជនដែលមិនត្រូវបានគិតគូរ។<br>• ពុំមានការអនុវត្តន៍នូវកំណែទម្រង់គោលនយោបាយដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព។ |

*របៀបដែលគោលបំណងអភិវឌ្ឍន៍ទី ២ ជំរុញ J2SR របស់កម្ពុជា*

ដូចដែលបានបង្ហាញនៅក្នុងផែនទីបង្ហាញផ្លូវទៅកាន់ J2SR របស់កម្ពុជា សមត្ថភាពរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាបខ្លាំងនៅឡើយ ហើយគម្លាតគឺនៅតែមានសម្រាប់គុណភាពអប់រំ និង សុខភាពកុមារ។ លើសពីនេះទៅទៀត *សមត្ថភាពរបស់រដ្ឋាភិបាល* ក្នុងការគាំទ្រសេវាប្រកបដោយគុណភាពនៅតែមិនទាន់ទទួលបានការពេញចិត្តនៅឡើយ។ ទោះបីជាមានការខិតខំប្រឹងប្រែងនៅក្នុងការធ្វើឲ្យប្រសើរឡើងនូវសេវា និង លទ្ធភាពទទួលបានសេវាឱ្យកាន់តែល្អប្រសើរក៏ដោយ ក៏ជំងឺកូវីដ-១៩ បានគូសបញ្ជាក់ថាក្រុមកុមារ និង គ្រួសារមួយចំនួន រួមទាំងក្រុម៖ ១) ដែលរស់នៅក្នុងតំបន់ដាច់ស្រយាល ២) មកពីគ្រួសារមានស្ថានភាពសេដ្ឋកិច្ចសង្គមកម្រិតទាប ៣) មានពិការភាព និង ៤) មកពីសហគមន៍ជនជាតិភាគតិច នៅតែបន្តមានអបរិយាបន្ន និងមិនទទួលបានផលប្រយោជន៍ដូចគ្នាពីការទទួលបានសេវាមានគុណភាព។ ជាងនេះទៅទៀត ជំងឺកូវីដ-១៩ ក៏បានគូសបញ្ជាក់អំពីតម្រូវការជាចាំបាច់នូវភាពធន់កាន់តែខ្លាំងនៃប្រព័ន្ធផ្តល់សេវា ដើម្បីធានាថាប្រជាជនកម្ពុជាអាចបន្តទទួលបានសេវានៅក្នុងអំឡុងពេលមានគ្រោះមហន្តរាយ ជំងឺរាតត្បាត និង គ្រោះអាសន្នផ្សេងៗទៀត។

លទ្ធផលរំពឹងទុក ដែលពង្រឹងឱ្យគ្នាទៅវិញទៅមក នឹងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការបំបែកវដ្តនៃការពឹងផ្អែកទៅលើម្ចាស់ជំនួយ ការកសាងភាពធន់ទៅនឹងវិបត្តិហិរញ្ញវត្ថុ និងហេតុការណ៍រាតត្បាតដែលពុំបានព្រៀងទុក ព្រមទាំងពង្រឹងប្រព័ន្ធថ្នាក់ក្រោមជាតិដើម្បីបន្តដំណើររបស់កម្ពុជាឆ្ពោះទៅរកការពឹងផ្អែកលើខ្លួនឯង។ បន្ថែមពីលើនេះទៅទៀត តាមរយៈការវិនិយោគលើគោលនយោបាយឆ្លើយតប និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់អ្នកផ្តល់សេវាដែលទទួលខុសត្រូវចំពោះការផ្តល់ការថែទាំ និងសេវាប្រកបដោយគុណភាព ទីភ្នាក់ងារ USAID នឹងបង្ហាញផ្លូវច្បាស់លាស់ឆ្ពោះទៅការពឹងផ្អែកលើខ្លួនឯងដោយផ្អែកលើប្រព័ន្ធគណនេយ្យភាព និងតម្លាភាព ដែលអនុញ្ញាតឱ្យសង្គមស៊ីវិលមានការសន្ទនាប្រកបដោយអត្ថន័យ។

ការប្តេជ្ញាចិត្តរាជរដ្ឋាភិបាលកម្ពុជានៅក្នុងក្រសួងពាក់ព័ន្ធមានកម្រិតខ្ពស់ចំពោះកំណែទម្រង់សំខាន់ៗ និងការកែលម្អគុណភាព។ ទោះជាយ៉ាងណាក៏ដោយ ភាពខ្វះចន្លោះផ្នែកសមត្ថភាពសំខាន់ៗគឺនៅតែមាន ហើយទីភ្នាក់ងារ USAID នឹងបន្តយកចិត្តទុកដាក់លើការកសាងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ តារាងទី ៩ សង្ខេបអំពីរបៀបដែលគោលបំណងអភិវឌ្ឍន៍ទី ២ នឹងរួមចំណែកដល់សមាសធាតុ J2SR នីមួយៗ។

**តារាងទី ៩៖ សមាសធាតុ J2SR សម្រាប់គោលបំណងអភិវឌ្ឍន៍ទី ២**

| សមាសធាតុ J2SR | វិធីសាស្ត្រគោលបំណងអភិវឌ្ឍន៍ទី ២ |
|---|---|
| កំណត់ទំនាក់ទំនងឡើងវិញ | ពង្រឹងសមត្ថភាពស្នូលរបស់រាជរដ្ឋាភិបាល និងជំរុញការប្តេជ្ញាចិត្ត (ក) ដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង (ខ) រៀបចំបង្កើត និងពង្រីកវិសាលភាពគោលនយោបាយ និងកម្មវិធីក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជា។ |
| ការពឹងផ្អែកហិរញ្ញប្បទានលើខ្លួនឯង | គាំទ្រលទ្ធភាពរបស់កម្ពុជាក្នុងការសម្រេចបាននូវតុល្យភាពត្រឹមត្រូវរវាងជំនួយបរទេស ធនធានសាធារណៈក្នុងស្រុក និងធនធានវិស័យឯកជនដែលចាំបាច់ក្នុងការបន្តដំណើរឆ្ពោះទៅរកការកំណត់ និងការផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន។ |
| ការចូលរួមរបស់វិស័យឯកជន | ជំរុញធនធានវិស័យឯកជន ដើម្បីបង្កើនគុណភាព និងគាំទ្រការបញ្ចូលគ្នាសមស្របនូវដៃគូវិស័យរដ្ឋ និងវិស័យឯកជន។ |
| ការបង្កើតភាពជាដៃគូប្រកបដោយប្រសិទ្ធភាព និងកំណែទម្រង់លទ្ធកម្ម | ពង្រឹងការគ្រប់គ្រង និងការអនុវត្តថវិការបស់រដ្ឋាភិបាលកម្ពុជាដែលរក្សាបាននូវតម្លាភាព និងគណនេយ្យភាព។ កសាងសមត្ថភាពរបស់ក្រសួងស្ថាប័នដើម្បីបំពេញតាមស្តង់ដារអន្តរជាតិប្រកបដោយប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម។ |

<u>របៀបដែលគោលបំណងអភិវឌ្ឍន៍ទី ២ ជំរុញឱ្យតំបន់ឥណ្ឌូប៉ាស៊ីហ្វិកកាន់តែសេរី និងបើកចំហ</u>

វិស័យសុខាភិបាល អប់រំ និងការពារកុមារ គឺជាមូលដ្ឋានគ្រឹះចាំបាច់សម្រាប់ភាពធន់របស់ប្រជាជនកម្ពុជា ដើម្បីសម្រេចបាននូវគោលដៅរយៈពេលវែង ដែលរួមចំណែកដល់ការកសាងធនធាន មនុស្ស និងកំណើនសេដ្ឋកិច្ច ដែលមានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងការធ្វើឱ្យតំបន់ឥណ្ឌូប៉ាស៊ីហ្វិក កាន់តែសេរី និងបើកចំហ។ វិធីសាស្ត្រនៅក្នុងគោលបំណងអភិវឌ្ឍន៍ នេះនឹងគាំទ្រដល់រាជរដ្ឋាភិបាល នៅក្នុងការបំបែកវដ្តនៃការពឹងផ្អែកលើការវិនិយោគពីបរទេស កសាងភាពធន់នឹងវិបត្តិហិរញ្ញវត្ថុ និងហេតុការណ៍វាតត្បាតដែលពុំបានព្រៀងទុក ព្រមទាំងពង្រឹងប្រព័ន្ធថ្នាក់ក្រោមជាតិ ដើម្បីបន្តដំណើររបស់ប្រទេសកម្ពុជាឆ្ពោះទៅកាន់ភាពពឹងផ្អែកលើខ្លួនឯង។ វិធីសាស្ត្រពង្រឹងប្រព័ន្ធ ក៏ដូចជាការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការពង្រឹងការត្រួតពិនិត្យបែបស្ថាបនាទៅលើសេវាសាធារណៈ ដើម្បីធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព ជួយជំរុញអភិបាលកិច្ចបែបប្រជាធិបតេយ្យឲ្យកាន់តែប្រសើរឡើង និង គំនិតផ្តួចផ្តើមតម្លាភាពក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក តាមរយៈគោលនយោបាយឆ្លើយតបចំពោះប្រជាពលរដ្ឋ។ ការវិនិយោគរបស់ទីភ្នាក់ងារ USAID ទៅលើវិស័យសុខាភិបាល និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា បង្ហាញអំពីវិធីសាស្ត្ររយៈពេលវែង ដែលជាជម្រើសប្រកបដោយនិរន្តរភាព និងមានឥទ្ធិពល។

<u>អាទិភាពរបស់រដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ</u>

រាជរដ្ឋាភិបាលកម្ពុជា កំពុងទទួលយកគំរូនៃភាពជាអ្នកដឹកនាំ និងភាពជាដៃគូកាន់តែច្រើនឡើងនៅក្នុងវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យការពារកុមារ និងសង្គម។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការច្បាស់លាស់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មប្រកបដោយគុណភាព និងទទួលខុសត្រូវកាន់តែច្រើនចំពោះការសន្ទតអំពីមធ្យោបាយទូទាត់ប្រាក់ និងការគ្រប់គ្រងរបស់អន្តរាគមន៍ដែលគាំទ្រដោយទីភ្នាក់ងារ

USAID រួមមានៈ ១) មូលនិធិសមធម៌សុខាភិបាល ២) កម្មវិធីឧបត្ថម្ភសាច់ប្រាក់តាមលក្ខខណ្ឌ និង ៣) លទ្ធកម្មនៃថ្នាំព្យាបាលជំងឺរបេងនិងមេរោគអេដស៍។ ដើម្បីគាំទ្រដល់ដំណើររបស់កម្ពុជាឆ្ពោះទៅរកគោលដៅខ្លួនទីពឹងខ្លួន រដ្ឋាភិបាលអាមេរិកបានពង្រឹងប្រព័ន្ធហិរញ្ញប្បទានសុខភាពនិងអប់រំ ដើម្បីប្រើប្រាស់ធនធានក្នុងស្រុកឱ្យកាន់តែមានប្រសិទ្ធភាព។[91] វិស័យទាំងនេះ នៅតែជាអាទិភាពខ្ពស់ និងទទួលបានបទពិសោធន៍នៃការកាត់បន្ថយមូលនិធិទាបបំផុតដោយសារតែឧបសគ្គសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាដោយសារតែជំងឺកូវីដ-១៩។

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល បង្ហាញថាការពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាលនៅក្នុងការផ្តល់សេវា ការប្រើប្រាស់ទិន្នន័យសមស្រប និងការប្រើប្រាស់ធនធានក្នុងស្រុក គឺជាយុទ្ធសាស្ត្រដ៏សមស្របនៅក្នុងការពង្រឹងអភិបាលកិច្ច និងគណនេយ្យភាពនៃប្រព័ន្ធសុខាភិបាល អប់រំ និងការពារកុមារនៅកម្ពុជា។

### តារាងទី ១០៖ ការបន្ស៊ីគោលបំណងអភិវឌ្ឍន៍ទី ២ ជាមួយយុទ្ធសាស្ត្រថ្នាក់វិស័យសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា

| យុទ្ធសាស្ត្រគន្លឹះរបស់រដ្ឋាភិបាលកម្ពុជា | ការបន្ស៊ីជាមួយនឹងគោលបំណងអភិវឌ្ឍន៍ទី ២ |
|---|---|
| • ផែនការយុទ្ធសាស្ត្រសុខាភិបាលដំណាក់កាលទី ៤ (ឆ្នាំ ២០២១-២០៣០)<br>• ផែនការយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់ការឆ្លើយតបគ្រប់ជ្រុងជ្រោយ និងពហុវិស័យចំពោះជំងឺអេដស៍/មេរោគអេដស៍ ដំណាក់កាលទី ៥ (ឆ្នាំ ២០១៩-២០២៣)<br>• ក្របខ័ណ្ឌនៃសកម្មភាពលុបបំបាត់ជំងឺគ្រុនចាញ់ ២<br>• ផែនការយុទ្ធសាស្ត្រសុខាភិបាលថ្នាក់ជាតិសម្រាប់ជំងឺរបេង (ឆ្នាំ ២០២១-២០៣០) | IR ២.១ |
| • ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ឆ្នាំ ២០១៩-២០២៣) | IR ២.២ & IR ២.៣ |
| • ផែនការសកម្មភាពអន្តរក្រសួងរបស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ (ឆ្នាំ ២០១៧-២០២១) | IR ២.២ & IR ២.៣ |

<u>តួអង្គអភិវឌ្ឍន៍ផ្សេងទៀត</u>

អាទិភាពរបស់ទីភ្នាក់ងារ USAID ត្រូវបានបន្ស៊ីយ៉ាងជិតស្និទ្ធ និងសម្របសម្រួលជាមួយក្រុមតួអង្គអភិវឌ្ឍន៍ដែលចូលរួមយ៉ាងសកម្មដែលត្រូវបានបង្ហាញក្នុងតារាងទី ១១។ តាមរយៈវេទិកាសម្របសម្រួលផ្លូវការ និងក្រៅផ្លូវការជាច្រើនដែលប្រមូលផ្តុំនូវម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលដើម្បីធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែគូនានាចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចបាននូវសមិទ្ធផលកំណែទម្រង់សំខាន់ៗ។ នៅក្នុងវិស័យការពារកុមារ ទីភ្នាក់ងារ USAID ផ្តល់មូលនិធិដល់កិច្ចប្រជុំធ្វើផែនការ និងសម្របសម្រួល រវាងអង្គការសង្គមស៊ីវិល ម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលកម្ពុជា ដែលជាផ្នែកនៃកិច្ចខិតខំ

[91] រាជរដ្ឋាភិបាលកម្ពុជា បានបង្កើនមូលនិធិពី $278 លានដុល្លារនៅក្នុងឆ្នាំ2016 ទៅ $513 ដុល្លារក្នុងឆ្នាំ2020។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតមូលនិធិអប់រំពី $334.65 លានដុល្លារនៅក្នុងឆ្នាំ2014 ទៅ 827.37 លាននៅក្នុងឆ្នាំ2020។

ប្រឹងប្រែង ដើម្បីបង្កើតយន្តការសម្របសម្រួល និងជំរុញឲ្យមានគំនិតផ្តួចផ្តើមជាងមុនពាក់ព័ន្ធនឹងគោលនយោបាយ និងកំណែទម្រង់សំខាន់ៗ។ វេទិកាសម្របសម្រួលទាំងនេះគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ទីភ្នាក់ងារ USAID ដើម្បីកាត់បន្ថយហានិភ័យ ដែលមានកំណត់ក្នុងតារាងទី ៨។ ខណៈពេលដែលមានប្រភពជំនួយទ្វេភាគីផ្សេងទៀតនៅក្នុងវិស័យទាំងនេះ លក្ខណៈនិងនិរន្តរភាពរបស់ជំនួយទាំងនេះគឺមិនមានភាពច្បាស់លាស់ និងមិនត្រូវបានសម្របសម្រួលនៅក្នុងយន្តការបែបបុរាណនោះឡើយ។ ជំនួយរបស់ទីភ្នាក់ងារ USAID គឺផ្តោតលើការបង្កើនការពឹងផ្អែកលើខ្លួនឯងកាន់តែខ្លាំងឡើង និងសម្របសម្រួលពេញលេញជាមួយរាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយផ្សេងទៀត។

**តារាងទី ១១៖ សេចក្តីសង្ខេបអំពីកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលរបស់ម្ចាស់ជំនួយនៅក្នុងគោលបំណងអភិវឌ្ឍន៍ទី ២**

| វិស័យ | ដៃគូម្ចាស់ជំនួយសំខាន់ៗ | យន្តការសម្របសម្រួល |
|---|---|---|
| សុខាភិបាល | មូលនិធិសាកលសម្រាប់ជំងឺអេដស៍ របេង និងគ្រុនចាញ់ (GFATM) ធនាគារពិភពលោក, DFAT, ធនាគារ KfW អង្គការ GIZ អង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ និងអង្គការ UNAIDS | ក្រុមដៃគូអភិវឌ្ឍន៍វិស័យសុខាភិបាល ក្រុមការងារបច្ចេកទេសផ្នែកសុខាភិបាល |
| អប់រំ | សហភាពអឺរ៉ុប ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ស្ថានទូតស៊ុយអ៊ែត ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការ Global Partnership for Education (GPE) អង្គការយូនីសេហ្វ និងអង្គការយូណេស្កូ | ក្រុមការងារវិស័យអប់រំ ក្រុមការងារបច្ចេកទេសរួម |
| ការពារកុមារ | អង្គការយូនីសេហ្វ សហភាពអឺរ៉ុប ស្ថានទូតស៊ុយអ៊ែត និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) | ក្រុមការងារវិស័យការពារកុមារក្រៅផ្លូវការ |

## IR ២.១៖ កែលម្អគុណភាព និងការប្រើប្រាស់សេវាសុខាភិបាលអាទិភាព

អនុ-IR ២.១.១៖ កែលម្អសមត្ថភាពប្រព័ន្ធវិស័យសុខាភិបាល ក្នុងការផ្តល់សេវាមាតុភាព សុខភាពកុមារ និងអាហារូបត្ថម្ភ
អនុ-IR ២.១.២៖ កែលម្អសមត្ថភាពប្រព័ន្ធសុខាភិបាលក្នុងការស្វែងរក វិភាគ និងព្យាបាលជំងឺឆ្លង
អនុ-IR ២.១.៣៖ កែលម្អការទទួលបានដោយសមភាពនូវសេវា និងផលិតផលមានគុណភាព
អនុ-IR ២.១.៤៖ កែលម្អឥរិយាបថស្វែងរកសេវាសុខាភិបាលនៅក្នុងចំណោមប្រជាជនសំខាន់ៗ

IR ២.១ នឹងធ្វើអោយមាននិរន្តរភាព នៃការរីកចម្រើន នៅក្នុងកម្មវិធីសុខភាពមាតា និង កុមារ និងកម្មវិធីជំងឺឆ្លងផ្សេងៗ (គ្រុនចាញ់ របេង អេដស៍) ក៏ដូចជាធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវាបំពេញបន្ថែមតាមរយៈវិស័យឯកជន ដើម្បីបំពេញតាមតម្រូវការរបស់ប្រជាជនកម្ពុជា។ ទីភ្នាក់ងារ USAID នឹងប្រើប្រាស់យុទ្ធសាស្រ្តទំនាក់ទំនងក្នុងការផ្លាស់ប្តូរឥរិយាបថដើម្បីជួយប្រជាជនកម្ពុជាឱ្យធ្វើការទាមទារ និងស្វែងរកសេវាថែទាំសុខភាពប្រកបដោយគុណភាពពីវិស័យសាធារណៈ និងឯកជន។ ទីភ្នាក់ងារ USAID នឹងសហការជាមួយអ្នកផ្តល់ សេវាថែទាំសុខភាព និងមូលដ្ឋានសុខាភិបាលទាំងវិស័យរដ្ឋ និងឯកជននានា រួមទាំងការចូលរួមពីសមាគមវិជ្ជាជីវៈក្នុងដំណើរការរៀបចំបង្កើតគោលនយោបាយ ដើម្បីគាំទ្រដល់ការផ្តល់អាជ្ញាប័ណ្ណ និងបទប្បញ្ញត្តិនៃសេវាសុខភាពឱ្យកាន់តែប្រសើរឡើង ដើម្បីធានាឱ្យបាននូវសុវត្ថិភាពសាធារណៈ ព្រមទាំងលើកកម្ពស់ គុណភាពសេវាកម្មផងដែរ។ IR ២.១ នឹងរួមបញ្ចូលទាំងការផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាសុខភាពប្រកបដោយគុណភាពដល់ជនរងគ្រោះនៃអំពើហិង្សាយេនឌ័រផងដែរ។ លើសពីនេះទៅទៀត វិធីសាស្រ្តពង្រឹងប្រព័ន្ធអន្តរវិស័យនៅក្នុងគោលបំណងអភិវឌ្ឍន៍នេះ នឹងជួយជួយដោះស្រាយឧបសគ្គពាក់ព័ន្ធនឹងការិយាល័យធិបតេយ្យ និងរចនាសម្ព័ន្ធបានផងដែរ។

ការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងការទទួលបានសេវាសុខភាពជាអាទិភាពអាចនៅមានកម្រិត ឬប្រែក្លាយជាមានការលំបាកកាន់តែខ្លាំងឡើងដោយសារតែបញ្ហាអាកាសធាតុ ដែលរំខានដល់ការទទួលបានសេវាសុខភាព ឬបង្កើនបន្ទុកលើថវិកាសុខភាពសាធារណៈ។[92] មានឱកាសសម្របសម្រួលជាមួយក្រុមម្ចាស់ជំនួយអន្តរជាតិសំខាន់ៗ ដូចជា អង្គការសុខភាពពិភពលោក មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ និងអង្គការជាច្រើនទៀត ដើម្បីជួយពង្រឹងភាពធន់នៃកម្មវិធីសុខភាព។ លើសពីនេះទៅទៀត ការបញ្ចូលនូវការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីរក្សាការផ្តល់សេវាបន្ទាប់ពីមានហេតុការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចជា ទឹកជំនន់ភ្លាមៗ គឺអាចជាជម្រើសនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

[92] "ការវិភាគការគ្រប់គ្រងហានិភ័យអាកាសធាតុរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ/កម្ពុជា" ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ

## IR ២.២៖ ពង្រឹងអភិបាលកិច្ច និងគណនេយ្យភាពនៃប្រព័ន្ធសុខាភិបាល អប់រំ និងការពារកុមាររបស់ប្រទេសកម្ពុជា

> អនុ-IR ២.២.១៖ កែលម្អការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់សេវាសុខាភិបាល អប់រំ និងកម្មវិធីការពារកុមារ
> អនុ-IR ២.២.២៖ កែលម្អការសម្រេចចិត្តដោយផ្អែកលើទិន្នន័យរបស់រដ្ឋាភិបាល
> អនុ-IR ២.២.៣៖ ពង្រឹងសមត្ថភាពបុគ្គលិកផ្តល់សេវាសុខាភិបាល អប់រំ និងសង្គមកិច្ច

សម្រាប់ IR ២.២ ទីភ្នាក់ងារ USAID នឹងបន្តជំរុញការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះវិស័យសុខាភិបាល អប់រំ និងការពារកុមារ ដោយប្រើប្រាស់វិធីសាស្ត្រពង្រឹងប្រព័ន្ធ និងការតស៊ូមតិ ដើម្បីធ្វើការកៀរគរធនធានក្នុងស្រុកកាន់តែច្រើនឡើង (FSR)។ ទីភ្នាក់ងារ USAID នឹងធ្វើការងារដោយសហការយ៉ាងជិតស្និទ្ធជាមួយអង្គការមូលនិធិសកលដើម្បីជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់ (GFATM) នៅកម្ពុជា និងធ្វើការងារនៅក្រុមប្រឹក្សាសម្របសម្រួលប្រចាំប្រទេសនៃមូលនិធី GFATM។ មូលនិធិ GFATM ទទួលស្គាល់តម្លៃនៃការពង្រឹងប្រព័ន្ធសុខាភិបាលថាជាការអនុវត្តល្អនៅទូទាំងពិភពលោក។[93] ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ស្រុក និងខេត្តនៅក្នុងការសម្រេចលើកម្មវិធី និងថវិកាដែលបានបម្រុងទុកសម្រាប់ក្រសួងពាក់ព័ន្ធ។ ខណៈពេលដែលរចនាសម្ព័ន្ធ និងប្រព័ន្ធជាច្រើនសម្រាប់ការអនុវត្តត្រូវបានបង្កើតឡើង មានស្ថាប័នជាច្រើននៅមិនទាន់បានអនុវត្តពេញលេញ និងដោយជោគជ័យនូវរចនាសម្ព័ន្ធ និងប្រព័ន្ធនៅឡើយ។ នៅពេលដែលរដ្ឋបាលថ្នាក់ខេត្ត និងស្រុក ទទួលយកនូវទំនួលខុសត្រូវច្រើនជាងមុន ទីភ្នាក់ងារ USAID នឹងគាំទ្រភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងការពង្រឹងសមត្ថភាពរបស់អ្នកជំនាញផ្តល់សេវាសុខភាព អប់រំ និងសង្គមកិច្ច និងការប្រើប្រាស់ភស្តុតាង និងទិន្នន័យសម្រាប់ជាព័ត៌មាននៅក្នុងការធ្វើសេចក្តីសម្រេចចិត្តកំណត់អាទិភាពធនធានក្នុងស្រុកក្នុងវិស័យទាំងនេះ ព្រមទាំងកែលម្អការអនុវត្ត និងការប្រើប្រាស់ថវិកាឱ្យកាន់តែល្អប្រសើរឡើងនៃធនធានដែលមានស្រាប់។ ទីភ្នាក់ងារ USAID នឹងខិតខំប្រឹងប្រែងធ្វើការងារដើម្បីបង្កើនតម្លាភាព ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការសម្រេចចិត្ត ជាពិសេស ការចូលរួមរបស់ស្ត្រី និងប្រជាជនដែលបាត់បង់ឱកាស និងគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ (រួមទាំងធនធានវិស័យឯកជន) ដើម្បីបម្រើប្រជាជនកម្ពុជា។ គោលបំណងរបស់ទីភ្នាក់ងារ USAID គឺត្រូវភ្ជាប់ទំនាក់ទំនងដោយផ្ទាល់នូវអ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រង ជាមួយអ្នកដែលមានទំនួលខុសត្រូវក្នុងការផ្តល់សេវា ដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជាអាចចូលរួមប្រកបដោយសមធម៌ និងទទួលបានអត្ថប្រយោជន៍ពីក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដែលបង្កើនគុណភាពនៃការផ្តល់សេវា ផ្តល់ការត្រួតពិនិត្យគុណភាព និងបង្កើនលទ្ធភាពក្នុងការទទួលបានសេវាគោលដៅប្រកបដោយសមធម៌។

ការពិនិត្យជាប្រព័ន្ធបានរកឃើញថា ឥទ្ធិពលវិជ្ជមាននៃវិមជ្ឈការទៅលើវិស័យសុខាភិបាល គឺរួមចំណែកធ្វើឱ្យមានការកើនឡើងនូវការចូលរួមរបស់សហគមន៍ចំពោះការដោះស្រាយបញ្ហាសុខភាព។ លើសពីនេះទៅទៀត ការបង្កើនហិរញ្ញប្បទានសុខាភិបាលនៅកម្រិតមូលដ្ឋាន និងការកាត់បន្ថយការចំណាយប្រាក់ពីហោប៉ៅ

[93] "ប្រព័ន្ធមានភាពធន់ និងនិរន្តរភាពសម្រាប់វិស័យសុខាភិបាល" អង្គការ GFATM ឆ្នាំ2020

បង្ហាញថាការគាំទ្ររបស់ទីភ្នាក់ងារ USAID សម្រាប់កិច្ចខិតខំប្រឹងប្រែងទាំងនេះគឺមានភាពសមរម្យ ហើយអាចជួយជំរុញការពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើខ្លួនឯងផងដែរ។[94]

## IR ២.៣៖ កែលម្អគុណភាពសេវាអប់រំ និងការពារកុមារ

អនុ-IR ២.៣.១៖ កែលម្អសមត្ថភាពប្រព័ន្ធការពារកុមារ និងអបរំ ក្នុងការផ្តល់សេវាមានគុណភាពខ្ពស់
អនុ-IR ២.៣.២៖ កែលម្អសមត្ថភាពរបស់បុគ្គល សហគមន៍ និងស្ថាប័ន ដើម្បីការពារកុមារពីអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច
អនុ-IR ២.៣.៣៖ កែលម្អការទទួលបានដោយសមភាពនូវសេវាអប់រំ និងការពារកុមារមានគុណភាពខ្ពស់

សម្រាប់វិស័យអប់រំ និងការពារកុមារ ទីភ្នាក់ងារ USAID នឹងផ្តោតលើការបង្កើន និងពង្រឹងសមត្ថភាពប្រព័ន្ធផ្តល់សេវារបស់រដ្ឋាភិបាល ព្រមទាំងកសាងសមត្ថភាព និងជំនាញរបស់អ្នកអប់រំវិជ្ជាជីវៈ និងអ្នកផ្តល់សេវាសង្គមកិច្ចឱ្យមានលទ្ធភាពកាន់តែល្អប្រសើរនៅក្នុងការផ្តល់សេវាប្រកបដោយគុណភាពសម្រាប់កុមារទាំងអស់ ជាពិសេស កុមារមានពិការ និងកុមារងាយរងគ្រោះបំផុត។ ទីភ្នាក់ងារ USAID នឹងធ្វើការងារដោយបង្កើតភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល វិស័យឯកជន និងសហគមន៍ ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាប្រកបដោយគុណភាព និងសមធម៌ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័នរដ្ឋ និងឯកជននៅក្នុងការផ្តល់សេវាគាំពារកុមាររងគ្រោះដោយសារតែអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចផងដែរ។ សមត្ថភាពគ្រូបង្រៀនមានកម្រិតទាប នៅតែជាឧបសគ្គចំពោះការធ្វើកំណែទម្រង់វិស័យអប់រំ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។[95] គុណភាពអប់រំមិនល្អ បានប៉ះពាល់ដល់កុមារទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ទោះបីជាក្មេងស្រីសម្រេចបានសមភាពផ្នែកអប់រំជាមួយក្មេងប្រុសនៅថ្នាក់បឋមសិក្សាក៏ដោយ ក៏ប៉ុន្តែក្មេងស្រីបានបោះបង់ការសិក្សាដោយសារតែការរៀបការវ័យក្មេង និងបន្ទុកការងារផ្ទះ។ នៅថ្នាក់មធ្យមសិក្សាបឋមភូមិ ក្មេងប្រុសបោះបង់ការសិក្សាច្រើនជាងក្មេងស្រីដោយសារតែមានការរំពឹងទុកខ្ពស់ចំពោះពួកគេនៅក្នុងការធ្វើការងារ។ កម្មវិធីអប់រំត្រូវកំណត់គោលដៅលើក្មេងប្រុស និងក្មេងស្រី និងដោះស្រាយឧបសគ្គជាក់លាក់ផ្នែកយេនឌ័រ ដែលមានឥទ្ធិពលលើបំណងប្រាថ្នានៃការអប់រំរបស់ពួកគេ។[96]

នៅក្នុង IR នេះ ទីភ្នាក់ងារ USAID មានបំណងធ្វើការកែលម្អលទ្ធផលសិក្សាជាមូលដ្ឋានសម្រាប់កុមារ តាមរយៈការបង្កើនសមត្ថភាពរបស់រដ្ឋាភិបាល ពង្រឹងការគ្រប់គ្រងនៅតាមសាលារៀន និងបង្កើនគណនេយ្យភាពសង្គមរវាងសាលារៀន និងសហគមន៍ បង្កើនភាពធន់នៃប្រព័ន្ធអប់រំនៅក្នុងការផ្តល់សេវាអប់រំប្រកបដោយសមធម៌សម្រាប់សិស្សទាំងអស់ និងបង្កើនលទ្ធភាពទទួលបានដោយសមធម៌នូវសេវាអប់រំប្រកបដោយគុណភាពសម្រាប់កុមារដែលមានការអភិវឌ្ឍយឺតយ៉ាវ និងមានពិការភាពតាមរយៈប្រព័ន្ធរដ្ឋាភិបាល។ កិច្ចខិតខំប្រឹងប្រែងនៅក្នុងការពង្រឹងសេវាគាំពារកុមារនឹងពង្រឹងបន្ថែមលើការវិនិយោគរបស់ទីភ្នាក់ងារ USAID ចាប់តាំងពីឆ្នាំ ២០០៩ មក គឺដើម្បីលើកកម្ពស់ការថែទាំ និងការគាំពារកុមារនៅក្នុងប្រទេសកម្ពុជា។ ទី

[94] Cobos Muñoz D, et al. "វិមជ្ឈការនៃប្រព័ន្ធសុខាភិបាលនៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម៖ ការពិនិត្យមើលជាប្រព័ន្ធ" Int. J. Pub. សុខភាព ឆ្នាំ2017។
[95] "ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ2019-2023" ក្រសួងអប់រំ យុវជន និងកីឡានៃរាជរដ្ឋាភិបាលកម្ពុជា ខែមិថុនា ឆ្នាំ2019។
[96] "ហេតុអ្វីបានជាក្មេងប្រុសបោះបង់ការសិក្សានៅថ្នាក់មធ្យមសិក្សាបឋមភូមិនៅកម្ពុជា? អង្គការយូនីសេហ្វកម្ពុជានៅខែសីហា ឆ្នាំ2020

ភ្នាក់ងារ USAID នឹងធ្វើការងារដោយបង្កើតភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល ដើម្បីកាត់បន្ថយចំនួនកុមារដែលធំធាត់ដោយពុំមានការថែទាំតាមគ្រួសារប្រកបដោយសុវត្ថិភាពនិងការចិញ្ចឹមបីបាច់ ត្រឹមត្រូវ ។ ទីភ្នាក់ងារ USAID នឹងធ្វើការដើម្បីការពារការបំបែកកុមារពីគ្រួសារដែលមិនចាំបាច់ កាត់បន្ថយចំនួនកុមារដែលរស់នៅមណ្ឌលកុមារកំព្រា និងស្ថាប័នថែទាំផ្សេងទៀត បង្កើនចំនួនកុមារដែលបានធ្វើ សមាហរណកម្មទៅក្នុងគ្រួសារសមរម្យ ដោយមានការគាំពារ និងជាអចិន្ត្រៃយ៍ និងកាត់បន្ថយចំនួនមណ្ឌលកុមារកំព្រា និងគ្រឹះស្ថានថែទាំផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។ ការយឺតយ៉ាវយ៉ាងខ្លាំងនៅក្នុងរៀបចំបង្កើត និងការអនុម័តលើគោលការណ៍ណែនាំសំខាន់ៗ បាននាំឱ្យមានទិដ្ឋភាពបែកខ្ញែកដែលមានកម្រិតគុណភាពខុសៗគ្នា។ ដោយហេតុថា កិច្ចការគាំពារកុមារគឺជាមានពាក់ព័ន្ធនឹងក្រសួងស្ថាប័នច្រើន ដូច្នេះចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីប្រមូលផ្តុំក្រសួងស្ថាប័នទាំងអស់ដែលពាក់ព័ន្ធនឹងការថែទាំ ការអប់រំ និងសុខភាពរបស់កុមារមានពិការភាព។

ឧត្តមភាពប្រៀបធៀបរបស់ទីភ្នាក់ងារ USAID នៅក្នុងវិស័យសុខាភិបាល អប់រំ និងគាំពារកុមារ

តាមរយៈជំនួយគាំពារកុមារជាង ៣០ ឆ្នាំ ប្រកបដោយគុណភាពខ្ពស់ពីសំណាក់ទីភ្នាក់ងារ USAID កន្លងមកនេះ ប្រទេសកម្ពុជាសម្រេចបាននូវការធ្វើឱ្យប្រសើរយ៉ាងខ្លាំងនូវលទ្ធផលក្នុងវិស័យសុខាភិបាល អប់រំ និងគាំពារកុមារ។ ដោយមានយន្តការដ៏រឹងមាំក្នុងការធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយ គោលការណ៍ណែនាំ និងស្តង់ដារដើម្បីមានគុណភាពដែលបានបញ្ជ្រាប ដៃគូនានារបស់ទីភ្នាក់ងារ USAID បានពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដោយជោគជ័យនៅក្នុងផ្នែកស្នូល និងមានទំនាក់ទំនងរយៈពេលវែងជាមួយអង្គភាពសំខាន់ៗនៃក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ទីភ្នាក់ងារ USAID បានកំណត់ឱកាសគាំទ្ររាជរដ្ឋាភិបាលកម្ពុជានៅក្នុងការពង្រឹងការអនុវត្ត និងការអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិ ការពង្រឹងការសម្របសម្រួល និងការកសាងសមត្ថភាពរបស់ រាជរដ្ឋាភិបាលកម្ពុជា រួមទាំងផ្នែកលេខនព្វន្ត អក្ខរកម្មជាមូលដ្ឋាន និងការគាំទ្រកំណែទម្រង់ការថែទាំ។ ទីភ្នាក់ងារ USAID បានប្រមូលផ្តុំប្រកបដោយប្រសិទ្ធភាពនូវអង្គការសង្គមស៊ីវិល ដៃគូវិស័យឯកជន ម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលកម្ពុជាឱ្យរួមគ្នារៀបចំបង្កើត និងកំណត់កិច្ចអន្តរាគមន៍ដើម្បីដោះស្រាយអាទិភាពកំណែទម្រង់សំខាន់ៗ។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុក ទីភ្នាក់ងារ USAID ជាដៃគូយុទ្ធសាស្ត្រដ៏សំខាន់នៅក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល អប់រំ និងគាំពារកុមារ ដែលលើកកម្ពស់សេវាប្រកបដោយគុណភាពដល់ប្រជាជនកម្ពុជា។

តើទីភ្នាក់ងារ USAID នឹងកំណត់ឡើងវិញនូវទំនាក់ទំនងជាមួយតួអង្គក្នុងស្រុក ដើម្បីកែលម្អវិស័យសុខាភិបាល អប់រំ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជាឱ្យល្អប្រសើរយ៉ាងដូចម្តេច?

ប្រទេសកម្ពុជា សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការផ្លាស់ប្តូរពីការពឹងផ្អែកយ៉ាងខ្លាំងលើសលប់លើអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការផ្តល់សេវារដ្ឋាភិបាលយ៉ាងធំធេញដល់ប្រជាជនកម្ពុជា។ ទីភ្នាក់ងារ USAID បានផ្តួចផ្តើមដំណើរការការប្រឹក្សាយោបល់ដើម្បីកំណត់រកឧបសគ្គសំខាន់ៗ និងរៀបចំបង្កើតផែនការដើម្បីដោះស្រាយកំណែទម្រង់សំខាន់ៗ និងពង្រឹងប្រព័ន្ធគោល

នយោបាយ និងអភិបាលកិច្ចសំដៅកែលម្អគុណភាពសេវាកម្ម។ កិច្ចការនេះបានបង្កើតទំនាក់ទំនងកាន់តែធំធេងនៅក្នុងវិស័យទាំងនេះ និងការធ្វើការងារក្នុងភាពជាដៃគូដ៏រឹងមាំ។ ដោយធ្វើការងារនៅក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ការកែលម្អគុណភាពបានបង្កើនលទ្ធភាពទទួលបានសេវាប្រកបដោយគុណភាពនៅតាមមូលដ្ឋានសាធារណៈ។

ការចូលរួមពីវិស័យឯកជនក៏នៅតែជាវិធីសាស្ត្រជាមូលដ្ឋាននៅក្រោម គោលបំណងអភិវឌ្ឍន៍ទី ២។ ប្រជាជនកម្ពុជាភាគច្រើនបន្តស្វែងរកសេវាសុខភាព ហើយប្រជាជនកាន់តែច្រើនឡើងកំពុងតែស្វែងរកសេវាអប់រំពីវិស័យឯកជន ដោយសារតែមានការយល់ឃើញថាសេវារបស់វិស័យសាធារណៈមានគុណភាពទាប ដែលបណ្តាលឱ្យវិស័យឯកជនមានការកើនឡើង និងពុំមានការគ្រប់គ្រង។ វិធីសាស្ត្ររបស់ទីភ្នាក់ងារ USAID នឹងរៀបចំបញ្ជីឈ្មោះតួអង្គវិស័យឯកជន បង្កើតស្តង់ដារវិជ្ជាជីវៈ និងស្តង់ដារទទួលស្គាល់គុណភាព ព្រមទាំងផ្តល់ឧបករណ៍ឌីជីថល និងការបណ្តុះបណ្តាលដើម្បីបង្កើនការរកឃើញនូវករណី សេវាបញ្ជូនបន្ត ការព្យាបាល និងការតាមដាន។ ទីភ្នាក់ងារ USAID បន្តមើលឃើញពីតម្រូវការនៅក្នុងការបន្តចូលរួម និងការធ្វើការងារក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងអង្គការផ្អែកលើជំនឿសាសនាដើម្បីកសាងសមត្ថភាពរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងវិស័យសំខាន់ៗ ដែលធនធានមនុស្សនៅមានកម្រិត រួមទាំងការគាំទ្រដល់កុមារមានពិការផងដែរ។ ទីភ្នាក់ងារ USAID នឹងជំរុញយន្តការដែលមានស្រាប់ និងបង្កើតភាពជាដៃគូថ្មីជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយធ្វើការងារដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូទ្វេភាគី និងពហុភាគីដែលមានគោលបំណងដូចគ្នាសំដៅពង្រីកការផ្ទេរការវិនិយោគរបស់ទីភ្នាក់ងារ USAID ទៅជាភាពម្ចាស់ការរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងលើកកម្ពស់ការពង្រីក និងការដាក់បញ្ចូលប្រជាជនដែលមិនត្រូវបានគេគិតគូរផងដែរ។

## គោលបំណងអភិវឌ្ឍន៍ទី ៣៖ ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល

ខណៈដែលប្រទេសកម្ពុជាមានអង្គការសង្គមស៊ីវិលដ៏សកម្ម កិច្ចប្រជុំពិគ្រោះជាមួយភាគីពាក់ព័ន្ធរបស់ទីភ្នាក់ងារ USAID បានបង្ហាញថា ក្តីកង្វល់អំពីលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងអភិបាលកិច្ច គឺជាប្រធានបទដែលត្រូវបានពិភាក្សាញឹកញាប់បំផុតក្នុងចំណោមអ្នកចូលរួម ដោយបានបង្ហាញពីការយល់ដឹងនៅក្នុងចំណោមសាធារណជនទូទៅអំពីបញ្ហាទាំងនេះ និងមានបំណងចង់ឱ្យមានការដោះស្រាយក្តីកង្វល់ទាំងនេះ។ នៅក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាត្រូវបានចាត់ចំណាត់ថ្នាក់ថា “ពុំមានសេរីភាព” នៅក្នុងរបាយការណ៍ “សេរីភាពក្នុងពិភពលោក” ការសិក្សាប្រចាំឆ្នាំរបស់អង្គការ Freedom House ស្តីពីសិទ្ធិនយោបាយ និងសេរីភាពពលរដ្ឋទូទាំងពិភពលោក ដោយបានដាក់ពិន្ទុ ៥ លើ ៤០ សម្រាប់សិទ្ធិនយោបាយ និង ២០ លើ ៦០ សម្រាប់សេរីភាពពលរដ្ឋ។[97] លើសពីនេះទៅទៀត យោងតាមអង្គការតម្លាភាពអន្តរជាតិ កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៦២ ក្នុងចំណោមប្រទេសចំនួន ១៨០ ផ្អែកសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ[98] ហើយបានដាក់ពិន្ទុទាបជាប់ជាបន្តបន្ទាប់ចាប់តាំងទទួលបានសន្ទស្សន៍នោះមក។

[97] “កម្ពុជា“ អង្គការ Freedom House។

[98] “ការងាររបស់យើងនៅក្នុងប្រទេសកម្ពុជា“ អង្គការតម្លាភាពអន្តរជាតិ។

ការកម្រិតលើសេរីភាពនៃការបញ្ចេញមតិ និងការជួបប្រជុំ បានបន្តមាននៅក្នុងអំឡុងពេល ហើយនៅក្នុងករណីខ្លះ មានសភាពកាន់តែធ្ងន់ធ្ងរខ្លាំងដោយសារតែជំងឺកូវីដ-១៩។[99,100]

យោងតាមគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា មានអង្គការសង្គមស៊ីវិល និងសមាគមដែលបានចុះបញ្ជីប្រមាណ ៣.៥០០ នៅក្នុងប្រទេសកម្ពុជា (ទំនងជាមានសកម្មភាពតិចជាងពាក់កណ្ដាល) ដែលភាគច្រើនជាអង្គការក្នុងស្រុក។[101] ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ សមត្ថភាពរបស់អង្គការសង្គមស៊ីវិលក្នុងស្រុកមានការរីកចម្រើនយ៉ាងខ្លាំង។[102] អង្គការសិទ្ធិមនុស្សបានបង្កើនជំនាញវិជ្ជាជីវៈក្នុងការប្រមូលទិន្នន័យ និងការតាមដានទាក់ទងនឹងបញ្ហា ដូចជា សម្បទានដីសេដ្ឋកិច្ច លក្ខខណ្ឌពន្ធនាគារ និងសេរីភាពនៃការបញ្ចេញមតិ ខណៈដែលអង្គការផ្តល់សេវាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកែលម្អសេវាសុខភាព និងអប់រំសម្រាប់ប្រជាជនកម្ពុជាទូទាំងប្រទេស។ ទន្ទឹមនឹងនេះ ក៏មានអ្នកផ្តល់សេវាកសាងសមត្ថភាពក្នុងស្រុកជាច្រើនដែលកំពុងជួយបង្កើនសមត្ថភាពរបស់អង្គការសង្គមស៊ីវិល និងវិស័យសាធារណៈ និងឯកជននៅកម្ពុជា។ ទោះបីជាមានចំណាប់អារម្មណ៍រួមជាច្រើននៅក្នុងចំណោមអង្គការសង្គមស៊ីវិលដ៏សកម្មរបស់កម្ពុជាក៏ដោយ ក៏ការខ្វះការសហការគ្នានៅក្នុងចំណោមតួអង្គទាំងនេះរារាំងដល់លទ្ធផលនៃការអភិវឌ្ឍនៅទូទាំងវិស័យបច្ចេកទេសផ្សេងៗ ដូចជា ការយល់ឃើញខុសគ្នារវាងការផ្តល់សេវា និងក្រុមអ្នកតស៊ូមតិ។ អង្គការផ្តល់សេវាអាចមានការស្ទាក់ស្ទើរនៅក្នុងការលើកឡើងដោយបើកចំហនូវបញ្ហារសើបជាងអង្គការតស៊ូមតិ ។ ជារឿយៗ អង្គការតស៊ូមតិទាំងនេះ ត្រូវបានពិនិត្យបច្ច័យយ៉ាងដិតដល់។ ហេតុដូច្នេះ ខណៈពេលដែលបញ្ហាទាក់ទងនឹងអំពើពុករលួយ ការរេចរិលបរិស្ថាន និងគណនេយ្យភាពរបស់រដ្ឋាភិបាលមានលក្ខណៈអន្តរវិស័យ កម្រនឹងមានអន្តរកម្មដ៏មានអត្ថន័យរវាងអង្គការសង្គមស៊ីវិល ដែលធ្វើការនៅក្នុងវិស័យបច្ចេកទេសផ្សេងៗគ្នាណាស់។ ការកសាងសម្ព័ន្ធបែបនេះក៏នឹងជួយឱ្យរាជរដ្ឋាភិបាលធ្វើការពិចារណា និងដោះស្រាយចំពោះធាតុចូល និងមតិស្ថាបនារបស់សង្គមស៊ីវិលចំពោះគោលនយោបាយ ឬការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយភាពគ្រុងជ្រោយ។ អភិបាលកិច្ចប្រកបដោយគណនេយ្យភាព និងតម្លាភាព ស្វាគមន៍និងលើកទឹកចិត្តដល់វិស័យសង្គមស៊ីវិលដ៏រឹងមាំ និងប្រព័ន្ធផ្សព្វផ្សាយសេរី និងបើកចំហ។ យោងតាមផែនទីបង្ហាញផ្លូវថ្នាក់ជាតិ J2SR សមត្ថភាពអង្គការសង្គមស៊ីវិលនៅកម្ពុជា ក៏មានកម្រិតទាបជាងកម្រិតមធ្យមភាគសកលផងដែរ។[103] ជាការពិតណាស់ អង្គការសង្គមស៊ីវិលមានកម្រិតសម្រាប់ផ្នែកជាច្រើន។[104] លើសពីនេះទៅទៀត ប្រទេសកម្ពុជាមានការថយចុះនូវសេរីភាពសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ដូចដែលបានបង្ហាញដោយតារាងម៉ាទ្រីសបន្ទាប់បន្សំ ពិន្ទុសន្ទស្សន៍សេរីភាពសារព័ត៌មាន ដោយមានពិន្ទុ ៤៥ លើ ១០០ (ពិន្ទុ 0 គឺល្អបំផុត)។[105] ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការវិភាគទិន្នន័យពីកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ "អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ" គឺ

---

[99] មាត្រដ្ឋានបន្ទាប់បន្សំ៖ សន្ទស្សន៍ប្រជាធិបតេយ្យដោយការបោះឆ្នោត សេរីភាពនៃការបញ្ចេញមតិ ឆ្នាំ2019 ពិន្ទុគឺ 0.314 លើ 1។ និន្នាការនេះប្រែជាកាន់តែអាក្រក់អន់ខ្លាំងឡើងជាងមួយទសវត្សរ៍កន្លងទៅនេះ។

[100] "កម្ពុជា៖ ជំងឺកូវីដ-19 Spurs Bogus ការចាប់ខ្លួន "ព័ត៌មានមិនពិត" អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី29 ខែមេសាឆ្នាំ2020។

[101] "គេហទំព័រ" គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា។

[102] ការបង្កើនសមត្ថភាពអង្គការសង្គមស៊ីវិលពីឆ្នាំ2017-2020 សកម្មភាពពង្រឹងសង្គមស៊ីវិលកម្ពុជា ឆ្នាំ2020។

[103] មាត្រដ្ឋានបន្ទាប់បន្សំស្តីពីលទ្ធភាពហិរញ្ញវត្ថុរបស់អង្គការសង្គមស៊ីវិលក៏មានកម្រិតមធ្យមផងដែរ៖ ពិន្ទុឆ្នាំ 2018 គឺ 5.2 លើ 7 ។ ប្រភព៖ FHI 360 CSO Sustainability Index។

[104] "ការបិទលំហនៅកម្ពុជា-ការវាយតម្លៃសមត្ថភាពប្រតិបត្តិការរបស់សង្គមស៊ីវិល"វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិឆ្នាំ2018

[105] "Reporters Without Borders," Press Freedom Index, 2020.

ជាប្រធានបទមួយក្នុងចំណោមប្រធានបទពីរ ដែលឱកាសមានច្រើនជាងបញ្ហាប្រឈម ដោយបានបង្ហាញពីផ្នែកផ្តោតការយកចិត្តទុកដាក់ខ្លាំងសម្រាប់ទីភ្នាក់ងារ USAID និងទិសដៅយុទ្ធសាស្ត្រដែលអាចសម្រេចបាន។[106] ជាការពិតណាស់ ទីភ្នាក់ងារ USAID បានគាំទ្រអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាអស់រយៈពេលជាយូរយារណាស់មកហើយ ហើយការវិនិយោគរបស់យើងបាននាំឱ្យមានការបង្កើនសមត្ថភាព ទោះបីជាមានបញ្ហាប្រឈមក៏ដោយ។ ទីភ្នាក់ងារ USAID នឹងបន្តធ្វើការងារដោយផ្អែកលើភាពជោគជ័យនេះ។

<u>*សម្មតិកម្មនៃការអភិវឌ្ឍ*</u>

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមជាច្រើនទាំងអស់នេះ ទីភ្នាក់ងារ USAID នឹងផ្តល់អាទិភាពដល់ "គោលបំណងអភិវឌ្ឍន៍ទី ៣៖ ការពារសិទ្ធិមនុស្ស និងលើកកម្ពស់គណនេយ្យភាពរដ្ឋាភិបាល" ដែលភ្ជាប់ទំនាក់ទំនងទៅនឹងគោលដៅ CDCS ដោយគាំទ្រដល់លទ្ធផលនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលមានភាពចាំបាច់សម្រាប់ការបង្កើនវិបុលភាព និងភាពធន់ក្នុងប្រទេស និងដើម្បីពង្រឹងអភិបាលកិច្ចតាមរយៈគណនេយ្យភាពសង្គម។ វិធីសាស្ត្រ ថ្មីនេះនឹងផ្តោតលើការកាត់បន្ថយលំហស៊ីវិលដែលត្រូវបានបិទខ្ទប់កាន់តែច្រើនឡើងនៅក្នុងប្រទេស។

ទីភ្នាក់ងារ USAID មានគោលបំណងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងការចូលរួមយ៉ាងសកម្មនៅក្នុងការកសាងការគាំទ្រវិស័យសាធារណៈ និងឯកជនកាន់តែទូលំទូលាយដើម្បីអភិបាលកិច្ចកាន់តែមានការឆ្លើយតបខ្លាំងឡើង ខណៈពេលដែលគាំទ្រដល់ការការពារសិទ្ធិ។ ឱនភាពដ៏ធំបំផុតរបស់កម្ពុជានៅលើផែនទីបង្ហាញផ្លូវថ្នាក់ជាតិ J2SR គឺជាការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះ *រដ្ឋាភិបាលបើកចំហ និងលទ្ធិប្រជាធិបតេយ្យសេរី*។ គោលបំណងអភិវឌ្ឍន៍នេះផ្តល់ការបំពេញបន្ថែម និងពង្រឹងគ្នាទៅវិញទៅមកនូវលទ្ធផលរំពឹងទុកក្នុងគោលបំណងគាំទ្រការតស៊ូមតិដើម្បីសិទ្ធិមនុស្ស និងបង្កើនគណនេយ្យភាពរបស់រដ្ឋាភិបាល ដោយជំរុញគោលដៅរបស់ទីភ្នាក់ងារ USAID ក្នុងការជួយកម្ពុជាសម្រេចឱ្យបាននូវការប្តេជ្ញាចិត្តរដ្ឋាភិបាលកាន់តែជាន់ខ្ពស់ថែមទៀត។ សមិទ្ធិផលនៃគោលបំណងអភិវឌ្ឍន៍ទី ៣ ត្រូវបានភ្ជាប់ទំនាក់ទំនងទៅនឹងកិច្ចខិតខំប្រឹងប្រែងអន្តរវិស័យនៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ១ និង គោលបំណងអភិវឌ្ឍន៍ទី ២ ដើម្បីគាំទ្រដល់ទំនួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការផ្តល់សេវាកម្មសាធារណៈប្រកបដោយគុណភាព។

សម្មតិកម្មនៃការអភិវឌ្ឍនៃគោលបំណងអភិវឌ្ឍន៍ទី ៣ បានលើកឡើងថា *ប្រសិនបើ* ប្រជាជនកម្ពុជាកាន់តែច្រើនប្រើប្រាស់យន្តការដែលមាន សម្រាប់បង្កើននិងសម្របសម្រួលសកម្មភាពជំរុញដំណើរការប្រជាធិបតេយ្យ ការពារសិទ្ធិ និងតាមដានស្ថាប័នសាធារណៈ *នោះ* យន្តការទាំងនេះនឹងជំរុញឱ្យមានការឆ្លើយ

[106] "USAID/ឯកសារសង្ខេបវិភាគយុទ្ធសាស្ត្រសហប្រតិបត្តិការអភិវឌ្ឍន៍ថ្នាក់ជាតិប្រទេសកម្ពុជា៖ ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ និងអភិបាលកិច្ច"។ ក្រុមហ៊ុន Social Impact, Inc. ឆ្នាំ2020។

តបពីសំណាក់រដ្ឋាភិបាលកាន់តែច្រើនឡើងចំពោះប្រជាជន និងគោរពសិទ្ធិពលរដ្ឋនៅក្រោមច្បាប់ជាតិកម្ពុជា រួមទាំងរដ្ឋធម្មនុញ្ញរបស់កម្ពុជា។

ទីមួយ អ្នកការពារសិទ្ធិ និងអង្គការដែលមានការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចនៅក្នុងការទាមទារសិទ្ធិ (*ឧទាហរណ៍* សហជីពការងារ ក្រុមមូលដ្ឋានដែលពាក់ព័ន្ធនៅក្នុងជម្លោះដីធ្លី និងក្រុមផ្សេងៗទៀត) គួរតែត្រូវបានផ្តល់សិទ្ធិអំណាច។ ក្រុមទាំងនេះគួរតែទទួលបានលើកទឹកចិត្តឱ្យធ្វើការរួមគ្នា និងពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីការការពារសិទ្ធិមនុស្សកាន់តែខ្លាំង ដែលគាំទ្រដល់ J2SR របស់កម្ពុជា (IR ៣.១)។ ទីពីរ សកម្មភាពកំណែទម្រង់គួរតែមានការគាំទ្រយ៉ាងទូលំទូលាយដល់ក្រុមជាច្រើន រួមទាំង អង្គការមិនមែនរដ្ឋាភិបាលតាមបែបប្រពៃណី ក៏ដូចជាស្ត្រី យុវជន ប្រជាជនដែលមិនត្រូវបានគិតគូរ និងអង្គការដែលលើកកម្ពស់ផលប្រយោជន៍របស់ពួកកាត់។ ឧទាហរណ៍នៃចំនួនប្រជាជនដែលមិនត្រូវបានគិតគូរ រួមមានក្រុមអ្នកស្រលាញ់ភេទដូចគ្នា ក្រុមជនជាតិភាគតិច និងក្រុមសាសនា និងជនមានពិការភាព (IR ៣.២)។ ទីបី គណនេយ្យភាពសង្គមត្រូវតែពង្រឹងបន្ថែម តាមរយៈការពង្រីកលទ្ធភាពទទួលបានព័ត៌មានត្រឹមត្រូវ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យរបស់ប្រជាជនកម្ពុជា និងតាមរយៈការផ្តល់លទ្ធភាពត្រួតពិនិត្យរបស់ប្រជាពលរដ្ឋទៅលើសេវាសាធារណៈ (IR ៣.៣)។ គណនេយ្យភាពសង្គម រួមមានការវិនិយោគអន្តរវិស័យនៅក្រោមគោលបំណងអភិវឌ្ឍន៍ទី ១ និង គោលបំណងអភិវឌ្ឍន៍ទី ២ ដើម្បីលើកកម្ពស់អភិបាលកិច្ចប្រកបដោយតម្លាភាពនៅក្នុងវិស័យត្រូវធ្វើកំណែទម្រង់ (ឧទាហរណ៍ ការអប់រំ)។ គោលនយោបាយថ្មីៗដែលធ្វើប្រតិភូកម្មមុខងារសុខាភិបាល អប់រំ និងមុខងារផ្សេងទៀតទៅឱ្យរដ្ឋាភិបាលថ្នាក់ក្រោមជាតិ អាចផ្តល់ឱកាសឱ្យទីភ្នាក់ងារ USAID ចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជានៅក្នុងការបន្តគណនេយ្យភាពសម្រាប់សេវាសាធារណៈ។

ដូចដែលបានបង្ហាញនៅក្នុងផែនទីបង្ហាញផ្លូវថ្នាក់ជាតិ J2SR ហើយថា ប្រទេសកម្ពុជាមានពិន្ទុខ្ពស់ជាកម្រិតមធ្យមផ្នែក *គម្លាតយេនឌ័រសេដ្ឋកិច្ច* (0,៧៤)។ គួរឱ្យសោកស្តាយ ផលសេដ្ឋកិច្ចសម្រាប់ស្ត្រី មិនត្រូវបានឆ្លុះបញ្ចាំងដោយការចូលរួមនៅក្នុងនយោបាយនោះទេ។ ពិន្ទុសន្ទស្សន៍សម្រាប់ការផ្តល់សិទ្ធិអំណាចនយោបាយដល់ស្ត្រី ឆ្នាំ ២០១៩ របស់អង្គការ Varieties of Democracy (V-Dem) នៅតែមានកម្រិតទាបគឺ 0,៥៨៩ លើ ១ ខណៈដែលពិន្ទុសម្រាប់អំណាចចែកចាយតាមយេនឌ័រ (V-Dem) ឆ្នាំ ២០១៩ គឺត្រឹមតែ -0,៣ (0 ជាមធ្យម) ជាមួយនឹងនិន្នាការកាន់តែខ្សោយខ្លាំងបំផុតទៅតាមពេលវេលា។[107] ទិន្នន័យអំពីការវិភាគការអភិវឌ្ឍយេនឌ័រ និងបរិយាបន្ន របស់ទីភ្នាក់ងារ USAID ក៏បានរៀបរាប់លម្អិតផងដែរថា បទដ្ឋានយេនឌ័រមានការរឹតត្បិត បន្ថែមពីលើការយល់ឃើញថាមានកម្រិតទាប (ដោយទាំងបុរស និងស្ត្រីខ្លួនឯង) នៃសមត្ថភាពរបស់ស្ត្រីក្នុងការកាន់តួនាទីធ្វើសេចក្តីសម្រេចចិត្ត គឺជាកត្តារួមចំណែកយ៉ាងសំខាន់ដល់ស្ត្រីនៅខាងក្រៅខ្សែបន្ទាត់នៃការចូលរួមរបស់ពលរដ្ឋ។[108] ប្រទេសកម្ពុជាមានពិន្ទុទាបជាងកម្រិតមធ្យមសម្រាប់*សមភាពក្រុមសង្គម* (0,៣៤) និងចំណាត់ថ្នាក់ទាប គឺ ១២១ លើ ១៥៧ ចំពោះការប្តេជ្ញាចិត្តនៅក្នុងការកាត់បន្ថយសន្ទស្សន៍វិសមភាព របស់អង្គការ Oxfarm។[109] បញ្ហាប្រឈមផ្នែកបរិយាបន្ន នៅតែបន្តមានសម្រាប់ជនជាតិដើមភាគ

---

[107] មាត្រដ្ឋានបន្ទាប់បន្សំពីសន្ទស្សន៍ V-Dem។

[108] "USAID/ការវិភាគការអភិវឌ្ឍយេនឌ័រ និងបរិយាបន្នកម្ពុជា" USAID ឆ្នាំ2020។

[109] ការប្តេជ្ញាចិត្តកាត់បន្ថយសន្ទស្សន៍វិសមភាព អង្គការអុកស្វាម ឆ្នាំ2020។

តិច ជនជាតិភាគតិច និងក្រុមសាសនាភាគតិច ដូចជា ជនជាតិចាម និងសមាជិកនៃក្រុមអ្នកស្រលាញ់ភេទដូចគ្នា។ ជាចុងក្រោយ យុវជនគឺជាចំណែកដ៏ធំបំផុតនៃចំនួនប្រជាជនកម្ពុជា ប៉ុន្តែក៏ត្រូវបានទុកចោលនៅពីក្រោយផ្នែកសេដ្ឋកិច្ច និងនយោបាយផងដែរ។ ពិន្ទុសន្ទស្សន៍វឌ្ឍនភាពយុវជន ឆ្នាំ ២០១៧ សម្រាប់កម្ពុជាគឺត្រឹមតែ ៤៧,១៤ លើ ១០០។[110] ទោះជាយ៉ាងណាក៏ដោយ ចំនួនយុវជនយ៉ាងច្រើននេះក៏ជាឱកាសដ៏ធំធេងបំផុតសម្រាប់ទីភ្នាក់ងារ USAID នៅក្នុងការគាំទ្រតួអង្គផ្លាស់ប្តូរជំនាន់ថ្មីនៅក្នុងកម្ពុជាផងដែរ។[111]

មានការសន្មតសំខាន់ៗជាច្រើនដែលបានឆ្លុះបញ្ចាំងពីសម្មតិកម្មនិងហានិភ័យរបស់យើងនៅ ដើម្បីសម្រេចបាននូវភាពជោគជ័យរបស់គោលបំណងអភិវឌ្ឍន៍ទី ៣ ដូចដែលត្រូវបានរៀបរាប់នៅក្នុងតារាងទី ១២ ខាងក្រោម។ ហានិភ័យដ៏ធំបំផុតចំពោះ គោលបំណងអភិវឌ្ឍន៍ទី ៣ គឺថា លំហប្រកបដោយអត្ថន័យសម្រាប់អង្គការសង្គមស៊ីវិលធ្វើប្រតិបត្តិការអាចនឹងត្រូវរឹតបន្តឹងបន្ថែមទៀត។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីឆន្ទៈខ្ពស់ជាងមុននៅអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលចូលរួមដោះស្រាយបញ្ហាមួយចំនួនដូចជា យុទ្ធសាស្រ្ត C-TIP របស់ខ្លួនជាដើម។ ទីភ្នាក់ងារ USAID នឹងធ្វើការជាមួយដៃគូអន្តរភ្នាក់ងារ (និងដៃគូផ្សេងទៀត) ដើម្បីធានាថាហានិភ័យនេះនៅតែមានកម្រិតទាបដដែល ហើយនឹងពិនិត្យមើលឡើងវិញនូវការសន្មតនេះ និងការសន្មតផ្សេងទៀតជារៀងរាល់ឆ្នាំ ដែលជាផ្នែកនៃការពិនិត្យបែបផែនការងារ និងការសម្របសម្រួលគោលដៅឡើងវិញ។

**តារាងទី ១២៖ ការសន្មត និងហានិភ័យសំខាន់ៗសម្រាប់គោលបំណងអភិវឌ្ឍន៍ទី ៣**

| ការសន្មត | ហានិភ័យ |
|---|---|
| • រដ្ឋាភិបាលនឹងអនុញ្ញាតឱ្យមានលំហខ្លះសម្រាប់សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (រួមមានប្រព័ន្ធបណ្តាញសង្គម) ដើម្បីដំណើរការ<br>• រដ្ឋាភិបាលនៅតែមានភាពអត់ឱនចំពោះមតិត្រលប់ដែលបច្ចុប្បន្នមិនត្រូវបានចាត់ទុកថា "មានលក្ខណៈនយោបាយ" (ឧ. គុណភាពសេវាសាធារណៈ) | • រដ្ឋាភិបាលអាចចាប់ផ្តើមការផ្តល់ទោសទណ្ឌដល់ប្រជាពលរដ្ឋដែលបានផ្តល់មតិត្រលប់អំពីបញ្ហាដែលបច្ចុប្បន្នមិនត្រូវបានចាត់ទុកថា "មានលក្ខណៈនយោបាយ" (ឧ. ការត្អូញត្អែរអំពីសេវាសាធារណៈ)<br>• រដ្ឋាភិបាលអាចបង្កើនការរឹតត្បិតបន្ថែមទៀតលើអង្គការសង្គមស៊ីវិល សហជីព និងប្រព័ន្ធផ្សព្វផ្សាយ<br>• ច្បាប់ថ្មីៗនឹងបង្កើនការរឹតត្បិតបន្ថែមទៀតទៅលើសេរីភាពស្ថាប័ន |

## របៀបដែលគោលបំណងអភិវឌ្ឍន៍ទី ៣ ជំរុញ J2SR របស់កម្ពុជា

នៅទីបំផុត សកម្មភាព គោលបំណងអភិវឌ្ឍន៍ទី ៣ នឹងជួយជំរុញវឌ្ឍនភាពរបស់ប្រទេសកម្ពុជានៅក្នុងដំណើរឆ្ពោះទៅរកការពឹងផ្អែកលើខ្លួនឯង តាមរយៈការពង្រឹងការចូលរួមរបស់វិស័យសាធារណៈ ឆ្ពោះទៅសម្រេចនូវការប្តេជ្ញាចិត្តកាន់តែម៉ឺតមាត់ចំពោះ*អភិបាលកិច្ចមានការបើកចំហ និងប្រកបដោយគណនេយ្យ*

[110] មាត្រដ្ឋានបន្ទាប់បន្សំ៖ សន្ទស្សន៍វឌ្ឍនភាពយុវជន Deloitte ឆ្នាំ2017។
[111] "ការវាយតម្លៃយុវជនរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ/កម្ពុជា" ឥទ្ធិពលសង្គម ឆ្នាំ2019។

*ភាព*។ ការប្តេជ្ញានេះអាចសម្រេចបានតាមរយៈការធ្វើការជាមួយនឹងតួអង្គសង្គមស៊ីវិលដែលសហការជាមួយតួអង្គផ្សេងទៀតដើម្បីលើកកម្ពស់ដំណើរការប្រជាធិបតេយ្យ។ ការផ្តល់ការគាំទ្រនៅក្នុងការកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលនៅក្នុងការលើកទឹកចិត្ត និងតស៊ូមតិឱ្យរដ្ឋាភិបាលមានការប្តេជ្ញាចិត្តកាន់តែច្រើនឡើង នឹងតម្រូវឱ្យមានវិធីសាស្ត្រប្រកប ដោយនិរន្តរភាព និងរយៈពេលវែង ដែលរាប់បញ្ចូលទាំង ការផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយហានិភ័យដែលកើតមានចំពោះសកម្មជនសិទ្ធិមនុស្សដែលធ្វើការងារនៅជួរមុខ។

តាមរយៈ គោលបំណងអភិវឌ្ឍន៍នេះ ទីភ្នាក់ងារ USAID កំពុងបង្កើនការគាំទ្ររបស់ខ្លួនដល់អង្គការយុវជនវ័យក្មេង ជាពិសេស សហគ្រិនស្ត្រីវ័យក្មេង ដើម្បីលើកកម្ពស់តម្លៃប្រជាធិបតេយ្យនៃការចូលរួមរបស់ប្រជាពលរដ្ឋ ការចូលរួម គំនិតផ្តួចផ្តើម និងការគោរពនីតិរដ្ឋ។ តារាងទី ១៣ សង្ខេបអំពីរបៀបដែល គោលបំណងអភិវឌ្ឍន៍ទី ៣ នឹងរួមចំណែកដល់សមាសធាតុ J2SR នីមួយៗ។

**តារាងទី ១៣៖ ដំណើរឆ្ពោះទៅសម្រេចសមាសធាតុនៃការពឹងផ្អែកលើខ្លួនឯងសម្រាប់ គោលបំណងអភិវឌ្ឍន៍ទី ៣**

| សមាសភាគ J2SR | វិធីសាស្ត្រគោលបំណងអភិវឌ្ឍន៍ទី ៣ |
|---|---|
| ការកំណត់ទំនាក់ទំនងឡើងវិញ | ផ្តោតលើការបង្កើនការត្រួតពិនិត្យសាធារណៈរបស់ស្ថាប័នរដ្ឋាភិបាល និងការចូលរួមរបស់ក្រសួងស្ថាប័នរដ្ឋាភិបាល |
| ការពឹងផ្អែកហិរញ្ញប្បទានលើខ្លួនឯង | បង្កើនតម្លាភាព និងគណនេយ្យភាពនៅក្នុងការមុខងាររដ្ឋាភិបាលដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងអនុញ្ញាតឱ្យមានការបង្កើនមូលនិធិកាន់តែច្រើនចំពោះការពឹងផ្អែកហិរញ្ញប្បទានលើខ្លួនឯង |
| ការចូលរួមរបស់វិស័យឯកជន | ការចូលរួម និងការបង្កើនធនធានវិស័យឯកជនក្នុងការផ្តល់ជំនាញ បច្ចេកវិទ្យា និងការទទួលបាននូវមូលធនដែលមានភាពចាំបាច់សម្រាប់គាំទ្រអាជីវកម្មរបស់ស្ត្រី និងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ។ សម្របសម្រួលការងាររវាងវិស័យឯកជន និងសហភាពដើម្បីបង្កើនគណនេយ្យភាពរបស់រដ្ឋាភិបាលសំដៅលើកស្ទួយសិទ្ធិការងារ។ |
| ការបង្កើតភាពជាដៃគូមានប្រសិទ្ធភាព និងកំណែទម្រង់លទ្ធកម្ម | អនុញ្ញាតឱ្យមានការចូលរួមពីតួអង្គយ៉ាងទូលំទូលាយ រួមមានម្ចាស់ជំនួយផ្សេងទៀត ស្ថាប័នពហុភាគី និងស្ថាប័នថ្នាក់តំបន់ដើម្បីបង្កើនកំណែទម្រង់អភិបាលកិច្ច។ |

## <u>របៀបដែលគោលបំណងអភិវឌ្ឍន៍ទី ៣ ជំរុញតំបន់ឥណ្ឌូប៉ាស៊ីហ្វិកមានសេរីភាព និងបើកចំហ</u>

គោលបំណងអភិវឌ្ឍន៍ទី ៣ ផ្តោតលើការពង្រឹងប្រព័ន្ធប្រជាធិបតេយ្យដោយធ្វើការលើកឡើងនូវបញ្ហាតម្លាភាព និងគណនេយ្យភាពដោយស្របតាមគំនិតផ្តួចផ្តើមតម្លាភាព។ វិធីសាស្ត្រយុទ្ធសាស្ត្ររបស់ទីភ្នាក់ងារ USAID នៅក្នុងគោលបំណងអភិវឌ្ឍន៍នេះ មានគោលបំណងលើកកម្ពស់បរិយាកាសអំណោយផលវិជ្ជមានសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ឱ្យប្រជាពលរដ្ឋចូលរួមកាន់តែច្រើននៅក្នុងការត្រួត

ពិនិត្យទៅលើសេវាកម្មរបស់រដ្ឋាភិបាល និងការធានានូវសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលកែលម្អអភិបាលកិច្ចដែលឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋកាន់តែល្អប្រសើរឡើង។ ការកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល រួមទាំងអង្គការដែលដឹកនាំដោយស្ត្រី និងយុវជន នឹងអនុញ្ញាតឱ្យមានការសន្ទនាបែបស្ថាបនា និងបើកចំហបន្ថែមទៀតរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ វិធីសាស្ត្រនេះផ្តល់នូវជម្រើសមួយសម្រាប់គំរូបែបផ្តាច់ការបន្ថែមទៀត ដែលបង្កហានិភ័យយ៉ាងសំខាន់ដល់ការអភិវឌ្ឍប្រកបដោយចីរភាព អធិបតេយ្យភាព និងអភិបាលកិច្ចដែលឆ្លើយតបនឹងពលរដ្ឋ។ ការបង្កើនលទ្ធភាពទទួលបានព័ត៌មានដែលអាចទុកចិត្តបានក៏នឹងលើកកំពស់សមត្ថភាពរបស់ប្រជាជនកម្ពុជាក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងនាមជាពលរដ្ឋដែលមានចំណេះដឹង។ តាមរយៈការបង្កើនព័ត៌មានអំពីសេវាកម្មរបស់រដ្ឋាភិបាល និងការវិនិយោគសាធារណៈ រួមទាំងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ សង្គមស៊ីវិលនឹងកាន់តែអាចចូលរួមក្នុងការជជែកពិភាក្សាជាសាធារណៈ និងដោះស្រាយបញ្ហាសំខាន់ៗចំពោះការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរួមបញ្ចូល។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែលមានសមត្ថភាពជាងនេះ នឹងអនុញ្ញាតឱ្យប្រជាជនកម្ពុជាចូលរួមកាន់តែមានប្រសិទ្ធភាពជាមួយរដ្ឋាភិបាលរបស់ពួកគេ ដើម្បីជំរុញឱ្យមានសេរីភាពជាមូលដ្ឋាន និងបង្កើនតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាល ដែលកត្តាទាំងពីរនេះចាំបាច់សម្រាប់ការពឹងផ្អែកលើខ្លួនឯងបន្ថែមទៀតរបស់កម្ពុជា។

**អាទិភាពរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ**

រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ពីការប្តេជ្ញាចិត្តចំពោះគំនិតផ្តួចផ្តើមគណនេយ្យភាពសង្គម និងផ្សព្វផ្សាយជាសាធារណៈនូវឧបករណ៍បច្ចេកវិទ្យាមួយចំនួនដើម្បីជំរុញគណនេយ្យភាពសង្គម។ ទោះបីជារហូតមកដល់ពេលនេះ កិច្ចខិតខំប្រឹងប្រែងទាំងនេះបានផ្តោតទៅលើវិស័យដែលត្រូវបានគេមើលឃើញថាមានលក្ខណៈនយោបាយ ដូចជាវិស័យអប់រំ អនាម័យ និងកសិកម្មក៏ដោយ ប៉ុន្តែក៏នៅមានចំណុចជាច្រើនដែលត្រូវការការធ្វើសកម្មភាពច្រើនជាងនេះដូចជា ការអភិរក្សបរិស្ថាន សិទ្ធិដីធ្លី និងការកាប់ឈើខុសច្បាប់ ដែលវិស័យទាំងនេះ ត្រូវបានគេមើលឃើញថាមិនមានការប្តេជ្ញាចិត្តស្រដៀងគ្នាទៅនឹងចំណុចខាងលើនោះទេ។ នៅក្រោមគោលបំណងអភិវឌ្ឍន៍នេះ ទីភ្នាក់ងារ USAID នឹងជំរុញគំនិតផ្តួចផ្តើមគណនេយ្យភាពសង្គម ជាពិសេសនៅក្រោម IR ៣.៣ ដោយសម្លឹងឆ្ពោះទៅរកការផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋដោយប្រើប្រាស់វិធានការគណនេយ្យភាព ដែលពួកគេអាចមានឥទ្ធិពលប្រកបដោយអត្ថន័យ។

បរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិល គឺជាកត្តាសំខាន់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែត្រូវបានរឹតត្បិតកាន់តែខ្លាំងឡើងៗនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ (យោងតាមរបាយការណ៍ស្តីពីសេរីភាពក្នុងពិភពលោកដែលបានរៀបរាប់ខាងលើ) ដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានសម្រាប់ប្រជាពលរដ្ឋក្នុងវិស័យដូចជាគណនេយ្យភាពសាធារណៈ តម្លាភាពរបស់រដ្ឋាភិបាល និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការបង្កើតគោលនយោបាយសាធារណៈ។ ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិល ដែលធ្វើការលើបញ្ហាប្រជាធិបតេយ្យ ឬបញ្ហាសិទ្ធិមនុស្ស ក៏ត្រូវបានរារាំងផងដែរ។[112] ម៉្យាងវិញទៀត ពលរដ្ឋត្រូវបានកាត់ទោសពី

[112] ការវាស់ស្ទង់បន្ទាប់បន្សំ៖ សន្ទស្សន៍ការចូលរួមសង្គមស៊ីវិល. V-Dem ២០១៩ ពិន្ទុ៖ 0,៣៩៤ លើ ១។ ទំនោរនេះកំពុងមានការថយចុះក្នុងពេលកន្លងមកនេះ ដោយមានអតិផរណាច្រើនជារៀងរាល់ឆ្នាំ។

បទបរិហារកេរ្តិ៍ ការផ្សព្វផ្សាយព័ត៌មានមិនពិត និងបទញុះញង់។[113] លើសពីនេះទៅទៀត រាជរដ្ឋាភិបាលបានរៀបចំកិច្ចពិភាក្សាជាមួយសង្គមស៊ីវិលលើច្បាប់សាធារណៈ ដូចជាច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងមានចំណាប់អារម្មណ៍លើការកែលម្អសេវាជូនប្រជាពលរដ្ឋ។

## តួអង្គអភិវឌ្ឍន៍ផ្សេងទៀត

ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតនៅក្នុងវិស័យនេះ រួមមាន សហភាពអឺរ៉ុប ស៊ុយអែត អូស្ត្រាលី ធនាគារពិភពលោក និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)។ ទីភ្នាក់ងារ USAID តែងតែជំរុញឱ្យមានការចូលរួមពីសំណាក់ម្ចាស់ជំនួយផ្សេងទៀត ដើម្បីធានាថាជំនួយនានាត្រូវបានសម្របសម្រួល និងមិនមានភាពជាន់គ្នា។ លើសពីនេះ ទីភ្នាក់ងារ USAID ក៏បានលើកឡើងអំពីបទពិសោធន៍យ៉ាងទូលំទូលាយរបស់ខ្លួនពាក់ព័ន្ធនឹងដៃលផ្តល់មូលនិធិដល់ក្រុមសង្គមស៊ីវិល អស់រយៈពេលជាង ២ ទសវត្សរ៍កន្លងមកផងដែរ ដែលជារឿយៗ បានផ្តល់ការវាយតម្លៃរបស់ខ្លួនអំពីទិដ្ឋភាពសង្គមស៊ីវិលជូនដល់ម្ចាស់ជំនួយផ្សេងទៀត។ វិធីសាស្ត្ររបស់ទីភ្នាក់ងារ USAID គឺបំពេញបន្ថែមទៅលើវិធីសាស្ត្ររបស់ម្ចាស់ជំនួយទាំងនេះតាមពីរវិធី៖ ១) ទីភ្នាក់ងារ USAID ជារឿយៗកំណត់អត្តសញ្ញាណអង្គការសង្គមស៊ីវិលថ្មីៗ តាមរយៈបទពិសោធន៍ការងារជាយូររបស់ខ្លួនក្នុងការពង្រឹងសង្គមស៊ីវិល និង ២) ទីភ្នាក់ងារ USAID អាចផ្តល់ជំនួយតាមគោលដៅដល់អង្គការសង្គមស៊ីវិលដែលមានឈ្មោះរយៈពេលយូរមក ដែលខ្លួនគាំទ្រដោយផ្តោតលើកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយរបស់អង្គការសង្គមស៊ីវិលទាំងនេះនៅក្នុងខេត្តនានាទូទាំងប្រទេស។ ជាចុងក្រោយ ទីភ្នាក់ងារ USAID ចាប់ដៃគូជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីលើកកម្ពស់សាររួមគ្នានៃការការពារសិទ្ធិមនុស្ស។

## IR ៣.១៖ ពង្រឹងកិច្ចការពារសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀត

អនុ-IR ៣.១.១៖ ពង្រឹងអង្គការដែលតស៊ូមតិសម្រាប់សិទ្ធិជាមូលដ្ឋាន
អនុ-IR ៣.១.២៖ បង្កើនការតស៊ូមតិសម្រាប់សិទ្ធិការងារ
អនុ-IR ៣.១.៣៖ បង្កើនការតស៊ូមតិសម្រាប់សិទ្ធិដីធ្លី
អនុ-IR ៣.១.៤៖ បង្កើនការតស៊ូមតិសម្រាប់ជនគ្រោះនៃអំពើជួញដូរ

វិធីសាស្ត្រដែលបានស្នើឡើងសម្រាប់ IR ៣.១ គឺផ្តល់សិទ្ធិអំណាចដល់អ្នកការពារសិទ្ធិ និងអង្គការនានានូវការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដើម្បីពង្រឹងសិទ្ធិស្របច្បាប់ (ឧ. សហជីពការងារ និងក្រុមមូលដ្ឋានដែលពាក់ព័ន្ធនឹងជម្លោះដីធ្លី)។ ទីភ្នាក់ងារ USAID នឹងគាំទ្រក្រុមទាំងនេះក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការបង្រួបបង្រួម និងតស៊ូមតិសម្រាប់ការការពារសិទ្ធិមនុស្សកាន់តែខ្លាំងឡើងៗ។ ខណៈពេលដែលរដ្ឋធម្មនុញ្ញកម្ពុជាផ្តល់ការការពារសិទ្ធិមនុស្សដ៏រឹងមាំ ផែនទីបង្ហាញផ្លូវរបស់ប្រទេស J2SR ក៏បានបង្ហាញថាការអនុវត្តសិទ្ធិទាំងនេះក៏ជាបញ្ហាប្រឈមផងដែរ។[114] ជាប្រវត្តិសាស្ត្រ គោលនយោបាយរបស់រដ្ឋាភិបាលលើវិស័យការងារ និងដីធ្លីបានរារាំងលទ្ធភាពរបស់ប្រជាជន

[113] "ការពិនិត្យតាមការកំណត់ជាសកលជាលើកទីពីរ៖ ប្រទេសកម្ពុជា," OHCHR, ឆ្នាំ ២០១៩
[114] "ប្រទេសកម្ពុជា៖ ដំណើរទៅកាន់ផែនទីប្រទេសដែលពឹងផ្អែកលើខ្លួនឯងឆ្នាំ ២០២១," ទីភ្នាក់ងារ USAID

កម្ពុជាក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ។ ជាឧទាហរណ៍ ច្បាប់ស្តីពីសហជីពបានបង្កការលំបាកដល់កម្មករនៅកម្ពុជាក្នុងការរួបរួម និងស្វែងរកការដោះស្រាយចំពោះការរំលោភសិទ្ធិការងារ។ ដូចគ្នានេះផងដែរ ឯករាជ្យភាពរបស់តុលាការក៏ត្រូវបានគេសង្ស័យ ដោយសារតុលាការតែងតែប្រឆាំងនឹងប្រជាជនកម្ពុជាដែលត្រូវបានគេដកហូតដីរបស់ពួកគេនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ពួកគេ។[115] ឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងការចូលរួមកាន់តែប្រសើរជាមួយរដ្ឋាភិបាលរបស់ពួកគេដើម្បីដោះស្រាយបញ្ហាទាំងនេះគឺមានផ្តល់ជូន ដែលនឹងត្រូវបានគាំទ្រតាមរយៈ IR នេះ។

ទីភ្នាក់ងារ USAID ជឿជាក់ថានឹងមានឱកាសមួយសម្រាប់តួអង្គដែលត្រូវបានជំរុញជាចម្បងដោយការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដូចជាវិស័យការងារ និងសិទ្ធិដីធ្លី ដើម្បីធ្វើជាដៃគូជាមួយអង្គការសិទ្ធិមនុស្សផ្សេងទៀតដើម្បីលើកកម្ពស់សិទ្ធិក្រោមច្បាប់កម្ពុជា។ សិទ្ធិដីធ្លី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវបានគេកំណត់ថាជាបញ្ហាសំខាន់ក្នុងអំឡុងកិច្ចពិភាក្សាមុន CDCS នៅទូទាំងប្រទេស ក្នុងនោះរួមទាំងតំបន់ជនបទដូចជាខេត្តមណ្ឌលគិរី និងកណ្តាលទីក្រុងដែលកំពុងមានការរីកចម្រើនដូចជាខេត្តព្រះសីហនុផងដែរ។[116] លើសពីនេះការពង្រីកវិស័យកាត់ដេរក្នុងទសវត្សរ៍ចុងក្រោយនេះ បាននាំមកនូវសិទ្ធិការងារ ការការពារកម្មករ និងតម្រូវការក្នុងការដោះស្រាយវិសមភាពយេនឌ័រ ខណៈដែលស្ត្រីមានប្រមាណ ៨៥ ភាគរយ នៃកម្លាំងពលកម្មក្នុងវិស័យនេះ ប៉ុន្តែមានតំណាងតិចតួចក្នុងថ្នាក់គ្រប់គ្រង និងតួនាទីជាអ្នកដឹកនាំ។[117] បញ្ហាផ្លូវច្បាប់ជុំវិញសិទ្ធិការងារ និងដីធ្លី គឺជាឱកាសមួយដើម្បីពង្រីកសម្ព័ន្ធនៃអង្គការនានាដែលកំពុងស្វែងរកការដោះស្រាយបញ្ហាជាមួយរដ្ឋាភិបាល។ ទីភ្នាក់ងារ USAID ក៏នឹងបន្តការងាររបស់ខ្លួនក្នុងការពង្រឹងសមត្ថភាពរបស់អង្គការសិទ្ធិមនុស្សដែលខ្លួនបានគាំទ្ររួចហើយផងដែរ។

ដូចដែលបានរៀបរាប់ខាងលើ ទោះបីជារាជរដ្ឋាភិបាលរក្សាគោលនយោបាយ និងច្បាប់គ្រប់គ្រង C-TIP ក៏ដោយ ក៏ការអនុវត្តមានភាពមិនស្មើគ្នា និងខ្សោយនៅឡើយនោះទេ។ IR នេះក៏នឹងលើកឡើងអំពីវិធានការ C-TIP ផងដែរ។ ការចូលរួមចំណែករបស់ទីភ្នាក់ងារ USAID ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងបេសកកម្មទាំងមូលរបស់ស្ថានទូតអាមេរិក ពាក់ព័ន្ធនឹងការធ្វើការតាមរយៈភាពជាដៃគូក្នុងស្រុក ដើម្បីលើកកម្ពស់សិទ្ធិរបស់អ្នករស់រានមានជីវិតពីការជួញដូរមនុស្ស ក្នុងនោះរួមទាំងអ្នកដែលរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការកេងប្រវ័ញ្ចផ្លូវភេទ ដោយធ្វើការលើការបង្ការ ការកាត់ទោស ការការពារ និងភាពជាដៃគូ។ ដៃគូនានា នឹងអប់រំសហគមន៍អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងគ្មានសុវត្ថិភាព តាមដានយ៉ាងដិតដល់នូវករណីជួញដូរមនុស្ស និងតស៊ូមតិសម្រាប់ចំណាត់ការរបស់រដ្ឋាភិបាលដើម្បីឱ្យជនល្មើសទទួលខុសត្រូវ និងផ្តល់ការគាំទ្រ និងជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះពីការជួញដូរ និងក្រុមគ្រួសាររបស់ពួកគេដើម្បីពង្រឹងការទាមទារយុត្តិធម៌ និងសំណងរបស់ពួកគេ។ ការងារនេះក៏នឹងគាំទ្រដល់ការធ្វើសមាហរណកម្មឡើងវិញសម្រាប់អ្នករស់រានមានជីវិតពីការជួញដូរ រួមទាំងការលើកកម្ពស់ជីវភាព និងការបណ្តុះបណ្តាល

[115] "[របាយការណ៍នៃការឃ្លាំមើលសិទ្ធិមនុស្សពិភពលោកឆ្នាំ ២០២០](),” អង្គការ Human Rights Watch, ឆ្នាំ ២០១៩

[116] "ឯកសារសង្ខេបអំពីការវិភាគយុទ្ធសាស្ត្រសហការនៃការអភិវឌ្ឍន៍ប្រទេសរបស់ទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា៖ ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ និងអភិបាលកិច្ច" Social Impact, Inc., ឆ្នាំ2020

[117] "របាយការណ៍ថ្មី "ភ្លើងបំភ្លឺ" លើថាមវន្តយេនឌ័រនៅក្នុងរោងចក្រប្រទេសកម្ពុជា" BetterWork, ថ្ងៃទី07 ខែមីនា ឆ្នាំ2018

ដើម្បីការពារអ្នករស់រានមានជីវិតពីអំពើជួញដូរ ពីការទទួលរងការរំលោភបំពានការងារបន្ថែម។ ជាចុងក្រោយ ទីភ្នាក់ងារ USAID នឹងផ្តល់ជំនួយបច្ចេកទេសដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើការគ្រប់គ្រង និងរាយការណ៍ទិន្នន័យ TIP ដែលរួមមានទិន្នន័យ និងការខិតខំប្រឹងប្រែងទាក់ទងនឹងការ ការពារ និងជំនួយជនរងគ្រោះ។

## IR ៣.២៖ បង្កើនការចូលរួម និងសកម្មភាពរបស់ពលរដ្ឋក្នុងកំណែទម្រង់

> អនុ-IR ៣.២.១៖ ពង្រឹងសមត្ថភាពរបស់ស្ត្រីដើម្បីតស៊ូមតិក្នុងកំណែទម្រង់
> អនុ-IR ៣.២.២៖ ពង្រឹងសមត្ថភាពរបស់យុវជន ដើម្បីតស៊ូមតិក្នុងកំណែទម្រង់
> អនុ-IR ៣.២.៣៖ បង្កើនការតស៊ូមតិសម្រាប់បរិយាបន្ន និងការមិនរើសអើង

សកម្មភាពកំណែទម្រង់ក្រោម IR ៣.២ ត្រូវតែទទួលបានការគាំទ្រកាន់តែខ្លាំងឡើងដោយក្រុមជាច្រើន រួមមាន៖ អង្គការមិនមែនរដ្ឋាភិបាល ស្ត្រី យុវជន ប្រជាជនដែលខ្វះខាត និងអង្គការដែលលើកកម្ពស់ផលប្រយោជន៍របស់ពួកគេ។ សកម្មភាពដែលបានគ្រោងទុកនៅក្រោម IR នេះ នឹងផ្តល់ជំនួយដល់ក្រុមដែលមិនត្រូវបានគេគិតគូរ ដើម្បីការពារខ្លួននៅក្នុងលំហពលរដ្ឋ និងលើកកម្ពស់ការគោរពកាន់តែទូលំទូលាយចំពោះភាពខុសគ្នានៅក្នុងសង្គមកម្ពុជា។ ឧទាហរណ៍នៃចំនួនប្រជាជនដែលមិនត្រូវបានគេគិតគូរ រួមមានអ្នកស្រឡាញ់ភេទដូចគ្នា ជនជាតិភាគតិច និងក្រុមសាសនា និងជនមានពិការភាព។ លើសពីនេះ សកម្មភាពក្រោម IR នេះនឹងពង្រឹងទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្កើតវេទិកាប្រព័ន្ធផ្សព្វផ្សាយ និងខ្លឹមសារដែលមានលក្ខណៈពិត ទាក់ទាញ និងផ្តល់ព័ត៌មានអំពីបញ្ហាពលរដ្ឋ។

ស្ត្រីប្រឈមមុខនឹងឧបសគ្គជាច្រើនចំពោះការចូលរួមផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយនៅក្នុងប្រទេសកម្ពុជា ដូចដែលបានពិពណ៌នានៅក្នុងផ្នែកសម្មតិកម្មនៃការអភិវឌ្ឍន៍ខាងលើ និងរៀបរាប់លម្អិតនៅក្នុងការវិភាគយេនឌ័រ និងការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្នរបស់ទីភ្នាក់ងារ USAID។[118] ការជម្នះឧបសគ្គទាំងនេះគឺជាគោលដៅរយៈពេលវែងដ៏សំខាន់នៃយុទ្ធសាស្ត្រនេះ។ ការកសាងសមត្ថភាពរបស់អង្គការដែលដឹកនាំដោយស្ត្រី និងយុវជន ដែលតស៊ូមតិសម្រាប់បរិយាបន្ន និងការមិនរើសអើង នឹងពង្រីកលំហនៃការចូលរួម និងសមត្ថភាពរបស់ប្រជាពលរដ្ឋ ដើម្បីជំរុញឱ្យមានកំណែទម្រង់ពីរាជរដ្ឋាភិបាលកម្ពុជា។ បញ្ហាប្រឈមមួយទៀតនៅក្នុង IR នេះ គឺជាការធានាឱ្យបាននូវកម្រិតខ្ពស់នៃការចូលរួមរបស់យុវជននៅក្នុងសកម្មភាពទាំងនេះ។ ទីភ្នាក់ងារ USAID នឹងដោះស្រាយបញ្ហានេះ តាមរយៈកម្មវិធីប្រកបដោយភាពច្នៃប្រឌិត ដែលទាក់ទាញចំណាប់អារម្មណ៍របស់យុវជនកម្ពុជា។ ជាការពិតណាស់ ការវាយតម្លៃយុវជនឆ្លងវិស័យបានកំណត់ថា ការចូលរួមរបស់យុវជនតម្រូវឱ្យមានកម្មវិធីឯកទេស ហើយទីភ្នាក់ងារ USAID នឹងធ្វើការងារ ដើម្បីបង្កើតកម្មវិធីប្រភេទទាំងនេះ។[119] គោលបំណងនៃ IR នេះក៏ជាការបំពេញបន្ថែមទៅនឹងកំណើនសេដ្ឋកិច្ច ជីវភាពរស់នៅ និងលទ្ធផលនៃការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងគោលបំណងអភិវឌ្ឍនទី ១ ផងដែរ។

[118] "ការវិភាគយេនឌ័រ និងការអភិវឌ្ឍប្រកបដោយបរិយាបន្នរបស់ទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា" ទីភ្នាក់ងារ USAID, ឆ្នាំ ២០២០
[119] "ការវាយតម្លៃយុវជនឆ្លងវិស័យរបស់ទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា" ទីភ្នាក់ងារ USAID, ឆ្នាំ ២០១៩

## IR ៣.៣៖ ពង្រឹងការត្រួតពិនិត្យសាធារណៈទៅលើស្ថាប័នរដ្ឋាភិបាល

> អនុ-IR ៣.៣.១៖ កែលម្អលទ្ធភាពទទួលបានព័ត៌មានអំពីដំណើរការ និងការអនុវត្តការងាររបស់រដ្ឋាភិបាល
> អនុ-IR ៣.៣.២៖ បង្កើនការតស៊ូមតិ និងផ្តល់មតិត្រលប់អំពីសេវាសាធារណៈ
> អនុ-IR ៣.៣.៣៖ កែលម្អការទទួលបានរបាយការណ៍ផ្សព្វផ្សាយឯករាជ្យ

គណនេយ្យភាពសង្គម ត្រូវតែពង្រឹងបន្ថែមតាមរយៈការពង្រីកលទ្ធភាពទទួលបានព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យសម្រាប់ប្រជាជនកម្ពុជា និងតាមរយៈការជំរុញឱ្យប្រជាពលរដ្ឋមានលទ្ធភាពតាមដានសេវាសាធារណៈ។ ទីភ្នាក់ងារ USAID ក៏នឹងមានបំណងធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មានអំពីដំណើរការ និងការអនុវត្តរបស់រដ្ឋាភិបាល ព្រមទាំងពង្រឹងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងការរាយការណ៍។ លទ្ធផលរកឃើញសំខាន់មួយពីការពិគ្រោះយោបល់មុន CDCS គឺថាមានទស្សនមួយលើកឡើងថាសាធារណជនមិនដឹងថាតើសកម្មភាពអ្វីដែលពួកគេអាចធ្វើបានដើម្បីដោះស្រាយកង្វល់ចំពោះ សេវាកម្មរដ្ឋាភិបាល ឬប្រភពព័ត៌មានដែលអាចជួយពួកគេធ្វើដូច្នេះបាននោះទេ។[120] ព័ត៌មានមានតម្លាភាពអំពីទិន្នន័យរបស់រដ្ឋាភិបាល ថវិកា និងគោលនយោបាយ និងការសម្រេចចិត្តរបស់រដ្ឋាភិបាលគឺចាំបាច់ណាស់សម្រាប់ប្រជាពលរដ្ឋ និងអ្នកសារព័ត៌មាន ដើម្បីវាយតម្លៃសេវាសាធារណៈ និងគោលនយោបាយ និងធានាឱ្យបាននូវការគោរពសិទ្ធិដោយស្របតាមរដ្ឋធម្មនុញ្ញ។ ក្នុងឆ្នាំ ២០១៧ សារព័ត៌មាន និងវិទ្យុចំនួន ១៩ ស្ថាប័ន ត្រូវបានបង្ខំឱ្យបិទការិយាល័យរបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ឱកាសដោះស្រាយបញ្ហាប្រឈមទាំងនេះគឺមាន។ ឧទាហរណ៍ រដ្ឋាភិបាលលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងគណនេយ្យភាពសង្គមក្នុងវិស័យមួយចំនួន។ ទីភ្នាក់ងារ USAID នឹងគាំទ្រដល់ឱកាសទាំងនោះ ជាពិសេសក្នុងវិស័យអប់រំ កសិកម្ម និងការគ្រប់គ្រងកាកសំណល់ ដើម្បីគាំទ្របន្ថែមទៀតដល់សមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តមុខងារត្រួតពិនិត្យរបស់ពួកគេ។ ជាងនេះទៅទៀត សក្តានុពលថាមពលក្នុងប្រទេសនាំឱ្យស្ត្រី និងក្រុមមិនត្រូវបានគេគិតគូរ (ឧទាហរណ៍ ជនមានពិការភាព ជនជាតិភាគតិច ក្រុមសាសនា និងយេនឌ័រ) ដែលមានសមត្ថភាពមានកម្រិតក្នុងការចូលរួមត្រួតពិនិត្យសាធារណៈ។ កិច្ចខិតខំប្រឹងប្រែងដើម្បីរួមបញ្ចូលពួកគេជាអ្នកចូលរួមសកម្មត្រូវតែបញ្ចូលទៅក្នុងសកម្មភាពដែលធានាសុវត្ថិភាព និងសន្តិសុខ និងលើកកម្ពស់ការពង្រីកឱកាសនៃភាពជាអ្នកដឹកនាំ។[121]

ហេតុការណ៍អាកាសធាតុដែលរំខាន ឬបង្កភាពតានតឹងលើមុខងារដំណើរការរបស់រដ្ឋាភិបាលក្នុងតំបន់ រួមទាំងការផ្តល់សេវាវិមជ្ឈការសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុក និងការគ្រប់គ្រងធនធានធម្មជាតិ អាចរាំងស្ទះដល់ការផ្តល់សេវា និងការត្រួតពិនិត្យសាធារណៈរបស់ស្ថាប័នរដ្ឋាភិបាល។[122] ការគាំទ្រប្រព័ន្ធផ្តល់សញ្ញាជាមុន ដែលអាចផ្តល់ពេលវេលាគ្រប់គ្រាន់នៅក្នុងការរៀបចំសម្រាប់ហេតុការណ៍បែបនេះ និងផលប៉ះពាល់ដែលអាចកើតមានរបស់ពួកគេ និងការតស៊ូមតិសម្រាប់ការប្រើប្រាស់ព័ត៌មានអាកាសធាតុដើម្បីធ្វើ

[120] ទីភ្នាក់ងារ USAID/កម្ពុជា៖ ឯកសារសង្ខេបវិភាគយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេស៖ ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ និងអភិបាលកិច្ច។ រៀបចំដោយ Social Impact, Inc., ឆ្នាំ ២០២០

[121] "ការវិភាគយេនឌ័រ និងការអភិវឌ្ឍន៍បរិយាបន្នរបស់ទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា" ទីភ្នាក់ងារ USAID ឆ្នាំ ២០២០

[122] "ការវិភាគការគ្រប់គ្រងហានិភ័យអាកាសធាតុរបស់ទីភ្នាក់ងារ USAID/ប្រទេសកម្ពុជា" ទីភ្នាក់ងារ USAID ឆ្នាំ ២០២០

ផែនការឱ្យបានគ្រប់គ្រាន់សម្រាប់ការផ្តល់សេវាសាធារណៈ និងការអន្តរាគមន៍អាចជួយកាត់បន្ថយហានិភ័យទាំងនោះ។

ឧត្តមភាពប្រៀបធៀបរបស់ទីភ្នាក់ងារ USAID នៅក្នុងផ្នែកលទ្ធិប្រជាធិបតេយ្យ សិទ្ធិ និងអភិបាលកិច្ច និង ការប្រឆាំងការជួញដូរមនុស្ស (C-TIP)

រដ្ឋាភិបាលអាមេរិក បាននិងកំពុងគាំទ្រអ្នកការពារសិទ្ធិមនុស្សជាច្រើនឆ្នាំមកហើយ ហើយទីភ្នាក់ងារ USAID មានទំនាក់ទំនងការងារយ៉ាងរឹងមាំជាមួយក្រុមអស់ទាំងនេះ ក៏ដូចជាអង្គការសង្គមស៊ីវិល និងសហជីពផ្សេងទៀតផងដែរ។ យើងនឹងកសាងបន្ថែមលើភាពជោគជ័យកន្លងមកនេះ និងកេរ្តិ៍ឈ្មោះរបស់ទីភ្នាក់ងារ USAID ដើម្បីពង្រីកមូលដ្ឋានភាពជាដៃគូរបស់យើង និងកសាងសម្ព័ន្ធភាពកាន់តែទូលំទូលាយដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាព និងបែបស្ថាបនា ជាមួយរាជរដ្ឋាភិបាលក្នុងការគាំទ្រការធ្វើកំណែទម្រង់នេះ។ ទីភ្នាក់ងារ USAID មានប្រវត្តិជាយូរណាស់មកហើយនៅកម្ពុជាពាក់ព័ន្ធនឹងការផ្តល់ជំនួយបែបនេះ ដែលជាឧត្តមភាពប្រៀបធៀបគួរឱ្យកត់សម្គាល់។ ទីភ្នាក់ងារ USAID បានគាំទ្រយុទ្ធនាការកំណែទម្រង់ច្បាប់អង្គការមិនមែនរដ្ឋាភិបាល ដែលឃើញថាមានការកើនឡើងនៃការចូលរួមរបស់ប្រជាពលរដ្ឋពីតួអង្គនានានៅទូទាំងប្រទេស។ ទីភ្នាក់ងារ USAID ក៏មានឧត្តមភាពប្រៀបធៀបទាក់ទងនឹងអំណាចកោះប្រជុំរបស់ខ្លួនដែលជាផ្នែកមួយនៃរដ្ឋាភិបាលអាមេរិកផងដែរ។ កាលពីពេលថ្មីៗនេះ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ក៏បានកោះប្រជុំអន្តរក្រសួង C-TIP ដោយប្រើវិធីសាស្ត្ររដ្ឋាភិបាលទាំងមូល ដែលទីភ្នាក់ងាររបស់រដ្ឋាភិបាលអាមេរិក និងក្រសួងជាច្រើនបានប្រមូលផ្តុំគ្នាដើម្បីបង្កើតផែនការសកម្មភាពដើម្បីបន្តកិច្ចខិតខំប្រឹងប្រែង C-TIP នៅក្នុងប្រទេសកម្ពុជា។

តើទីភ្នាក់ងារ USAID នឹងកំណត់ឡើងវិញនូវទំនាក់ទំនងជាមួយតួអង្គក្នុងស្រុកដើម្បីការពារសិទ្ធិមនុស្ស និងជំរុញគណនេយ្យភាពរបស់រដ្ឋាភិបាលដោយរបៀបណា?

IR ៣.១ មានគោលបំណងបង្កើតសម្ព័ន្ធភាពរវាងក្រុមផ្សេងៗគ្នា ដែលជាធម្មតាមិនមានដៃគូជាមួយគ្នា ដើម្បីស្វែងរកបុព្វហេតុរួម ក្នុងការតស៊ូមតិ និងពង្រឹងនីតិរដ្ឋ និងសិទ្ធិស្របច្បាប់ និងស្របតាមរដ្ឋធម្មនុញ្ញ។ ការព្រួយបារម្ភយ៉ាងទូលំទូលាយអំពីសិទ្ធិដីធ្លី និងសិទ្ធិការងារ អាចផ្តល់ឱកាសមួយដើម្បីពង្រឹងការតស៊ូមតិ និងការចូលរួមរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាល ដើម្បីពង្រឹងការការពារផ្លូវច្បាប់ដោយការកសាងបណ្តាញរវាងភាគីពាក់ព័ន្ធ ដែលនឹងមិនធ្វើការរួមគ្នាជាប្រចាំ។ ដើម្បីគាំទ្រការងារនេះ វិធីសាស្ត្រថ្មី អាចផ្តោតលើការពង្រីកសម្ព័ន្ធសង្គមស៊ីវិល ដែលរួមមានទាំង “ការអភិវឌ្ឍន៍” និង “ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស” អង្គការសង្គមស៊ីវិល អ្នកសារព័ត៌មាន ក្រុមស្ត្រី ក្រុមយុវជន ក្រុមមិនត្រូវបានគេគិតគូរ ក្រុមជនជាតិដើមភាគតិច និងវិស័យឯកជន ដើម្បីជំរុញឱ្យមានការចូលរួម និងការសន្ទនាកាន់តែច្រើន ការចូលរួមរបស់យុវជន និងស្ត្រីដែលមានច្រើនបំផុត ដើម្បីទទួលបានពីការកែលម្អលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស គឺជារឿងសំខាន់ដើម្បីសម្រេចបាន IR នេះ។ អង្គការសង្គមស៊ីវិលកាន់តែរឹងមាំជាងមុន នៅពេលដែលពួកគេធ្វើសកម្មភាពរួមគ្នា និងរួមគ្នាដោះស្រាយបញ្ហាចំពោះលំហពលរដ្ឋ ដោយធ្វើការដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាព និងស្ថាបនា។ ទីភ្នាក់ងារ USAID នឹងគាំទ្រសម្ព័ន្ធភាពដែលមានលក្ខណៈទូលំទូលាយ និងបរិយាបន្ន រួមទាំងតួអង្គពលរដ្ឋផ្លូវការ និងក្រៅផ្លូវការ និងនៅក្នុងសហគមន៍។ ការបន្តការគាំទ្រផ្នែកការទូត និងការផ្តល់ជំនួយដល់អង្គការសង្គម

ស៊ីវិលក្រោយការអនុម័តច្បាប់រឹតបន្តឹង គឺមានសារៈសំខាន់ណាស់ ក្នុងការបង្ហាញការព្រួយបារម្ភរបស់ពួកគេទៅខាងក្រៅ និងជួយការពារសន្តិសុខរបស់ពួកគេ។ នៅក្នុង IR ៣.២ ទីភ្នាក់ងារ USAID នឹងពង្រឹងសមត្ថភាពរបស់អង្គការដែលដឹកនាំដោយស្ត្រី អង្គការដែលដឹកនាំដោយយុវជន និងអង្គការដែលតស៊ូមតិសម្រាប់បរិយាបន្ន និងការមិនរើសអើង។ IR នេះនឹងពង្រីកមូលដ្ឋានដៃគូរបស់ទីភ្នាក់ងារ USAID ដើម្បីបញ្ចូលតំណាងដែលលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋ និងកំណែទម្រង់ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី យុវជន និងក្រុមដែលមិនត្រូវបានគេគិតគូរ។ ទីភ្នាក់ងារ USAID ក៏គាំទ្រដល់អង្គការដែលដឹកនាំដោយស្ត្រី និងយុវជន ប៉ុន្តែនឹងពង្រីកដៃគូរបស់យើង និងកសាងសមត្ថភាពនៃក្រុមអង្គការថ្មី ដើម្បីបំពេញបន្ថែមនូវលទ្ធផលការកសាងមតិរួមនៅក្នុង IR ៣.១ និងលទ្ធផលគណនេយ្យភាពសង្គមនៅក្នុង IR ៣.៣ ។ នៅក្នុង IR ៣.៣ ទីភ្នាក់ងារ USAID កំពុងចាប់ដៃគូកាន់តែច្រើនជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដ៏ទូលំទូលាយជាងពេលមុនៗ។ ទីភ្នាក់ងារ USAID កំពុងធ្វើដូច្នេះដោយមានការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយម្ចាស់ជំនួយផ្សេងទៀត និង OHCHR ដើម្បីជៀសវាងការខិតខំប្រឹងប្រែងដដែលៗ និងដើម្បីបង្កើតយុទ្ធសាស្ត្រដែលបង្កើនភាពរឹងមាំ និងឧត្តមភាពប្រៀបធៀបរបស់ម្ចាស់ជំនួយនីមួយៗដែលពាក់ព័ន្ធ។

## ការតាមដាន វាយតម្លៃ និងការសិក្សា (MEL)

ទីភ្នាក់ងារ USAID នឹងអនុវត្តកិច្ចខិតខំប្រឹងប្រែង MEL ជាច្រើន ដើម្បីជួយសម្រួលដល់ការសិក្សារៀនសូត្រជាយុទ្ធសាស្ត្រ និងការគ្រប់គ្រងការសម្របខ្លួននៃ CDCS ។ ជាពិសេស ការវាយតម្លៃខាងក្រៅ និងការស្រាវជ្រាវ នឹងត្រូវបានប្រើប្រាស់ដើម្បីស៊ើបអង្កេត និងផ្ទៀងផ្ទាត់ដោយឯករាជ្យនូវប្រសិទ្ធភាពនៃកិច្ចអន្តរាគមន៍។ ឧបករណ៍ និងវិធីសាស្ត្រស្រាវជ្រាវផ្សេងទៀតនឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើតភស្តុតាងដើម្បីជូនដំណឹងដល់ការអនុវត្ត CDCS រួមទាំងការវិភាគសេដ្ឋកិច្ចនយោបាយ ការវាយតម្លៃតាមវិស័យ ករណីសិក្សា ការស្ទង់មតិ វិធីសាស្ត្រចូលរួម ការវាយតម្លៃរហ័ស និងការស្ទង់មតិផ្អែកលើចំនួនប្រជាជន។ តារាងខាងក្រោមសង្ខេបអំពីសំណួរវាយតម្លៃកម្រិតខ្ពស់ដែលអាចត្រូវបានស្វែងយល់បន្ថែម ក្នុងផ្នែកនៃរបៀបវារៈសិក្សារបស់ទីភ្នាក់ងារ USAID៖

| | សំណួរសិក្សាវាយតម្លៃ |
|---|---|
| គោលបំណង អភិវឌ្ឍន៍ទី ១ | • តើសកម្មភាពកំណើនសេដ្ឋកិច្ចដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលអាមេរិកបានកែលម្អជីវភាពរស់នៅរបស់ប្រជាជនយ៉ាងដូចម្តេច?<br>• តើសកម្មភាពដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលអាមេរិកមានឥទ្ធិពលលើការកែប្រែគោលនយោបាយ ដើម្បីកសាងអភិបាលកិច្ចសេដ្ឋកិច្ច និងបរិស្ថានប្រកបដោយប្រសិទ្ធភាពសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពយ៉ាងដូចម្តេច?<br>• តើសកម្មភាពដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលអាមេរិកបានកសាងសមត្ថភាព និងការប្តេជ្ញាចិត្តសម្រាប់អភិបាលកិច្ចសេដ្ឋកិច្ច និងបរិស្ថានយ៉ាងដូចម្តេច? |
| គោលបំណង អភិវឌ្ឍន៍ទី ២ | • តើការវិនិយោគលើគុណភាពនៃការថែទាំសុខភាពទាំងនៅក្នុងវិស័យសុខាភិបាលសាធារណៈ និងឯកជនបានពង្រឹងភាពម្ចាស់ការក្នុងស្រុក និងចីរភាពយ៉ាងដូចម្តេច?<br>• តើអ្វីជាវិធីសាស្ត្រមានប្រសិទ្ធភាពបំផុតក្នុងការកសាងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពនៅក្នុងវិស័យសុខាភិបាល អប់រំ និងគាំពារកុមារ?<br>• តើនៅក្នុងវិសាលភាពកម្រិតណាដែលការចូលរួមក្នុងវិស័យឯកជនជួយកែលម្អលទ្ធផលនៃការអភិវឌ្ឍ? |
| គោលបំណង អភិវឌ្ឍន៍ទី ៣ | • តើអ្វីជាវិធីសាស្ត្រដ៏ល្អបំផុតក្នុងការគាំទ្រអ្នកការពារសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងការរឹតត្បិតលើដំណើរការការងាររបស់ពួកគេ?<br>• តើកត្តាជាក់លាក់តាមបរិបទអ្វីដែលជំរុញឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពជាមួយនឹងវិស័យឯកជន ដើម្បីធ្វើការតស៊ូមតិសម្រាប់អភិបាលកិច្ច និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈពីរាជរដ្ឋាភិបាលកម្ពុជា?<br>• តើអ្វីទៅជាវិធីសាស្ត្រ PSE ឬការរួមបញ្ចូលគ្នានូវវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពសម្រាប់ជំរុញឱ្យមានការផ្តល់ភាពអង់អាចដល់ស្ត្រី និងការចូលរួមរបស់ពលរដ្ឋប្រកបដោយបរិយាបន្ន? |
| ឆ្លងវិស័យ | • តើថាមវន្តយេនឌ័រនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលម្ចាស់ផ្ទះ ជះឥទ្ធិពលលើសមត្ថភាព និងការប្តេជ្ញាចិត្តរបស់ប្រទេសយ៉ាងដូចម្តេច? តើទីភ្នាក់ងារ USAID និងដៃគូជះឥទ្ធិពលលើចំណុចពិចារណាយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីនៅគ្រប់កម្រិតយ៉ាងដូចម្តេច?<br>• តើកិច្ចអន្តរាគមន៍អភិវឌ្ឍន៍ប្រភេទណា ដែលមានប្រសិទ្ធភាពបំផុតក្នុងការរួមចំណែកដល់សមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងការផ្តល់ហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍន៍ខ្លួនឯង?<br>• តើការធ្វើពិពិធកម្មមូលដ្ឋានដៃគូ មានប្រសិទ្ធភាពបែបណាក្នុងការសម្រេចលទ្ធផលអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព? |

# ឧបសម្ព័ន្ធ ១៖ ដំណើររបស់ប្រទេសកម្ពុជាទៅកាន់ការពឹងផ្អែកលើខ្លួនឯង៖ ផែនទីបង្ហាញផ្លូវ ឆ្នាំ ២០២១



USAID
FROM THE AMERICAN PEOPLE

# ដំណើររបស់ប្រទេសកម្ពុជាទៅកាន់ការពឹងផ្អែកលើខ្លួនឯង៖ ទំនោរប្រទេស ឆ្នាំ ២០២១

## សញ្ញាសម្គាល់

- 0-1 Score — ពិន្ទុកម្ពុជា 0-1 ថ្មីៗ, ឈានទៅដល់កម្រិតខ្ពស់ក្នុងពិភពលោក
- 0-1 Score — ពិន្ទុឆ្នាំមុនរបស់ប្រទេសកម្ពុជា 0-1 ថ្មីៗ, ឈានទៅដល់កម្រិតខ្ពស់ក្នុងពិភពលោក
- -------- — ពិន្ទុជាមធ្យមសម្រាប់ប្រទេសដែលមានចំណូលទាប និងមធ្យម

## ការប្តេជ្ញាចិត្ត

### អភិបាលកិច្ចបើកចំហ និងគណនេយ្យភាព

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|---|---|
| ប្រជាធិបតេយ្យសេរី | 0.15 | 0.12 | 0.12 | 0.11 | 0.09 | 0.10 | 0.09 |
| រដ្ឋាភិបាលបើកចំហ | | 0.19 | | 0.02 | 0.00 | 0.06 | 0.06 |

### ការអភិវឌ្ឍប្រកបដោយបរិយាបន្ន

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|---|---|
| ភាពស្មើគ្នានៃក្រុមសង្គម | 0.33 | 0.33 | 0.33 | 0.42 | 0.28 | 0.27 | 0.34 |
| គម្លាតយេនឌ័រសេដ្ឋកិច្ច | 0.64 | 0.67 | 0.64 | 0.70 | 0.73 | 0.78 | |

### គោលនយោបាយសេដ្ឋកិច្ច

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|---|---|
| បរិយាកាសធុរកិច្ច និងវិនិយោគ | 0.29 | 0.28 | 0.28 | 0.27 | 0.27 | 0.27 | |
| សេរីភាពពាណិជ្ជកម្ម | | | | | 0.74 | 0.46 | 0.46 |
| គោលនយោបាយបរិស្ថាន | 0.22 | | 0.11 | | 0.11 | | 0.11 |

### កំណត់សម្គាល់វិធីសាស្ត្រ

លទ្ធផលផែនទីបង្ហាញផ្លូវថ្នាក់ជាតិឆ្នាំ2021 (ចំណុចដិតពណ៌ខ្មៅ) និងលទ្ធផលឆ្នាំមុន (ចំណុចពណ៌ដិតស្រាល) គឺមានលក្ខណៈធម្មតាដូចគ្នា ដើម្បីធានាចំពោះលទ្ធភាពដែលអាចប្រៀបធៀបគ្នាបាន។ នៅក្នុងឧទាហរណ៍មួយចំនួន ទីភ្នាក់ងារ USAID បានចាត់វិធានការមួយចំនួនបន្ថែម ដើម្បីបង្កើនលទ្ធភាពប្រៀបធៀបនៃលទ្ធផលនាពេលកន្លងមក រួមទាំងការកែសម្រួលឆ្នាំរបាយការណ៍ប្រភព ទៅតាមឆ្នាំជាក់ស្តែងនៃវិធានការ និងការដកទិន្នន័យប្រវត្តិសាស្ត្រ ដែលមិនអាចប្រៀបធៀបបានទេ ដោយសារតែការកែសម្រួលវិធីសាស្ត្រ។ សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលសៀវភៅណែនាំអំពីសាស្ត្រផែនទីបង្ហាញផ្លូវថ្នាក់ជាតិ J2SR USAID ។

## សមត្ថភាព

### សមត្ថភាពរដ្ឋាភិបាល

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|---|---|
| ប្រសិទ្ធភាពរដ្ឋាភិបាល | 0.33 | 0.38 | 0.38 | 0.38 | 0.39 | 0.41 | |
| ប្រសិទ្ធភាពប្រព័ន្ធពន្ធដារ | 0.26 | 0.34 | 0.31 | 0.35 | | | |
| សុវត្ថិភាព និងសន្តិសុខ | 0.59 | 0.63 | 0.59 | 0.65 | 0.67 | 0.59 | |

### សមត្ថភាពសង្គមស៊ីវិល

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|---|---|
| សង្គមស៊ីវិល និងប្រសិទ្ធភាពប្រព័ន្ធផ្សព្វផ្សាយ | 0.52 | 0.51 | 0.51 | 0.40 | 0.34 | 0.35 | 0.33 |

### សមត្ថភាពប្រជាពលរដ្ឋ

| | 2013–2019 |
|---|---|
| អត្រាភាពក្រីក្រ (5$/ថ្ងៃ) | មិនមានទិន្នន័យទំនោរ |
| គុណភាពអប់រំ | មិនមានទិន្នន័យទំនោរ |
| សុខភាពកុមារ | មិនមានទិន្នន័យទំនោរ |

### សមត្ថភាពនៃសេដ្ឋកិច្ច

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 |
|---|---|---|---|---|---|---|---|
| ផសស ក្នុងប្រជាជនម្នាក់ | 0.28 | 0.29 | 0.31 | 0.32 | 0.33 | 0.34 | 0.35 |
| ការអនុវត្តព័ត៌មាន ទំនាក់ទំនង បច្ចេកវិទ្យា (ICT) | | | | 0.37 | 0.41 | 0.54 | |
| ការពេញចិត្តចំពោះការនាំចេញ | 0.41 | 0.42 | 0.41 | 0.41 | 0.40 | 0.42 | |

# ផែនទីបង្ហាញផ្លូវនៃការពឹងផ្អែកលើខ្លួនឯង
## ការកំណត់ និងប្រភពសូចនាករ

*ផែនទីបង្ហាញផ្លូវថ្នាក់ជាតិឆ្នាំ ២០២១ បានដកស្រង់នូវទិន្នន័យដែលមានចុងក្រោយបំផុតនៅក្នុងថ្ងៃទី01 ខែកក្កដា ឆ្នាំ ២០២០ ដែលមានលទ្ធផលចុងក្រោយបំផុតដែលគ្របដណ្តប់លើឆ្នាំ ២០១៩ ឬឆ្នាំ ២០១៨។ ទិន្នន័យប្រភពទាំងអស់ គឺបានដកស្រង់ចេញពីវិទ្យាស្ថានភាគីទីបី។ គ្រប់សូចនាករណ៍ទាំងអស់ គឺត្រូវបានវាស់ស្ទង់ស្មើគ្នានៅក្នុងការគណនានៃពិន្ទុប្តេជ្ញាចិត្ត និងសមត្ថភាពជារួម។ ការបង្ហាញអំពីព្រំដែនក្នុងផែនទី មិនមានជាប្រភពប្រើប្រាស់ស្របច្បាប់នោះទេ។*

*សម្រាប់ព័ត៌មានបន្ថែមអំពីការកំណត់ និងប្រភព សូមចូលទៅកាន់ selfreliance.usaid.gov ។*

## ការប្តេជ្ញាចិត្ត

### អភិបាលកិច្ចបើកចំហ និងគណនេយ្យភាព

**ប្រជាធិបតេយ្យសេរី៖** វាស់ស្ទង់សេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការប្រមូលផ្តុំ ការបញ្ចេញមតិ ការបោះឆ្នោត នីតិរដ្ឋ ការរឹតត្បិតប្រព័ន្ធតុលាការអំពីសាខាប្រតិបត្តិ និងបញ្ហានីតិរដ្ឋនៅលើសាខាប្រតិបត្តិ។ ប្រភព៖ ប្រភេទផ្សេងៗនៃប្រជាធិបតេយ្យ (V-Dem)។

**រដ្ឋាភិបាលបើកចំហ៖** វាស់ស្ទង់កម្រិតដែលរដ្ឋាភិបាលចែករំលែកព័ត៌មាន ការផ្តល់ភាពអង់អាចដល់ប្រជាជននូវឧបករណ៍ដែលរក្សាគណនេយ្យភាពរដ្ឋាភិបាល និងជំរុញការចូលរួមរបស់ពលរដ្ឋនៅក្នុងការពិភាក្សាគោលនយោបាយសាធារណៈ។ កត្តារងរួមមាន៖ ការផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យច្បាប់ និងរដ្ឋាភិបាល សិទ្ធិទទួលបានព័ត៌មាន ការចូលរួមរបស់ពលរដ្ឋ និងយន្តការបណ្តឹង។ ប្រភព៖ គម្រោងយុត្តិធម៌ពិភពលោក សន្ទស្សន៍នីតិរដ្ឋ។

### ការអភិវឌ្ឍប្រកបដោយបរិយាបន្ន

**ភាពស្មើគ្នានៃក្រុមសង្គម៖** វាស់ស្ទង់ភាពស្មើគ្នាផ្នែកគោលនយោបាយពាក់ព័ន្ធនឹងការការពារសេរីភាពជនស៊ីវិលនៅគ្រប់ក្រុមសង្គម ដូចដែលមានបញ្ជាក់ដោយក្រុមជនជាតិដើម សាសនា ឋានៈ ពូជសាសន៍ ភាសា និងតំបន់។ ប្រភព៖ ប្រភេទផ្សេងៗនៃប្រជាធិបតេយ្យ (V-Dem) ភាពស្មើគ្នានៃក្រុមសង្គមពាក់ព័ន្ធនឹងសេរីភាពស៊ីវិល។

**គម្លាតយេនឌ័រសេដ្ឋកិច្ច៖** សន្ទស្សន៍ដែលមានសមាសធាតុចំនួនប្រាំ៖ (១) ភាពស្មើគ្នានៃប្រាក់បៀវត្សរ៍រវាងស្ត្រី និងបុរសសម្រាប់ការងារស្រដៀងគ្នា (២) អនុបាត្រនៃប្រាក់ចំណូលរបស់ស្ត្រីដែលរកបានធៀបនឹងចំណូលរបស់បុរស (៣) អនុបាត្រការចូលរួមកម្លាំងពលកម្មស្ត្រីទៅនឹងការចូលរួមរបស់បុរស (៤) អនុបាត្រនៃអ្នកច្បាប់ស្ត្រី មន្ត្រីជាន់ខ្ពស់ និងអ្នកគ្រប់គ្រងទៅនឹងសមាភាគីបុរស និង (៥) អនុបាត្រនៃអ្នកវិជ្ជាជីវៈស្ត្រី និងបុគ្គលិកបច្ចេកទេស ទៅនឹងសមាភាគីបុរស។ ប្រភព៖ វេទិកាសេដ្ឋកិច្ចពិភពលោក របាយការណ៍គម្លាតយេនឌ័រសកល ការចូលរួមសេដ្ឋកិច្ច និងអនុសន្ទស្សន៍ឱកាស។

### គោលនយោបាយសេដ្ឋកិច្ច

**បរិយាកាសធុរកិច្ច និងវិនិយោគ៖** វិធានការសមាសធាតុដែលវាស់ស្ទង់ភាពអនុគ្រោះ (១) លក្ខខណ្ឌសហគ្រាស - កម្រិតដែលទីផ្សារ សហគ្រាស ពន្ធដារ ការងារ និងបទប្បញ្ញត្តិផ្សេងៗដែលជំរុញអាជីវកម្មឱ្យចាប់ផ្តើម ប្រកួតប្រជែង និងពង្រីកវិសាលភាព និង (២) បរិយាកាសវិនិយោគ - វិសាលភាពនៃការវិនិយោគត្រូវបានការពារគ្រប់គ្រាន់តាមរយៈការមានសិទ្ធិលើអចលនទ្រព្យ ការការពារអ្នកវិនិយោគ និងការអនុវត្តកិច្ចសន្យា ក៏ដូចជាអត្ថិភាពនៃមូលធនក្នុងស្រុក និងអន្តរជាតិ។ ប្រភព៖ វិទ្យាស្ថាន Legatum, Prosperity Index។

**សេរីភាពពាណិជ្ជកម្ម៖** វាស់ស្ទង់ភាពបើកចំហរបស់ប្រទេសចំពោះការធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយផ្អែកលើអត្រាពន្ធជាមធ្យម និងឧបសគ្គមិនមែនពន្ធគយចំពោះពាណិជ្ជកម្ម។ ប្រភព៖ Heritage Foundation, Index of Economic Freedom។

**គោលនយោបាយបរិស្ថាន៖** វាស់ស្ទង់ភាពជឿទុកចិត្តបានផ្នែកកិច្ចការបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដោយផ្តោតលើកត្តាលំដាប់នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាមួយនឹងផលប៉ះពាល់បរិស្ថាន ដូចជាគោលនយោបាយថាមពល និងពន្ធដារ និងការលើកទឹកចិត្តនៅកម្រិតក្រុមហ៊ុន និងគ្រួសារ។ ការវាស់ស្ទង់នេះ ក៏ផ្តោតលើកត្តានិតិកម្ម និងបទប្បញ្ញត្តិ ថាត្រូវបានផ្តោតដោយយកចិត្តទុកដាក់ឬយ៉ាងណានោះទេ ក៏ដូចជាឥទ្ធិពលនៃភាគីពាក់ព័ន្ធសង្គមហួសពីកម្រិតរដ្ឋាភិបាល រួមទាំងវិស័យឯកជន និងសង្គមស៊ីវិល។ ប្រភព៖ Bertelsmann Stitung Transformation Index (BTI)។

### ហានិភ័យនៃវិបត្តិបំណុលខាងក្រៅ

អត្រាដែលហានិភ័យនៃវិបត្តិបំណុលវិស័យសាធារណៈរបស់ប្រទេសគឺផ្តោតលើកម្រិតសម្ព័ន្ធចំនួនបួន៖ “ហានិភ័យទាប” “ហានិភ័យមធ្យម” “ហានិភ័យខ្ពស់” និង “វិបត្តិបំណុល”។ ការដាក់ពិន្ទុ គឺផ្អែកលើបំណុល និងរចនាសម្ព័ន្ធទីផ្សារ ទស្សនវិស័យសារពើពន្ធ និងម៉ាក្រូសេដ្ឋកិច្ច និងសមត្ថភាពស្ថាប័ន ដើម្បីគ្រប់គ្រងបន្ទុកបំណុល។ ការដាក់ពិន្ទុនេះ ជួយណែនាំអំពីការសម្រេចចិត្តក្នុងការខ្ចីបំណុលរបស់ប្រទេសដែលមានចំណូលទាប ដើម្បីបំពេញទៅតាមតម្រូវការអភិវឌ្ឍ ខណៈដែលត្រូវកាត់បន្ថយឱកាសនៃការជាប់បំណុលលើសលុប។ ការដាក់ពិន្ទុនេះ គឺមានបង្ហាញឡើងសម្រាប់ប្រទេសមានចំណូលទាប ៦៦ ប្រទេស ដែល IMF រៀបចំដាក់ពិន្ទុវាយតម្លៃ និងមិនទទួលបានពិន្ទុលើសមាសធាតុនៃការប្តេជ្ញាចិត្ត ឬសមត្ថភាព។ ប្រភព៖ មូលនិធិសាច់ប្រាក់អន្តរជាតិ ការវិភាគចីរភាពបំណុលសម្រាប់ប្រទេសចំណូលកម្រិតទាប។

## សមត្ថភាព

### សមត្ថភាពរដ្ឋាភិបាល

**ប្រសិទ្ធភាពរដ្ឋាភិបាល៖** វាស់ស្ទង់គុណភាពនៃសេវាសាធារណៈ គុណភាពនៃសេវាពលរដ្ឋ និងឯករាជ្យភាពរបស់ខ្លួនពីសម្ពាធនយោបាយ គុណភាពនៃការបង្កើត និងអនុវត្តគោលនយោបាយ និងទំនុកចិត្តនៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះគោលនយោបាយដែលបានលើកឡើង។ ប្រភព៖ World Bank, Worldwide Governance Indicator។

**ប្រសិទ្ធភាពប្រព័ន្ធពន្ធដារ៖** អនុបាត្ររវាងការប្រមូលពន្ធជាក់ស្តែងរបស់ប្រទេស និងកម្រិតចំណូលពន្ធដែលបានប៉ាន់ស្មាន ដែលប្រទេសមួយអាចសម្រេចបាន តាមរយៈម៉ាក្រូសេដ្ឋកិច្ច ប្រជាសាស្ត្រ និងលក្ខណៈស្ថាប័ន។ ប្រភព៖ ទីភ្នាក់ងារ USAID ការប្រមូលទិន្នន័យពន្ធ សូចនាករកិច្ចខិតខំប្រឹងប្រែងពន្ធដារ។

**សុវត្ថិភាព និងសន្តិសុខ៖** វាស់វែងអំពីកម្រិតដែលបុគ្គល ឬសហគមន៍ មិនមានជួបប្រទះសង្គ្រាម និងទំនាស់ស៊ីវិល ភេរវកម្ម ភេរវកម្មពាក់ព័ន្ធនឹងនយោបាយ និងអំពើហិង្សា បទល្មើសហិង្សា និងបទល្មើសទ្រព្យសម្បត្តិ។ ប្រភព៖ Legatum Institute, សន្ទស្សន៍វិបុលភាព។

### សមត្ថភាពសង្គមស៊ីវិល

**សង្គមស៊ីវិល និងប្រសិទ្ធភាពប្រព័ន្ធផ្សព្វផ្សាយ៖** វាស់ស្ទង់កម្រិតសកម្មភាព និងយន្តការដែលប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យអាចប្រើប្រាស់ដើម្បីរក្សាគណនេយ្យភាពរដ្ឋាភិបាល។ យន្តការនេះ រួមមានការប្រើប្រាស់ឧបករណ៍មិនផ្លូវការ ដូចជាការកៀរគរសង្គម និងទិន្នានុប្បវត្តន៍ស៊ើបអង្កេត។ ប្រភព៖ ប្រភេទផ្សេងៗនៃប្រជាធិបតេយ្យ (V-Dem) សន្ទស្សន៍គណនេយ្យភាពវិនិច្ឆ័យ។

### សមត្ថភាពប្រជាពលរដ្ឋ

**អត្រាភាពក្រីក្រ (៥$/ថ្ងៃ)៖** វាស់ស្ទង់ភាគរយនៃប្រជាជនដែលរស់នៅក្រោមលក្ខខណ្ឌ 5$/ថ្ងៃនៅក្នុងចំណែកនៃអំណាចទិញ (PPP)។ ប្រភព៖ ធនាគារពិភពលោក PovCalNet។

**គុណភាពអប់រំ៖** តាមដានគុណភាពនៃការអប់រំ ដោយប្រើប្រាស់ពិន្ទុស៊ីគ្នានូវគ្រប់ការធ្វើតេស្តលទ្ធផលសិក្សាសិស្សអន្តរជាតិភាគច្រើន និងបរិមាណនៃសាលារៀនដែលទទួលបាន ដោយប្រើប្រាស់អត្រាចុះឈ្មោះជាក់លាក់ ដើម្បីវាយតម្លៃលទ្ធផលនៃប្រព័ន្ធសិក្សាពាក់ព័ន្ធនៅលើពិភពលោក។ ប្រភព៖ ធនាគារពិភពលោក សន្ទស្សន៍ធនធានមនុស្ស ឆ្នាំសម្របសម្រួលការសិក្សានៃសូចនាករសាលារៀន។

**សុខភាពកុមារ៖** ការវាស់ស្ទង់សមាសធាតុដែលបូកបង្គរមរណភាពកុមារ ការទទួលបានយ៉ាងហោចណាស់ប្រភពទឹកជាមូលដ្ឋាន និងការមានបង្គន់អនាម័យមូលដ្ឋាន។ ប្រភព៖ មជ្ឈមណ្ឌលសកលវិទ្យាល័យកូឡុំប៊ីសម្រាប់បណ្តាញព័ត៌មានវិទ្យាសាស្ត្រផែនដីអន្តរជាតិ (CIESIN)។

### សមត្ថភាពនៃសេដ្ឋកិច្ច

**ផសស ក្នុងប្រជាជនម្នាក់៖** ការវាស់ស្ទង់លំហូរធនធានដែលមានជូនគ្រួសារ ក្រុមហ៊ុន និងរដ្ឋាភិបាល ទៅកាន់ការអភិវឌ្ឍន៍ហិរញ្ញវត្ថុ ដោយសារតែផលិតផលក្នុងស្រុកសរុបរបស់ប្រទេស (PPP) ចែកនឹងប្រជាជនរបស់ប្រទេស។ ប្រភព៖ ធនាគារពិភពលោក សូចនាករអភិវឌ្ឍន៍ពិភពលោក។

**ការអនុវត្តព័ត៌មាន ទំនាក់ទំនង បច្ចេកវិទ្យា (ICT)៖** សន្ទស្សន៍នេះរួមមាន (១) ការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធទូរសព្ទចល័ត (២) ការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតតាមទូរសព្ទ (៣) ការចុះឈ្មោះប្រើអ៊ីនធឺណិតថេរ (៤) ការចុះឈ្មោះប្រើអ៊ីនធឺណិតហ្វាយប៊ឺរ និង (៥) អ្នកប្រើប្រាស់អ៊ីនធឺណិត។ ប្រភព៖ វេទិកាសេដ្ឋកិច្ចពិភពលោក (WEF) សន្ទស្សន៍ប្រកួតប្រជែងសកល។

**ភាពជឿនលឿននៃការនាំចេញ៖** ការវាស់ភាពចម្រុះ និងភាពគ្រប់ជ្រុងជ្រោយនៃការនាំចេញទំនិញរបស់ប្រទេស តួអង្គសំខាន់ៗដែលអាចជួយវាស់វែងភាពគ្រប់ជ្រុងជ្រោយនៃសេដ្ឋកិច្ច និងភាពធន់។ ប្រភព៖ មជ្ឈមណ្ឌលសម្រាប់ការអភិឌ្ឍន៍អន្តរជាតិនៅសកលវិទ្យាល័យ Harvard សន្ទស្សន៍ភាពស្មុគស្មាញផ្នែកសេដ្ឋកិច្ច។

UNCLASSIFIED

USAID | CAMBODIA
FROM THE AMERICAN PEOPLE



# COUNTRY DEVELOPMENT COOPERATION STRATEGY (CDCS)

December 2020 – December 2025

APPROVED FOR PUBLIC RELEASE

# TABLE OF CONTENTS

TABLE OF CONTENTS....2
ACRONYMS....3
MAP OF CAMBODIA....5
EXECUTIVE SUMMARY....1
Figure 1: CDCS Results Framework 6
COUNTRY CONTEXT....7
Salient Factors in Country Context....7
Cambodia's National Development Priorities....12
Key Priorities in the Indo Pacific Region....13
Journey to Self-Reliance (J2SR): Country Roadmap Analysis....13
Country Transition Planning....15
STRATEGIC APPROACH....16
